នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Nov-2019, 14:44
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន ប្តឹងជំទាស់ទៅក្រុមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង០០២/០១

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence N. MWACHANDE-MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Megan HIRST

**ជនជាប់ចោទ:**
ខៀវ សំផន

**មេធាវីការពារក្តី ខៀវ សំផន:**
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

## I. សេចក្តីផ្តើម

1. សំណើសុំប្តឹងជិតចិត្តរបស់ ខៀវ សំផន ចំពោះចៅក្រមអង្គជំនុំជម្រះតុលាការកំពូលចំនួនប្រាំមួយរូប ដែលចៅក្រមទាំងនោះបានសម្រេចសេចក្តីលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង០០២/០១ ("ចៅក្រមដែលរងការជំទាស់") ពីការចូលរួមជំនុំជម្រះក្តីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០២ ("សំណើសុំប្តឹងជិតចិត្ត")[1] មិនបានបំពេញតាមលក្ខខណ្ឌតម្រូវចាំបាច់កម្រិតខ្ពស់ ក្នុងការជម្នះលើសច្ចធារណ៍នៃអនាគតិតុលាការដែលមានលទ្ធភាពវិនិច្ឆ័យលើរឿងក្តីនៅ អ.វ.ត.ក ទេ។ អាស្រ័យមូលហេតុដូចបានថែងដោយសហព្រះរាជអាជ្ញាខាងក្រោម សំណើសុំប្តឹងជិតចិត្តរបស់គាត់ គួរបានបដិសេធ។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយរបស់ខ្លួនក្នុងសំណុំរឿង០០២ បានចោទប្រកាន់ ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មនានាប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[2]។

3. នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ នៅក្នុងដីកាសម្រេចមួយ[3] ដែលក្រោយមកត្រូវបានមោឃភាពដោយអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣[4]។

4. នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបំបែកកិច្ចដំណើរការនីតិវិធីថ្មីមួយទៀត ដោយបានកំណត់វិសាលភាពសំណុំរឿង០០២/០១ ត្រឹមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាប់ពាក់ព័ន្ធទៅនឹងពីរដំណាក់កាលនៃការផ្លាស់ទីលំនៅរបស់ប្រជាជនដោយបង្ខំ និងការ

---

[1] ឯកសារ **F53** សំណើរបស់លោក ខៀវ សំផន សុំប្តឹងជិតចិត្តចៅក្រម ៦ រូប នៃអង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/០១, ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ("សំណើសុំប្តឹងជិតចិត្ត")។

[2] ឯកសារ **D427** ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៦១៣។

[3] ឯកសារ **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ*នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ៥។

[4] ឯកសារ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ ("សេចក្តីសេចម្រេចលើបណ្តឹងសាទុក្ខស្តីពីបំបែកកិច្ចដំណើរការនីតិវិធីលើកទី១") កថាខណ្ឌ ៥២។

សម្លាប់ដែលបានធ្វើឡើងនៅទួលពោធិ៍ជ្រៃ ភ្លាមៗបន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[5]។ អ.ជ.ត.ក បានផ្តល់សច្ចានុម័តលើដីកាបំបែកកិច្ចដំណើរការនីតិវិធីនេះ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០១៣[6]។

5. នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានកំណត់វិសាលភាពសំណុំរឿង ០០២/០២ ដោយបញ្ចូលអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម និងចាម ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរសន្តិសុខ ស-២១ ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅតាមការដ្ឋានទំនប់១មករា សហករណ៍ត្រាំកក់ ព្រលានយន្តហោះកំពង់ឆ្នាំង និងទំនប់ត្រពាំងថ្ម ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបោសសម្អាតផ្ទៃក្នុង[7]។ អ.ជ.ត.ក បានតម្កល់សេចក្តីសម្រេចនេះ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤[8]។

6. នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ អ.ជ.ត.ក បានចេញសាលដីកាបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១[9]។

---

[5] ឯកសារ **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ផ្នែកសម្រេចសេចក្តី (ទំព័រ ៧០)។

[6] ឯកសារ **E284/4/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង០០២ (សេចក្តីសង្ខេបនៃសម្អាងហេតុ) ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ៦-៧, ១៣។ ឯកសារ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១៣ ("សេចក្តីសេចម្រេចលើបណ្តឹងសាទុក្ខបំបែកិច្ចដំណើរការនីតិវិធីលើកទី២") កថាខណ្ឌ៧៦ (សម្អាងហេតុពេញលេញ)។

[7] ឯកសារ **E301/9/1** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ផ្នែកសម្រេចសេចក្តី (ទំព័រ២១)។

[8] ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ("សេចក្តីសេចម្រេចលើបណ្តឹងសាទុក្ខបំបែកិច្ចដំណើរការនីតិវិធីលើកទី៣") កថាខណ្ឌ៩១។

[9] ឯកសារ **F36** សាលដីកាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ("សាលដីកាសំណុំរឿង០០២/០១")។ ចៅក្រម គង់ ស្រ៊ីម, Chandra Nihal Jayasinghe, សោម សិរីវឌ្ឍ, Agnieszka Klonowiecka-Milart, ម៉ុង មុនីចរិយា, Florence Ndele Mwachande-Mumba, និងចៅក្រម យ៉ា ណារិន ជាសមាសភាពនៃអង្គចៅក្រម។

7. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រម និងការកាត់ទោស នៃសំណុំរឿង០០២/០២ ដោយបានផ្តល់នូវសេចក្តីសង្ខេបផ្ទាល់មាត់នៃការសន្និដ្ឋាន និងផ្នែកសម្រេចសេចក្តី[10]។ សាលក្រមជាលាយលក្ខណ៍អក្សរ ត្រូវបានចេញជាបីភាសារបស់តុលាការនេះ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩[11]។

8. នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ខៀវ សំផន បានដាក់សំណើសុំប្តឹងជំទាស់ចៅក្រមរបស់គាត់[12]។ នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញា បានស្នើសុំពេលវេលាបន្ថែមដើម្បីធ្វើការឆ្លើយតប[13]។ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ អ.ជ.ត.ក បានបន្ថែមពេលវេលាកំណត់ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩[14]។

## III. ច្បាប់ជាធរមាន

9. តេស្តិ៍សម្រាប់ការបកស្រាយ និងការអនុវត្តកាតព្វកិច្ចតុលាការអំពីអនាគតិ និងសិទ្ធិទទួលបានអនាគតិ ត្រូវបានបង្កើតឡើងដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Furundžija* នៅតុលាការ ICTY ("តេស្តិ៍ *Furundžija*")៖[15]

[10] ឯកសារ **E1/529.1** ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

[11] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("សាលក្រមសំណុំរឿង០០២/០២")។

[12] ឯកសារ **F53** សំណើរសុំប្តឹងជំទាស់។

[13] ឯកសារ **F53/1** សំណើបន្ទាន់របស់សហព្រះរាជអាជ្ញា សុំពន្យារពេលកំណត់សម្រាប់ចម្លើយតបទៅនឹងសំណើសុំប្តឹងជំទាស់របស់ ខៀវ សំផន ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១១។

[14] ឯកសារ **F53/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យារពេលដាក់សារណាតបទៅនឹងសំណើរបស់ ខៀវ សំផន សុំប្តឹងជំទាស់ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ កថាខណ្ឌ១៣។

[15] អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Furundžija* បានពិចារណាលើលទ្ធភាពលេចឡើងនៃភាពលម្អៀងរបស់ចៅក្រមជំនុំជម្រះក្នុងអំឡុងពេលជំនុំជម្រះ ចៅក្រម Mumba ដោយសារការជាប់ពាក់ព័ន្ធរបស់គាត់ទៅនឹងគណៈកម្មការអង្គការសហប្រជាជាតិស្តីពីឋានៈរបស់ស្ត្រី ("UNCSW") មុនពេលការតែងតាំងគាត់ជាចៅក្រមនៅតុលាការ ICTY។ ខណៈដែលចៅក្រម Mumba គឺជាសមាជិក UNCSW អង្គការនេះបានផ្តន្ទាទោសការរំលោភសេពសន្ថវៈទ្រង់ទ្រាយធំ និងជាប្រពន្ធដែលត្រូវបានចោទប្រកាន់ថាបានកើតមានឡើងក្នុងអំឡុងពេលសង្គ្រាមនៅក្នុងអតីតប្រទេសយូហ្គោស្លាវី និងបានជម្រុញឱ្យតុលាការ ICTY ផ្តល់អាទិភាពការផ្តន្ទាទោសជនទាំងឡាយដែលត្រូវបានចោទថាទទួលខុសត្រូវ។ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានចោទប្រកាន់ថាចៅក្រម Mumba *ពិតជា* លម្អៀងនោះទេ ប៉ុន្តែថា ការជម្រុញជាបន្តរបស់គាត់ចំពោះគោលបំណង និងផលប្រយោជន៍របស់ UNCSW ក្រោយពេលដែលសមាជិកភាពរបស់គាត់បានបញ្ចប់ បានផ្តល់ឱ្យមាន*ការលេចឡើង*នូវភាពលម្អៀងដែលបង្កើតបានជាការបារម្ភអំពីអនាគតិរបស់គាត់។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានពិចារណាលើយុត្តិសាស្ត្រពីតុលាការ

ក្រោយពីបានពិនិត្យមើលយុត្តិសាស្ត្រនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍សន្និដ្ឋានថា មានវិធាន ទូទៅមួយដែលថា ចៅក្រមមិនត្រឹមតែមិនលម្អៀងជាអត្តនោម័តនោះទេ ប៉ុន្តែថែមទាំងមិនគួរ មានអ្វីស្ថិតនៅជុំវិញកាលៈទេសៈនានា ដែលជាសត្យានុម័តនាំឲ្យមានលេចឡើងនូវភាព លម្អៀងនោះឡើយ។ ឈរលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ពិចារណាថា គោលការណ៍ខាងក្រោមនេះ គួរដឹកនាំខ្លួនក្នុងការបកស្រាយ និងការអនុវត្តលក្ខខណ្ឌតម្រូវ អនាគតិនៃលក្ខន្តិកៈ៖

ក. ចៅក្រមមិនមានអនាគតិប្រសិនបើរកឃើញថាភាពលម្អៀងជាក់ស្តែងកើតមាន។

ខ. មានការលេចឡើងនូវភាពលម្អៀងដែលមិនអាចទទួលយកបានប្រសិនបើ៖

i) ចៅក្រមជាភាគីបណ្តឹង ឬគាត់មានប្រយោជន៍ហិរញ្ញវត្ថុ ឬកម្មសិទ្ធិពី លទ្ធផលនៃបណ្តឹងនោះ ឬសេចក្តីសម្រេចរបស់ចៅក្រមនឹងបណ្តាលឲ្យកើត ជាបុព្វហេតុនាំឲ្យគាត់ជាប់ពាក់ព័ន្ធ ជាមួយនឹងភាគីម្ខាងក្នុងចំណោមភាគីទាំង ពីរ។ ក្នុងកាលៈទេសៈនេះចៅក្រមត្រូវដកសិទ្ធិដោយស្វ័យប្រវត្តិ។ ឬ

ii) កាលៈទេសៈទាំងនេះនឹងបណ្តាលឲ្យអ្នកអង្កេតការណ៍មានហេតុផលដែល ត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ ដឹងពីភាពលម្អៀង[16]។

---

សិទ្ធិមនុស្សអឺរ៉ុប ក៏ដូចជាប្រព័ន្ធច្បាប់ជាតិ និងបានរកឃើញថា មានវិធានទូទៅមួយដែលចៅក្រមគួរតែជាអត្តនោម័តមិនមាន ភាពលម្អៀង និងថាមិនគួរមានអ្វីនៅក្នុងកាលៈទេសៈជំវិញដែលជាសត្យានុម័តនាំឲ្យមានការលេចឡើងនូវភាពលម្អៀងនោះទេ។ អង្គជំនុំជម្រះបានគូសបញ្ជាក់លើស្ថានទម្ងន់ចាំបាច់ដែលសច្ចធារណ៍នៃអនាគតិជាប់ជាមួយនឹងចៅក្រម ដែលបានកំណត់ចំណុច ចាប់ផ្តើមដ៏ខ្ពស់ដើម្បីជំទាស់ទៅនឹងសច្ចធារណ៍នោះ។ សរុបមក "ការរិតចិត្តអាចធ្វើឡើងបានតែតាមរយៈការបង្ហាញឲ្យឃើញ ថា មានការបារម្ភដ៏មានហេតុផលអំពីភាពលម្អៀងតាមរយៈមូលហេតុនៃការធ្វើបុរេវិនិច្ឆ័យ ហើយការណ៍នេះត្រូវតែ "បង្ហាញឲ្យ ច្បាស់លាស់""។ *សូមមើល* *Furundžija*, IT-95-17/1-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ ("សាដីកា *Furundžija*") កថាខណ្ឌ១៦៤, ១៦៦, ១៧០, ១៨១-១៨៩, ១៩០-១៩៧។

[16] សាដីកា *Furundžija* កថាខណ្ឌ១៨៩។ *សូមមើលផងដែរ* *Akayesu*, ICTR-96-4-A, សាលដីកា អង្គជំនុំជម្រះសាលា ឧទ្ធរណ៍ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ ("សាលដីកា *Akayesu*") កថាខណ្ឌ២០៣។ *Galić*, IT-98-29-A, សាលដីកា អង្គជំនុំ ជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ ("សាលដីកា *Galić*") កថាខណ្ឌ ៣៩។ *Nahimana* *និងគូកន* ICTR-99-52-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ("សាលដីកា *Nahimana*") កថាខណ្ឌ៤៩។

10. "អ្នកអង្កេតការណ៍មានហេតុផល" ត្រូវបានកំណត់និយមន័យថាជា "បុគ្គលដែលដឹងអំពីកាលៈទេសៈដែលពាក់ព័ន្ធទាំងអស់ ក្នុងនោះរួមបញ្ចូលប្រពៃណីនៃសុច្ចរិតភាព និងអនាគតិភាព ដែលបង្កើតជាប្រវត្តិមួយផ្នែក ជាមួយនឹងការលើកឡើងផងដែរថា អនាគតិភាព គឺជាកាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចជាច្រើនទៀតដែលចៅក្រមធ្វើសម្បថត្រូវគោរពតាម"[17]។

11. អ.វ.ត.ក បានអនុម័តយក និងបានអនុវត្តតេស្ត៍ *Furundžija* និងបទដ្ឋាននៃ "អ្នកអង្កេតការណ៍មានហេតុផល" ខាងលើនេះ[18]។

12. ច្បាប់ជាធរមានដែលនៅសេសសល់ត្រូវបានង្ហាញនៅក្នុងផ្នែកពាក់ព័ន្ធខាងក្រោមនេះ។

## IV. **សារណា**

### <u>ក. ខៀវ សំផន និយាយបំផ្លើសអំពីអានុភាពនៃយុត្តិសាស្ត្រដែលគាត់បានផ្អែកលើ</u>

13. សហព្រះរាជអាជ្ញាឯកភាពទាំងស្រុងថា សិទ្ធិទទួលបានការកាត់ទោសដោយតុលាការមិនលម្អៀង គឺជាផ្នែកមួយនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក[19]។ ទោះជាយ៉ាងណា "យុត្តិសាស្ត្រពាក់ព័ន្ធ" ដែល ខៀវ សំផន ផ្អែកលើដើម្បីគាំទ្រអំណះអំណាងរបស់គាត់[20] មិនមានវិធីណាបង្កើតបានជា

---

[17] សាលដីកា *Furundžija* កថាខណ្ឌ ១៩០។

[18] *សូមមើលឧទាហរណ៍* ឯកសារ **C11/29** សេចក្តីសម្រេចស្តីពីបណ្តឹងជំទាស់ដិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន៍យ ថុល រង់ចាំបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នក្នុងរឿងក្តី នួន ជា អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ("សេចក្តីសម្រេចលើបណ្តឹងដិតចិត្តចៅក្រម នៃ ថុល") កថាខណ្ឌ ២០-២១។ ឯកសារ **E5/3** សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងដិតចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ ៦។ ឯកសារ **E55/4** សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងដិតចិត្តចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ ("សំណុំរឿង០០២/០១ សេចក្តីសម្រេចលើបណ្តឹងដិតចិត្តចៅក្រម អ.ជ.ស.ដ") កថាខណ្ឌ១១-១២។ Special SC02-1/4 សេចក្តីសម្រេចលើសំណើរបស់ អៀង ធិរិទ្ធ សុំដិតចិត្តចៅក្រម សោម សិរីវឌ្ឍ ដោយសារកង្វះឯករាជភាព អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ១០។ ឯកសារ **E314/12/1** សម្អាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងដិតចិត្ត ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ("សំណុំរឿង០០២/០២ សេចក្តីសម្រេចលើបណ្តឹងដិតចិត្តចៅក្រម អ.ជ.ស.ដ") កថាខណ្ឌ៣៣។

[19] ឯកសារ **F53** សំណើសុំប្តឹងដិតចិត្ត កថាខណ្ឌ១២-១៧។

[20] ឯកសារ **F53** សំណើសុំប្តឹងដិតចិត្ត កថាខណ្ឌ២៥-៣៩។

យុត្តិសាស្ត្រ "ខ្ពស់បំផុត" ដែលនៅពេលអនុវត្តចំពោះរឿងក្តីនេះ "គ្មានការសង្ស័យ" ចំពោះភាពលម្អៀងរបស់ចៅក្រមដែលរងការប្តឹងជំទាស់ចិត្តទាំងនេះទេ[21]។ ផ្ទុយទៅវិញ ខៀវ សំផន ផ្អែកលើការវិភាគរបស់ចៅក្រមជំទាស់របស់ អ.វ.ត.ក តែម្នាក់គត់ ជាសេចក្តីសម្រេចដែលមិនគួរឱ្យជឿជាក់ និងផ្ទុយពីគេដែលធ្វើឡើងដោយចៅក្រមតែម្នាក់នៅយន្តការអន្តរជាតិ ដែលត្រូវបានចាត់តាំងឱ្យបំពេញមុខងារនៅសេសសល់របស់តុលាការឧក្រិដ្ឋកម្ម ("យន្តការ") និងរឿងក្តីចំនួនបី មកពីតុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECtHR")។ ទាំងអស់នេះផ្ទុយទៅនឹងយុត្តិសាស្ត្រដ៏ត្រឹមត្រូវ ដែលតម្កល់សច្ចធារណ៍ខ្ពស់បំផុតនៃអនាគតិរបស់តុលាការ។

14. **មតិផ្ទុយដោយផ្អែករបស់ចៅក្រម Downing៖** ខៀវ សំផន ដាក់ការគាំទ្ររបស់ខ្លួនខុស ទៅលើមតិយោបល់ផ្ទុយដោយផ្អែករបស់ចៅក្រម Downing[22] មកពីសេចក្តីសម្រេចដោយសំឡេងលើសលប់របស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស ដើម្បីច្រានចោលពាក្យសុំប្តឹងជំទាស់ចិត្តចៅក្រម និល ណុន, យ៉ា សុខន, Jean-Marc Lavergne និងចៅក្រម យូរ ឧត្តរា នៃសំណុំរឿង០០២/០២[23]។ ក្រៅពីការប្រៀបធៀបទស្សនៈរបស់ចៅក្រម Downing ជាមួយនឹងទស្សនៈរបស់ចៅក្រមសំឡេងលើសលប់[24] ខៀវ សំផន គ្រាន់តែចោទថា ក្រុមប្រឹក្សាជំនុំជម្រះ ពិសេស "មានកំហុស" ក្នុងការច្រានចោលពាក្យសុំប្តឹងជំទាស់ចិត្តចៅក្រមជំនុំជម្រះក្នុងសំណុំរឿង០០២/០២នេះ ដោយយោងទៅលើ "យុត្តិសាស្ត្រថ្មីៗរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ"[25]។ ការចោទប្រកាន់នេះមិនមានអង្គសេចក្តីទេ។

15. **សេចក្តីសម្រេចរបស់ចៅក្រម Antonetti:** "យុត្តិសាស្ត្រថ្មីៗ" ដែល ខៀវ សំផន ចង់និយាយសំដៅនោះ គឺបានពឹងផ្អែកទៅលើតែសេចក្តីសម្រេចរបស់ចៅក្រម Antonetti មួយប៉ុណ្ណោះ ដើម្បីប្តឹងជំទាស់ចិត្តចៅក្រម Meron, ចៅក្រម Agius និងចៅក្រម Liu ពីខាងអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុង

---

[21] *ផ្ទុយពី*ឯកសារ F53 សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ៤០។

[22] ឯកសារ E314/12/1 សេចក្តីសម្រេចលើសំណើសុំប្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ជ ក្នុងសំណុំរឿង០០២/០២ មតិយោបល់ផ្ទុយដោយផ្អែករបស់ចៅក្រម Rowan Downing ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥។

[23] ឯកសារ E314/12/1 សេចក្តីសម្រេចលើសំណើសុំប្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ជ ក្នុងសំណុំរឿង០០២/០២ កថាខណ្ឌ៥។

[24] ឯកសារ F53 សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ២៥-២៧។

[25] ឯកសារ F53 សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ២៨។ *សូមមើលផងដែរ* ឯកសារ F53 សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ៥១-៥២។

រឿងក្ដី *Mladić* អំពីយន្ដការ (“សេចក្ដីសម្រេចរបស់ចៅក្រម Antonetti”)[26]។ សេចក្ដីសម្រេចរបស់ចៅក្រម Antonetti នៅតែគ្មានផ្លាស់ប្ដូរ ខណៈដែលសំណើរបស់ការិយាល័យអយ្យការសុំឱ្យពិនិត្យ*សាជាថ្មី* ត្រូវបានបដិសេធដោយឈរលើមូលដ្ឋានយុត្តាធិការក៏ដោយ[27] ប៉ុន្តែវាបានងាកចេញយ៉ាងឆ្ងាយពីបទដ្ឋានដែលត្រូវបានដោះស្រាយចប់សព្វគ្រប់ពាក់ព័ន្ធនឹងអនាគតិរបស់តុលាការ។

16. បទដ្ឋានដែលបានបង្កើតឡើងទាំងនេះ ផ្ដល់នូវសច្ចធារណ៍នៃអនាគតិដ៏រឹងមាំមួយជូនចៅក្រមនៅតាមបណ្ដាតុលាការអន្តរជាតិនានា[28]។ ចៅក្រមបានធ្វើសម្បថដើម្បីលើកកម្ពស់ភារកិច្ចនៃអនាគតិ[29]

---

[26] ឯកសារ **F53** សំណើសុំប្ដឹងជំទាស់, កថាខណ្ឌ ២៩-៣៦។ *Mladić,* MICT-13-56-A, សេចក្ដីសម្រេចលើញត្តិរបស់មេធាវីការពារក្ដីសុំប្ដឹងជំទាស់ចៅក្រម Theodor Meron, Carmel Agius និង Liu Daqun, ចៅក្រមជាន់ខ្ពស់, ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨ (“សេចក្ដីសម្រេចរបស់ចៅក្រម Antonetti”)។

[27] អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានថ្លែងថា ការប្រើយុត្តាធិការលើបណ្ដឹងឧទ្ធរណ៍ត្រូវបានប្រើប្រាស់តែក្នុង “ករណីពិសេស” ប៉ុណ្ណោះ ហើយអយ្យការខកខានមិនបានបង្ហាញឱ្យឃើញនូវកាលៈទេសដូច្នេះទេ ដែលនឹងបង្កើតបាននូវយុត្តាធិការទៅលើបណ្ដឹងឧទ្ធរណ៍នោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនជម្រះលើអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍នេះទេ (*សូមមើល* *Mladić*, MICT-13-56-A, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អយ្យការប្រឆាំងនឹងសេចក្ដីសម្រេចរបស់ប្រធានស្ដីទី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨, កថាខណ្ឌ ១២-១៩)។

[28] *សូមមើល ជាឧទាហរណ៍ សាលដីកា* *Furundžija*, កថាខណ្ឌ ១៩៦-១៩៧។ *Šainović និងគូកន.*, IT-05-87-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ (“សាលដីកា *Šainović*”), កថាខណ្ឌ ១៨១)។ សាលដីកា *Galić*, កថាខណ្ឌ ៤១។ *Ntawukulilyayo* ICTR-05-82-A, សាលដីកាលើញត្តិស្នើសុំប្ដឹងជំទាស់ចៅក្រម, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ (“សាលដីកាលើបណ្ដឹងជំទាស់ក្នុងរឿងក្ដី *Ntawukulilyayo*”), កថាខណ្ឌ ៧។ *សាលដីកា* *Nahimana*, កថាខណ្ឌ ៤៨។ *Taylor*, SCSL-03-01-A, សាលដីកាលើញត្តិរបស់ Charles Ghankay Taylor សុំដកខ្លួនចេញមួយផ្នែកដោយស្ម័គ្រចិត្ត ឬប្ដឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២, កថាខណ្ឌ ១៩។

[29] នៅ អ.វ.ត.ក *សូមមើលឧទាហរណ៍* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្ដីពីការកាត់កាត់សេចក្ដីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ (“កិច្ចព្រមព្រៀង អ.ស.ប-រាជ្យរដ្ឋាភិបាលកម្ពុជា”) មាត្រា៣.៣ (“ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និងសុចរិត មានគុណសម្បត្តិ ដែលតម្រូវសម្រាប់តែងតាំងឱ្យបម្រើការក្នុងការិយាល័យតុលាការនៅប្រទេសរបស់ខ្លួន។ ចៅក្រមត្រូវឯករាជ្យក្នុងការ បំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ។”) ក្រមសីលធម៌ចៅក្រម បានអនុម័តដោយសម័យប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ និងត្រូវបានវិសោធនកម្មនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ មាត្រា ២.១ (“ចៅក្រមត្រូវរក្សានូវភាពមិនលម្អៀង និងត្រូវធានាពីការបង្ហាញពីភាពមិនលម្អៀងនោះក្នុងការបំពេញមុខនាទីរបស់ខ្លួន) ៧.១ (“ចៅក្រមត្រូវអនុវត្តសិទ្ធិក្នុងការបញ្ចេញមតិ និងចូលរួមក្នុងកិច្ចការសាធារណៈណាដែលសមស្របជាមួយនឹងមុខនាទីនៃការិយាល័យរបស់ខ្លួន ហើយដែលមិនជះឥទ្ធិពល ឬទំនងជាអាចជះឥទ្ធិពលដល់ឯករាជភាព និងភាពមិនលម្អៀង

ដូច្នេះដើម្បីកំណត់បានថា ចៅក្រមណាម្នាក់ពិតជាមានការលំអៀង ឬអ្នកសង្កេតការសមហេតុផលណាម្នាក់មានការយល់ដឹងគ្រប់ជ្រុងជ្រោយ ដែលនាំឱ្យគេយល់បានអំពីភាពលំអៀងដែលកើតឡើងចេញពីខាងចៅក្រមនោះ គឺទាមទារឱ្យមានលក្ខខណ្ឌតម្រូវនៃភស្តុតាងដ៏ខ្ពស់បំផុត[30]។ សំខាន់បំផុតសម្រាប់ករណីចំពោះមុខ សច្ចធារណ៍នៃអនាគតិត្រូវបានបកស្រាយស្របគ្នាដែលត្រូវសម្រេចថាចៅក្រមមិនត្រូវបានហាមឃាត់ពីការចូលរួមមានតួនាទីក្នុងករណីចាប់ពីពីរឡើងទៅ ទាក់ទងនឹងព្រឹត្តិការណ៍ដូចគ្នាជាបន្តបន្ទាប់ ឬក្នុងការដោះស្រាយលើបញ្ហាច្បាប់ ឬអង្គហេតុស្រដៀងគ្នានោះឡើយ[31]។

---

របស់តុលាការ។")។ សេចក្តីព្រៀងក្រមស្តីពីការប្រព្រឹត្តរបស់ចៅក្រមរបស់ Bangalore ឆ្នាំ២០០១ ដែលបានអនុម័តដោយក្រុមតុលាការស្តីពីការពង្រឹងសុច្ចរិតភាពរបស់តុលាការ ដូចដែលត្រូវបានកែប្រែនៅកិច្ចប្រជុំតុមូលរបស់ប្រធានតុលាការនៅក្នុងទីក្រុងឡាអេ ចុះថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០០២ មាត្រា ២.២ ("ចៅក្រមត្រូវធានាថាទង្វើរបស់គាត់ ទាំងក្នុងនិងក្រៅតុលាការរក្សា និងលើកម្ពស់ទំនុកចិត្តសាធារណៈ វិជ្ជាជីវៈ និងបណ្តឹងវិវាទផ្លូវច្បាប់របស់ចៅក្រម និងតុលាការ។")។ គោលការណ៍របស់ Bangalore ត្រូវបានដកស្រង់មកអនុវត្តចំពោះចៅក្រម អ.វ.ត.ក (*សូមមើល ឧទាហរណ៍* ឯកសារ Special PTC02-7 សាលដីកាលើបណ្តឹងជំទាស់របស់ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde អ.ប.ជ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Lemonde លើកទី១") កថាខណ្ឌ២៧។ ឯកសារ Special PTC02-4 សាលដីកាលើបណ្តឹងរបស់ នួន ជា សុំប្តឹងជំទាស់ចៅក្រម Marcel Lemonde អ.ប.ជ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ កថាខណ្ឌ១៧)។ *សូមមើលផងដែរ* គោលការណ៍មូលដ្ឋានរបស់ អ.ស.ប ស្តីពីឯករាជភាពរបស់តុលាការ ត្រូវបានអនុម័តដោយសន្និបាទអង្គការសហប្រជាជាតិលើកទីប្រាំពីរស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្ម និងការប្រព្រឹត្តលើជនល្មើស ត្រូវបានអនុម័តដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាទ អ.ស.ប លេខ Res. 40/32 ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និងលេខ 40/146 ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥ កថាខណ្ឌ២, ៦, ៨។

[30] *សូមមើល ជាឧទាហរណ៍* ឯកសារ **C11/29** បណ្តឹងជំទាស់ចៅក្រម នៃ ថុល, កថាខណ្ឌ ១៩។ **E55/4** សំណុំរឿង០០២/០១ សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើបណ្តឹងជំទាស់ កថាខណ្ឌ១២។ *Delalić* នឹងគូកន., IT-96-21-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ ("សាលដីកា *Čelebići*"), កថាខណ្ឌ ៧០៧។ សាលដីកា *Šainović*, កថាខណ្ឌ ១៨១។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ *Ntawukulilyayo*, កថាខណ្ឌ ៧។ *Renzaho*, ICTR-97-31-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ ("សាលដីកា *Renzaho*") កថាខណ្ឌ ២៣។ សាលដីកា *Nahimana*, កថាខណ្ឌ ៤៨-៥០។ សាលដីកា *Galić* កថាខណ្ឌ ៤១, ៤៤។

[31] *សូមមើល ជាឧទាហរណ៍* **E55/4** សំណុំរឿង០០២/០១ សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើបណ្តឹងជំទាស់ កថាខណ្ឌ១៥។ *Mladić*, IT-09-92-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ស្វែងរកការប្តឹងជំទាស់ចៅក្រមដ៏មានកិត្តិយស Alphons Orie និងចៅក្រម Christoph Flügge, ដែលជាប្រធានតុលាការ, ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ("សេចក្តីសម្រេចអំពីចៅក្រម Judges Orie និង Flügge ក្នុងរឿងក្តី *Mladić*"), ទំព័រ ៣, កំណត់សម្គាល់ជើងទំព័រ ១៤ *លើកយោង Stanišić និង Župljanin*, IT-08-91-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦, កថាខណ្ឌ ៤៤។ *Šešelj*, IT-03-67-R77.3, សេចក្តីសម្រេចលើញត្តិធ្វើឡើងដោយសាស្ត្រាចារ្យ Vojislav Šešelj សុំប្តឹងជំទាស់ចៅក្រម O-Gon Kwon និង Kevin

17. ក្រៅពីករណីយុត្តិសាស្ត្រតុលាការមួយផ្នែកធំដែលផ្ទុយនឹងសេចក្តីសម្រេចរបស់ចៅក្រម Antonetti នោះ ព្រឹត្តិការណ៍ជាបន្តបន្ទាប់មួយចំនួនទៀតក្នុងរឿងក្តី ជំទាស់បន្ថែមទៀតទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា សេចក្តីសម្រេចរបស់ចៅក្រម Antonetti ជាករណីយុត្តិសាស្ត្រដ៏រឹងមាំ[32]។ ខណ: ខៀវ សំផន កត់សំគាល់ថា ចៅក្រម Meron "បានដកខ្លួនចេញដោយស្ម័គ្រចិត្តពីរឿងក្តី *Karadžić*" ដើម្បីឆ្លើយតបទៅនឹងញត្តិស្នើសុំមួយដែលប្រឆាំងនឹងគាត់ដែលផ្អែកលើសេចក្តីសម្រេចរបស់ចៅក្រម Antonetti ក៏ដោយ[33] ក៏ចៅក្រម Meron បានបញ្ជាក់យ៉ាងច្បាស់ថា គាត់បានជ្រើសរើសដើម្បីដើរចេញ គឺដើម្បីធានាថា កិច្ចដំណើរការនីតិវិធីប្តឹងជំទាស់ មិនរារាំងដល់ដំណើរការរបស់រឿងក្តី[34] គឺមិនមែនដោយសារគាត់បានយល់ព្រមជាមួយនឹងគោលការណ៍នានាដែលសេចក្តីសម្រេចរបស់ចៅក្រម Antonetti អនុម័តនោះទេ។ លើសពីនេះ ចៅក្រម Meron បានធ្វើការសង្កេតចំៗចំណុចថា សេចក្តីសម្រេចរបស់ចៅក្រម Antonetti "ផ្ទុយគ្នាយ៉ាងស្រឡះទៅនឹងយុត្តិសាស្ត្រដែលបានបង្កើត" និងជា "គ្រោះថ្នាក់ចំពោះផលប្រយោជន៍នៃយុត្តិធម៌" ដោយបានបញ្ជាក់ថា គាត់គួរតែបានបន្តទៅជំនុំជម្រះរឿងក្តីដោយចិត្តគំនិតមិនលំអៀង[35]។ ដូច្នេះ ទោះបីយើងត្រូវទុកយុត្តិសាស្ត្រដែលត្រូវបានបង្កើតឡើងយ៉ាងល្អមួយអន្លើរសម្រាប់គោលបំណងនៃអំណះអំណាងក៏ដោយ ក៏សេចក្តីសម្រេចរបស់ចៅក្រម Antonetti មិនបានតំណាងឲ្យអ្វីទាំងអស់ក្រៅតែអំពីទស្សនៈរបស់ចៅក្រមតែម្នាក់គត់ដែលត្រូវបានធ្វើឲ្យមានតុល្យភាព តាមរយៈទស្សនៈប្រឆាំងដោយផ្ទាល់របស់ចៅក្រមម្នាក់ផ្សេងទៀត[36]។ ការនេះទោះតាមមធ្យោបាយណាក៏ដោយ មិនមែនជាយុត្តិសាស្ត្រដ៏ខ្លាំងក្លាឡើយ[37]។

---

Parker, អង្គជំនុំជម្រះពិសេស, ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០, កថាខណ្ឌ ២៨ *ដកស្រង់ Brđanin និង Talić*, IT-99-36-T, សេចក្តីសម្រេចលើពាក្យសុំ ធ្វើឡើងដោយ Momir Talić សុំប្តឹងជំទាស់ចិត្ត និងដកចៅក្រមមួយរូប, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០, កថាខណ្ឌ ១៨។ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្ត *Ntawukulilyayo*, កថាខណ្ឌ ១២, ១៣។ សាលដីកា *Nahimana*, កថាខណ្ឌ ៧៨។ សាលដីកា *Renzaho* កថាខណ្ឌ ២២។ *Karera*, ICTR-01-74-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៩, កថាខណ្ឌ ៣៧៨។ សាលដីកា *Akayesu*, កថាខណ្ឌ ២៦៩។

32 ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត, កថាខណ្ឌ ៤០។

33 ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត, កថាខណ្ឌ ៣៦។

34 *Karadžić*, MICT-13-55-A, សេចក្តីសម្រេច ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ (សេចក្តីសម្រេចដកខ្លួនរបស់ Meron)។

35 សេចក្តីសម្រេចដកខ្លួនរបស់ Meron), ទំព័រទី ១-២។ *សូមមើល* ជាពិសេស ការយោងរបស់គាត់អំពីយុត្តិសាស្ត្រដែលបានកំណត់ដែលគាត់គិតថាផ្ទុយនឹងសេចក្តីសម្រេចរបស់ចៅក្រម Antonetti (សេចក្តីសម្រេចដកខ្លួនរបស់ Meron, កំណត់សម្គាល់ជើងទំព័រ ៦។

36 សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តជាបន្តបន្ទាប់ស្តីពីយុត្តិធម៌ មិនបានពិចារណាលើបញ្ហានៃការធ្វើបុរេវិនិច្ឆ័យទេ ទោះបីជាយ៉ាងហោចណាស់មានចៅក្រមសាលាឧទ្ធរណ៍ប្រាំបីរូប បានតម្កល់អភិក្រមដែលបានកំណត់ទាក់ទងនឹងសច្ចធារណ៍នៃអនាគតិ

18. **យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប:** ការព្យាយាមរបស់ ខៀវ សំផន ក្នុងការគាំទ្រទៅលើទស្សនៈរបស់ចៅក្រម Antonetti និងចៅក្រម Downing ដោយប្រើយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប មិនអាចទប់ទល់មិនឱ្យធ្វើការពិនិត្យពិច័យបានឡើយ[38]។ ទីមួយ គាត់ព្យាយាមគេចវេះពីភាសាធម្មតាក្នុងរឿងក្តី *Poppe ទល់នឹង ហូឡង់* "*Poppe*" ដែលបានពិនិត្យអំពីថាតើចៅក្រមពីររូបដែលពីមុនបានផ្តន្ទាទោសសហជនជាប់ចោទរបស់ម្ចាស់បណ្តឹងបានធ្វើការសម្រេចនៅក្នុងរឿងក្តីទាំងនោះ ថាតើការជាប់ពាក់ព័ន្ធរបស់ម្ចាស់បណ្តឹងបំពេញ "លក្ខណវិនិច្ឆ័យពាក់ព័ន្ធ*ទាំងអស់* ដែលចាំបាច់ដើម្បីបង្កើតបានជាបទល្មើសព្រហ្មទណ្ឌណាមួយ" ដែរឬអត់[39]។ គាត់ធ្វើដូច្នេះតាមរយៈការប្រកាសថា ចៅក្រម Antonetti និងចៅក្រម Downing "បានថ្លែងយ៉ាងត្រឹមត្រូវថា" សេចក្តីយោងក្នុងសាលក្រមដែលយោងដល់គ្រប់ "ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌទាំងអស់" គឺគ្រាន់តែជា "ការបង្ហាញ" ប៉ុណ្ណោះ មិនមែនជាតេស្តិ៍សាកល្បងផ្នែកសម្រេចសេចក្តីសម្រាប់ការធ្វើបុរេវិនិច្ឆ័យឡើយ[40]។ ក្នុងការគាំទ្រ គាត់អះអាងទាំងខុសថា "ករណីផ្សេងទៀត" នៅតុលាការសិទ្ធិមនុស្សអឺរ៉ុបបង្ហាញឱ្យឃើញថា ចៅក្រមមិនចាំបាច់ធ្វើការប្រកាស "គ្រប់ធាតុផ្សំនីមួយៗ" នៃបទល្មើសសម្រាប់ការធ្វើបុរេវិនិច្ឆ័យដែលនឹងត្រូវកើតមាននោះទេ[41]។ តាមពិតនោះ ការធ្វើតេស្តិ៍ "ធាតុផ្សំទាំងអស់"

---

តុលាការយ៉ាងខ្ពស់ក៏ដោយ។ *សូមមើល Karadžić*, MICT-13-55-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩, កថាខណ្ឌ ៥៣៥, ៣៥៥ (អង្គជំនុំជម្រះមានសមាសភាពចៅក្រម Joensen, ចៅក្រម Sekule, ចៅក្រម de Prada, ចៅក្រម Gatti, និងចៅក្រម Rosa)។ *Karadžić*, MICT-13-55-A, សេចក្តីសម្រេចលើញត្តិសុំប្តឹងជិតចិត្ត និងញត្តិតវ៉ាលើបញ្ហាយុត្តាធិការ, អង្គចៅក្រមពិសេស, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩, កំណត់សម្គាល់ជើងទំព័រ ៤០ (អង្គចៅក្រមពិសេស សមាសភាពរួមមាន ចៅក្រម Hall, ចៅក្រម Masanche, និងចៅក្រម Park)។

[37] នៅពេលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Taylor* និង *Šainović* ប្រឈមមុខនឹងច្បាប់ផ្ទុយស្តីពីថាតើ តម្រូវឱ្យមានការណែនាំជាក់លាក់ដែរឬអត់ដើម្បីកំណត់អំពី*អំពើពិរុទ្ធ* នៃការផ្តល់ទំនុកបម្រុងនោះ ចៅក្រមបានធ្វើការវាយតម្លៃយ៉ាងទូលំទូលាយទៅលើយុត្តិសាស្ត្រ*ចំពោះកិច្ច* ព្រមទាំងច្បាប់ទម្លាប់អន្តរជាតិ ហើយជាចុងក្រោយបានទាត់ចោលទស្សនៈរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Perišić* ដែលមានលក្ខណៈផ្ទុយគ្នាដោយផ្ទាល់ និងយ៉ាងជាក់ស្តែងជាមួយនឹងយុត្តិសាស្ត្រជាអាទិភាព។ *សូមមើល Taylor*, SCSL-03-01-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣, កថាខណ្ឌ ៤៦៦-៤៨១, ៤៨៦។ សាលដីកា *Šainović*, កថាខណ្ឌ ១៦១៧-១៦៥១។

[38] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត, កថាខណ្ឌ ៣៧-៣៩។

[39] *រឿងក្តី Poppe ទល់នឹងប្រទេសហូឡង់* លេខ 32271/04, សាលក្រម ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ ("សាលក្រម *Poppe*") កថាខណ្ឌ ១៩-២០, ២៨ (សង្កត់ន័យដើម)។

[40] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត, កថាខណ្ឌ ៣៧។

[41] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត, កថាខណ្ឌ ៣៧។

ត្រូវបានចាត់ទុកថាជាផ្នែកដែលត្រូវានសម្រេចរួចហើយក្នុងឱកាសជាច្រើន[42] ហើយតុលាការសិទ្ធិមនុស្សអឺរ៉ុប ដូចគ្នានឹង អ.វ.ត.ក ដែរ បានបង្ហាញភាពខុសគ្នានៃ "សំណុំរឿងផ្សេងៗទៀត" ពីរ ឬ បី ដែល ខៀវ សំផន បានពឹងផ្អែកលើ[43]។ ការណ៍នេះ ទំនងជាមូលហេតុ ដែល ខៀវ សំផន មិនបាន

---

[42] ខៀវ សំផន បានថ្លែងដោយនាំឲ្យយល់ខុសថា សាលក្រម "នៅពេលនោះ" ត្រូវបានបកស្រាយដើម្បីតម្រូវឲ្យចៅក្រមដែលរងនូវការចោទប្រកាន់ បានសំរេចនូវលក្ខណៈវិនិច្ឆ័យចាំបាច់ទាំងអស់ដើម្បីបង្កើតនូវបទល្មើសឧក្រិដ្ឋមួយ (ឯកសារ **F53** សំណើសុំប្តឹងជំទាស់ កថាខណ្ឌ ៣៧)។ *ក៏ប៉ុន្តែ សូមមើល ឧទា. សំណុំរឿងរបស់* Schwarzenberger *ទល់នឹង ប្រទេស អាល្លឺម៉ង់* លេខ ៧៥៧៣៧/០១ សាលក្រម ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ ("សាលក្រមរបស់ *Schwarzenberger*") កថាខណ្ឌ ៤៣។ *សំណុំរឿងរបស់* Miminoshvili *ទល់នឹង ប្រទេសរុស្សី* លេខ ២០១៩៧/០៣ សាលក្រម ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ("សាលក្រមរបស់ *Miminoshvili*") កថាខណ្ឌ ១១៨។ ឯកសារ **E55/4** សំណុំរឿង០០២/០១ សេចក្តី សម្រេចរបស់ អ.ជ.ស.ដ លើបណ្តឹងជំទាស់ កថាខណ្ឌ ២១។ ឯកសារ **E314/12/1** សំណុំរឿង០០២/០២ សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើបណ្តឹងជំទាស់ កថាខណ្ឌ ៣៨-៤៤, ៩៤ (ដោយបានកត់សម្គាល់ថា សាលក្រមសំណុំរឿង០០២/០១ មិនបានវាយតម្លៃ ឬ កំណត់ថា*បំណងឧក្រិដ្ឋ* របស់ ខៀវ សំផន ទាក់ទងនឹងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង០០២/០២ ឬក៏មិនបានធ្វើការរកឲ្យឃើញថាតើសហឧក្រិដ្ឋកម្មរួមដែលបណ្តាលមកពី និង/ឬ ចូលរួមចំណែកនៅក្នុងឧក្រិដ្ឋកម្មនៃសំណុំរឿង០០២/០២)។ សេចក្តីសម្រេច *Mladić* ស្តីពីចៅក្រម Orie និង Flügge ឧបសម្ព័ន្ធ ខ៖ អនុស្សរណៈផ្ទៃក្នុងពីចៅក្រមជំនុំជម្រះ Alphonse Orie ជូនទៅលោកប្រធាន Theodor Meron ក្រោមចំណងជើងថា "របាយការណ៍ អនុលោមតាមវិធាន ១៥(ខ)" ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ៣០, ៣៦-៣៧។ សេចក្តីសម្រេច *Mladić* ស្តីពីចៅក្រម Orie និង Flügge ឧបសម្ព័ន្ធ ក៖ អនុស្សរណៈ ផ្ទៃក្នុងពីចៅក្រម Christoph Flügge ជូនទៅចៅក្រមជំនុំជម្រះ Alphons Orie ក្រោមចំណងជើងថា "ការពិភាក្សាស្តីពីញត្តិសុំប្តឹងជំទាស់ អនុលោមតាមវិធាន ១៥(ខ)" ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ១៨-១៩, ៦-៣៨។ សេចក្តីសម្រេច *Mladić* ស្តីពីចៅក្រម Orie និង Flügge ឧបសម្ព័ន្ធ ខ៖ អនុស្សរណៈផ្ទៃក្នុងពីចៅក្រមជំនុំជម្រះ Alphons Orie ជូនទៅលោក ប្រធាន Theodor Meron ក្រោមចំណងជើងថា "របាយការណ៍ អនុលោមតាមវិធាន ១៥(ខ)" ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ២៩។

[43] *សូមមើល* ឯកសារ **F53** សំណើសុំប្តឹងជំទាស់ កំណត់សម្គាល់ជើងទំព័រលេខ ៦១ បានយោងទៅដល់សេចក្តីសម្រេចរបស់ Antonetti, កំណត់សម្គាល់ជើងទំព័រលេខ ៥៥ ដែលម្តងនេះបានយោងទៅដល់សំណុំរឿងរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ចំនួនពីរ៖ *សំណុំរឿង របស់ Rojas Morales ទល់នឹង ប្រទេសអ៊ីតាលី*, លេខ ៣៩៦៧៦/៩៨ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០០០ ("សាលក្រម របស់ *Rojas Morales*") និង *សំណុំរឿងរបស់* Ferrantelli *និង* Santangelo *ទល់និង ប្រទេសអ៊ីតាលី,* លេខ ១៩៨៧៤/៩២ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៦ ("*Ferrantelli និង Santangelo*")។ សំណុំរឿងទាំងពីរនេះត្រូវបានដឹងនូវភាពប្លែកគ្នា ដដែលៗ។ *សូមមើល ឧទា. សាលក្រមរបស់* Poppe កថាខណ្ឌ ២៨។ សាលក្រមរបស់ *Schwarzenberger* កថាខណ្ឌ ៤៤-៤៥។ សាលក្រមរបស់ *Miminoshvili* កថាខណ្ឌ ១១៥-១១៦។ ឯកសារ **E55/4** សំណុំរឿង០០២/០១ សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើបណ្តឹងជំទាស់ កំណត់សម្គាល់ជើងទំព័រលេខ ៤៥។ ឯកសារ **E314/12/1** សំណុំរឿង០០២/០២ សេចក្តីសម្រេច របស់ អ.ជ.ស.ដ លើបណ្តឹងជំទាស់ កថាខណ្ឌ ៤៤។

កំណាត់អត្ថសញ្ញាណរឿងក្តីទាំងពីរនោះឲ្យចំឈ្មោះ និងគ្រាន់តែយោងទៅកាន់ពួកវាដោយមិនចំពោះប៉ុណ្ណោះ[44]។

19. នៅក្នុងរឿងក្តី *Miminoshvili ទល់នឹង ប្រទេសរុស្ស៊ី* តុលាការបានសន្និដ្ឋានដោយបង្កប់ន័យថា "សំណុំរឿងផ្សេងៗទៀត" ទាំងពីរនេះ (*Ferrantelli និង Santangelo* និង *Rojas Morales*) លែងផ្ទុះបញ្ហាំងពីជំហរស្តីពីសច្ចធារណ៍នៃអនាគតិរបស់តុលាការទៀតហើយ[45]។ តុលាការបានសម្រេចផ្ទុយពីសំណុំរឿងចាស់ៗ នៅក្នុងរឿងក្តី *Poppe* និង *Schwarzenberger ទល់នឹង ប្រទេសអាល្លឺម៉ង់* ដែលរឿងក្តីទាំងពីរនេះបានរកឃើញថា នៅក្នុងកាលៈទេសៈស្រដៀងគ្នា ការភ័យខ្លាចរបស់អ្នកដាក់ពាក្យប្តឹងអំពីភាពលំអៀងរបស់ចៅក្រម គឺគ្មានមូលដ្ឋានទេ[46]។ តុលាការនេះក៏បានលើកឡើងពីគោលសំខាន់ៗនៃរឿងក្តី *Thomann ទល់និង ប្រទេសស្វីស* ដែលបានសម្រេចថា ចៅក្រមដែលបានកាត់ជនជាប់ចោទម្នាក់ឲ្យជាប់ទោស *ដោយកំបាំងមុខ* អាចនឹងវិនិច្ឆ័យសេចក្តីក្នុងសវនាការម្តងទៀតនៃវត្តមានរបស់ជនជាប់ចោទរូបនោះ ដោយមិនដែកវែកញែកពីភាពសង្ស័យស្តីពីអនាគតិផ្ទាល់ខ្លួនរបស់ពួកគាត់នោះឡើយ ពីព្រោះថាពួកគាត់នឹងធ្វើការពិចារណាថ្មីមួយ នៅក្នុងសំណុំរឿងទាំងមូល[47]។ ស្រដៀងគ្នានេះដែរ តុលាការ *Miminoshvili* បានសម្រេចថាវាមិនមានភស្តុតាងដែលថា

---

[44] *សូមមើល* កំណត់សម្គាល់ជើងទំព័រលេខ ៤៣ *យោងខាងលើ*។

[45] សាលក្រមរបស់ *Miminoshvili* កថាខណ្ឌ ១១៥-១១៦ ("នៅក្នុងសំណុំរឿងមួយចំនួន តុលាការសង្កេតឃើញថាខ្លួនបានឈានទៅដល់សេចក្តីសន្និដ្ឋានថា ការចូលរួមចំណែកនៃចៅក្រមដដែលៗនៅក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងពីរ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដូចៗគ្នា អាចលើកឡើងនូវបញ្ហាដែលអាចជជែកគ្នា នៅក្រោមមាត្រា ៦ § ១ នៃអនុសញ្ញា")។ ដូច្នោះ តុលាការរៀបរាប់ពីសាលក្រមរបស់ *Ferrantelli និង Santangelo* និង *Rojas Morales* មុននឹងបន្តថា៖"**យ៉ាងណាក៏ដោយ នៅក្នុងរឿងក្តីថ្មីៗនេះ តុលាការបានរកឃើញថា ភាពភ័យខ្លាចរបស់អ្នកដាក់ពាក្យសុំ អំពីភាពលំអៀងរបស់ចៅក្រមនៅក្នុងកាលៈទេសៈស្រដៀងគ្នានេះ មិនត្រូវបានរកឃើញទេ**" ដោយយោងទៅដល់សាលក្រមរបស់ *Schwarzenberger* និង សាលក្រមរបស់ *Poppe*) (ការសង្កត់ន័យដោយអក្សរដិតធំ ត្រូវបានបន្ថែម)។ *សូមមើល ផងដែរ* ឯកសារ **E55/4** សំណុំរឿង០០២/០១ សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើបណ្តឹងដិតចិត្ត កំណត់សម្គាល់ជើងទំព័រលេខ ៤៥។

[46] សាលក្រមរបស់ *Miminoshvili* កថាខណ្ឌ ១១៦។

[47] សាលក្រមរបស់ *Miminoshvili* កថាខណ្ឌ ១១៦ ដោយលើកឡើងពីសំណុំរឿងរបស់ *Thomann ទល់នឹង ប្រទេសស្វីស* លេខ ១៧៦០២/៩១ សាលក្រម ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៦ កថាខណ្ឌ ៣៥។ *សូមមើល ផងដែរ* សំណុំរឿងដែលរកឃើញថាចៅក្រមទទួលរ៉ាប់រងពិចារណាថ្មីមួយនៅក្នុងសំណុំរឿងដែលនៅចំពោះមុខពួកគាត់៖ សាលក្រមរបស់ *Schwarzenberger* កថាខណ្ឌ ៤៣។ *សំណុំរឿងរបស់ Khodorkovskiy និង Lebedev ទល់នឹង ប្រទេសរុស្ស៊ី* លេខ ១១០៨២/០៦ និង ១៣៧៧២/០៥ សាលក្រម ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ("សាលក្រមរបស់ *Khodorokovskiy*") កថាខណ្ឌ ៥៤៦, ៥៤៨, ៥៥៦។ សំណុំរឿងរបស់ *Ooo 'Vesti' និង Ukhov ទល់នឹង ប្រទេសរុស្ស៊ី* លេខ ២១៧២៤/០៣ សាលក្រម (អង្គសេចក្តី) ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ៨១។

សាលក្រមពីមុនប្រឆាំងនឹងមនុស្សដែលត្រូវបានចោទប្រកាន់របស់ម្ចាស់បណ្តឹង ដែលបានរៀចំសមាជិកឧក្រិដ្ឋកម្ម (បង/ប្អូនប្រុសរបស់គាត់) បានធ្វើបុរេវិនិច្ឆ័យលើពិរុទ្ធភាពរបស់ម្ចាស់បណ្តឹងនៅក្នុងកិច្ចដំណើរការនីតិវិធីជាបន្តបន្ទាប់[48]។ ដូចគ្នាទៅនឹងសំណុំរឿងនេះដែរ តុលាការបានបញ្ជាក់ថា ចៅក្រមដែលកាត់សេចក្តីនៅក្នុងសំណុំរឿងទាំងពីរ គឺជាចៅក្រមដែលប្រកបទៅដោយវិជ្ជាជីវៈ ដែលហេតុដូច្នេះហើយ គឺជា "*មនុស្សដំបូងគេម្នាក់* ដែលបានត្រៀមរៀបចំ ដើម្បីផ្តាច់ខ្លួនគាត់ចេញពីបទពិសោធន៍ពីមុននៅក្នុង [សវនាការផ្សេងៗ] ជាឧទាហរណ៍ ចៅក្រម ធម្មតាដែលមិនមានវិជ្ជាជីវៈ ឬ គណៈវិនិច្ឆ័យម្នាក់"[49]។

20. សំណុំរឿង "មួយផ្សេងទៀត" របស់តុលាការសិទ្ធិមនុស្សអឺរ៉ុបដែល ខៀវ សំផន *ពិតជាបាន* លើកឡើង នៅក្នុងសំណើសុំប្តឹងជិតចិត្តរបស់គាត់នេះ ក៏ខកខានមិនបានបកស្រាយបង្ហាញពីយុត្តិសាស្ត្រដ៏ "ខ្លាំង" ស្រដៀងគ្នាដែរ[50]។ នៅក្នុងរឿងក្តីរបស់ *Mancel និង Branquart* តុលាការបានរកឃើញថា ការលេចឡើងពីភាពលំអៀងត្រូវបានបង្ហាញ នៅពេលដែលចៅក្រមប្រាំពីររូប ក្នុងចំណោមប្រាំបួនរូបនៃសាលាវិនិច្ឆ័យ ដែលបានកំណត់លក្ខណៈធាតុផ្សំបង្កើតឡើងនូវបទល្មើសមួយ ត្រូវបានស្នើសុំជាថ្មីម្តងទៀតឲ្យពិនិត្យមើលពីបញ្ហាដដែល ចំពោះបទល្មើសដដែល នៅក្នុងរឿងក្តីដដែល[51]។ ច្បាស់ណាស់ថា រឿងក្តីរបស់ *Mancel និង Branquart* បានបង្ហាញពីកម្រងតែមួយនៃកាលៈទេសៈ ហើយវាជាការដែលគួរឲ្យកត់សម្គាល់ថា ខៀវ សំផន មិនបានចង្អុលបង្ហាញទៅដល់យុត្តិសាស្ត្រ បន្ត

---

[48] សាលក្រមរបស់ *Miminoshvili* កថាខណ្ឌ ១១៧-១១៩។ *សូមមើល ផងដែរ* សាលក្រមរបស់ *Khodorokovskiy* កថាខណ្ឌ ៥៤៦-៥៥៦។

[49] សាលក្រមរបស់ *Miminoshvili* កថាខណ្ឌ ១២០។ *សូមមើល ផងដែរ* សាលក្រមរបស់ *Khodorokovskiy* កថាខណ្ឌ ៥៥៥។ *S. Milošević* សំណុំរឿងលេខ IT-99-37-AR73, IT-01-50-AR73, IT-01-51-AR73, មូលហេតុចំពោះសេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់អយ្យការ ពីការបដិសេធទៅដីកាសម្រេចរួម អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០១ កថាខណ្ឌ ២៩ ("ប្រសិនបើភស្តុតាងត្រូវបានទទួលនៅក្នុងសវនាការនៃប្រទេសកូសូវ៉ូ ដែលនឹងត្រូវជាបុរេវិនិច្ឆ័យចំពោះជនជាប់ចោទ នៅក្នុងសវនាការនៃប្រទេសក្រូអាស៊ី និងប្រទេសបូស្នី នោះពួកសមាជិកនៃអង្គជំនុំជម្រះសាលាដំបូង ដែលជាពួកចៅក្រមដែលប្រកបទៅដោយវិជ្ជាជីវៈទាំងនោះ នឹងមានលទ្ធភាពអាចបដិសេធភ័ស្តុតាងបុរេវិនិច្ឆ័យទាំងនោះចេញពីគំនិតរបស់ពួកគេ កាលណាពួកគេបានឈានទៅដល់ការកំណត់ពីបញ្ហានានានៅក្នុងសវនាការ នៅក្នុងប្រទេសក្រូអាស៊ី និងប្រទេសបូស្នី")។

[50] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ ៣៨-៣៩ (ដោយបានពិភាក្សាពី *សំណុំរឿងរបស់ Mancel និង Branquart ទល់នឹង ប្រទេសបារាំង* លេខ ២២៣៤៩/០៦ សាលក្រម ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០ ("*Mancel និង Branquart*") កថាខណ្ឌ ៤០ (ដោយលើកឡើងចោទប្រកាន់ពីយុត្តិសាស្ត្រដ៏ "ខ្លាំង" របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប))។

[51] *Mancel និង Branquart* កថាខណ្ឌ ២១-២២, ២៧-២៨, ៣៩។

បន្ទាប់ណាមួយដែលដើរតាមរឿងក្តីរបស់ *Mancel និង Branquart* បើទុកណាជាការពិត វាត្រូវបានសម្រេចនៅក្នុងឆ្នាំ២០១០[52]។ នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ រឿងក្តីនៅក្នុងបញ្ហានេះ គឺអាចសង្កេតឃើញផ្សេងគ្នាពីរឿងក្តីរបស់ *Mancel និង Branquart*។ នៅទីនេះ ចៅក្រមនៃ អ.ជ.ត.ក ដែលរងការជំទាស់ទាំងនេះ ត្រូវតែវាយតម្លៃលើការរកឃើញខាងអង្គហេតុ និងអង្គច្បាប់ថ្មីៗដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៃសំណុំរឿង០០២/០២ ដែលទាក់ទងទៅនឹងឧក្រិដ្ឋកម្មខុសៗគ្នា ទីតាំងឧក្រិដ្ឋកម្មខុសៗគ្នា និងភស្តុតាងថ្មីៗមួយចំនួនធំ ដែលទាំងអស់នេះមិនត្រូវបានពិចារណានៅក្នុងសំណុំរឿង០០២/០១ នោះទេ។ ពីផ្នែក **ខ** នឹងពិភាក្សាពីបញ្ហាទាំងអស់នេះជាលម្អិតបន្ថែមទៀតខាងក្រោម។

21. ចំពោះហេតុផលទាំងអស់ខាងលើនេះ ខៀវ សំផន បានបំផ្លើសពីកម្លាំងនៃច្បាប់យុត្តិសាស្ត្រ ដែលគាត់បានសម្អាងលើ ហើយគាត់ខកខានមិនបានបកស្រាយបង្ហាញពីការអនុវត្តច្បាប់នេះបង្កើត "មូលហេតុរឹងមាំ" ដែលចាំបាច់សម្រាប់ការដកហូតសិទ្ធិរបស់ចៅក្រមដែលរងការប្តឹងជំទាស់ទាំងនោះឡើយ[53]។

## ខ. ការជំទាស់របស់ ខៀវ សំផន ទាក់ទងទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធី សិទ្ធិប្តឹងសាទុក្ខរបស់គាត់ និងសេចក្តីសន្និដ្ឋានជាន់គ្នា ខកខានមិនបានជម្នះលើសច្ចធារណ៍នៃអនាគតិរបស់តុលាការទេ

### *i. ការជំទាស់ទាក់ទងទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២*

22. អំណះអំណាងរបស់ ខៀវ សំផន ដែលថាចរិតលក្ខណៈមិនធ្លាប់មានពីមុននៃការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ បានបំពានសិទ្ធិរបស់គាត់ក្នុងទទួលបាននូវភាពប្រាកដប្រជាតាមផ្លូវតុលាការ និងបានគំរាមកំហែងដល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌នោះ[54] ត្រូវបានលើកឡើងម្តងហើយម្តងទៀត និងបានឆ្លើយតបយ៉ាងច្បាស់លាស់រួចហើយ[55]។ អ្វីដែលគួរឲ្យកត់

[52] ឯកសារ F53 សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ ៣៨-៣៩។

[53] ផ្ទុយពី ឯកសារ F53 សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ ២៤, ៤០។

[54] ឯកសារ F53 សំណើសុំប្តឹងជំទាស់ចិត្ត, កថាខណ្ឌ ៤២-៤៦។

[55] *សូមមើល ជាឧទាហរណ៍* ឯកសារ E301/5/5 សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីភាពចាំបាច់ក្នុងការ រង់ចាំសាលក្រមស្ថាពរនៃសំណុំរឿង០០២/០១ មុននឹងចាប់ផ្តើមសំណុំរឿង០០២/០២ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤ ដែលបាន បដិសេធដោយឯកសារ E301/5/5/1 សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្តើមសវនាការលើ សំណុំរឿង០០២/០២ រហូលដល់មានសាលក្រមស្ថាពរលើសំណុំរឿង០០២/០១ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ១២ (ដោយកត់សម្គាល់ថា ការអះអាងរបស់ ខៀវ សំផន ដែលភាពលំអៀងនឹងត្រូវបានកើត

សម្គាល់ ក្នុងការឆ្លើយតបទៅនឹងអំណះអំណាងដូចគ្នានេះ អជតក បានពិចារណាអំពីថាតើការបំបែកកិច្ចដំណើរការសំណុំរឿង០០២ បន្ថែមទៀត បានបង្កឲ្យមាន "បុរេវិនិច្ឆ័យពិតប្រាកដ និងមិនត្រឹមតែធ្វើឲ្យមានការធុញទ្រាន់ប៉ុណ្ណោះទេ" ហើយបានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់ "ភាពប្រាកដប្រជាផ្លូវច្បាប់ចាំបាច់ ទាក់ទងនឹងស្ថានភាពនៃបទចោទដែលនៅសេសសល់ និងផលវិបាកផ្នែកនីតិវិធីបណ្តាលមកពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម"[56]។ បន្ទាប់មក អជតក បានផ្តល់ការបំភ្លឺរបស់ខ្លួនផ្ទាល់ដើម្បីជាឧបាស្រ័យចំពោះភាពច្របូកច្របល់ណាមួយ[57]។ ជាជាងបង្ហាញនូវភាពលំអៀងពិតប្រាកដ ឬការលេចឡើងនៃភាពលំអៀងនេះបានបង្ហាញនូវឆន្ទៈរបស់ចៅក្រមដែលរងការជំទាស់ ដើម្បីលើកស្ទួយដល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ ខៀវ សំផន។

23. អនុសាសន៍របស់ អជតក ជូនចំពោះអង្គជំនុំជម្រះសាលាដំបូងដើម្បីបង្កើតអង្គចៅក្រមទីពីរ បង្ហាញឲ្យឃើញបន្ថែមទៀត អំពីកិច្ចខិតខំប្រឹងប្រែងរបស់ចៅក្រមដែលរងការជំទាស់ ក្នុងការការពារសិទ្ធិរបស់ ខៀវ សំផន[58]។ ទោះជាយ៉ាងណា ខៀវ សំផន ខកខានមិនបានផ្តល់បរិបទពេញលេញ និងមូលហេតុចំបងដែលអនុសាសន៍បានផ្តល់ឲ្យនោះទេ។ ក្នុងពេលនៃការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ កំពុងតែដំណើរការ គូភាគី អង្គជំនុំជម្រះសាលាដំបូង និង អជតក មានការព្រួយ

---

ឡើងពីការមិនដឹងថាអង្គជំនុំជម្រះសាលាដំបូងនឹងលើកឡើងពីលក្ខខណ្ឌតម្រូវរួមចំពោះ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, សហកម្មឧក្រិដ្ឋកម្មរួម យ៉ាងដូចម្តេច និងវិសាលភាពនៃសំណុំរឿង០០២/០១ និងថាមិនមានភាពលំអៀងដោយឡែកត្រូវបណ្តាលឲ្យមានឡើងនោះទេ ដោយសារតែគ្រប់ភាគីទាំងអស់មានស្ថានភាពស្រដៀងគ្នា)។ ឯកសារ **E301/9/1/1/1** បណ្តឹងសាទុក្ខភ្លាមៗរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងលើការកំណត់វិសាលភាពនៃសំណុំរឿង០០២/០២ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៤ *សូមមើលជាពិសេស* កថាខណ្ឌ ២១-៣៥ ដែលបានលើកឡើងដោយឯកសារ **E301/9/1/1/3** សេក្តីសម្រេចលើបណ្តឹងសារទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី៣ កថាខណ្ឌ ៣៩, ៦៣-៨៦។ ឯកសារ **E314/1** សំណើរបស់ ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការ រង់ចាំសាលក្រមក្នុងសំណុំរឿង០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង០០២/០២ និងសុំឲ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ (ដោយបានគូសបញ្ជាក់ពីហានិភ័យនៃការ ជាន់លើគ្នាមួយក្នុងការរកឃើញ) ដោយបានបដិសេធ ដោយឯកសារ **E314/5** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារការចាប់ផ្តើមសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤។

[56] ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី៣, កថាខណ្ឌ ៧៤, ៨៦។

[57] ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី៣, កថាខណ្ឌ ៨៦។

[58] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត, កថាខណ្ឌ ៤៨-៥០។

បារម្ភជាខ្លាំងអំពីអាយុកាន់តែជរា និងសុខភាពកាន់តែថមថយរបស់សហជនជាប់ចោទ ក្នុងស្មារតីនៃថិរវេលាដែលត្រូវការសម្រាប់ឈានដល់ការកំណត់សម្រេចជាចុងក្រោយអំពីបទចោទ ដែលតំណាងឲ្យបទចោទសមស្របនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[59]។ ការស្លាប់របស់ អៀង សារី ដែលបានកើតឡើងនៅមុនពេលដែលសវនាការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ត្រូវបានបញ្ចប់ គ្មានអ្វីក្រៅពីបានបន្ថែមទម្ងន់ទៅលើភាពបន្ទាន់នេះតែប៉ុណ្ណោះ[60]។ ដូច្នេះ អជតក ដែលបានផ្តល់អនុសាសន៍ឲ្យមានអង្គចៅក្រមទីពីរ ជាចំបង គឺដើម្បីធ្វើឲ្យកិច្ចដំណើរការនីតិវិធីកាន់តែមានប្រសិទ្ធភាព ដោយស្នើឲ្យអង្គចៅក្រមទីពីរ អាចចាប់ផ្តើមសវនាការជំនុំជម្រះក្នុងសំណុំរឿង០០២/០២ ចំណែកអង្គចៅក្រមដើមបានសរសេរសាលក្រមសំណុំរឿង០០២/០១[61]។ អជតក ដោយបានពិចារណាយ៉ាងប្រុងប្រយ័ត្នអំពីផលប្រយោជន៍ធម្មានុរូបខុសៗគ្នា រួមទាំងបុរេវិនិច្ឆ័យសក្តានុពលចំពោះសិទ្ធិរបស់ជនជាប់ចោទសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល បន្ទុកសាក្សីសក្តានុពល និងវ័យកាន់តែជរារបស់ជនរងគ្រោះ ព្រមទាំងសិទ្ធិរបស់ពួកគេក្នុងការទទួលបានការជំនុំជម្រះមួយដែលសមរម្យ បានធ្វើការសន្និដ្ឋានថា ការធានាបាននូវយុត្តិធម៌មួយដ៏មានអត្ថន័យតាមរយៈការទទួលបានសាលក្រមកាត់ទោសពេញមួយជីវិតរបស់សហជនជាប់ចោទ គឺជាផលប្រយោជន៍ដ៏ទទូចដែល "អាចជាអាទិភាពលើកង្វល់ដទៃទៀតទាំងអស់"[62]។

---

[59] *សូមមើល ជាឧទាហរណ៍* ឯកសារ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី១, កថាខណ្ឌ ២៤, ៤៣, ៤៩, ៥១។ ឯកសារ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី២, កថាខណ្ឌ ២៥, ៤៤, ៥០-៥១។ ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី៣, កថាខណ្ឌ ៥៣-៥៥, ៦១។

[60] *សូមមើល ជាឧទាហរណ៍* ឯកសារ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី២, កថាខណ្ឌ ២៥, ៥១។

[61] ឯកសារ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី១, កថាខណ្ឌ ៥១។ ឯកសារ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី២, កថាខណ្ឌ ៧៣-៧៤។ ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី៣, កថាខណ្ឌ ៣៥, ៩០។ ឯកសារ **E284/4/7/1** ដីកាទាក់ទងនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ, អជតក, ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ("រម្លឹកថា នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា កាលៈទេសៈនានាជុំវិញការបំបែកកិច្ចដំណើរនីតិវិធីសំណុំរឿង ០០២ជាថ្មី គឺត្រូវតែបង្កើតឲ្យបាននូវអង្គចៅក្រមទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង *ដើម្បីធានាថា សំណុំរឿង ០០២/០២ អាចចាប់ផ្តើមបានក្នុងពេលឆាប់ៗតាមដែលអាចធ្វើបាន នៅក្រោយការបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១")* (សង្កត់ន័យដើម)។

[62] *សូមមើល ជាឧទាហរណ៍* ឯកសារ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី២, កថាខណ្ឌ ៣៧-៣៨, ៤៣, ៥០-៥២ ("គោលដៅរបស់អង្គជំនុំជម្រះដែលបានថ្លែងម្តងហើយម្តងទៀត ក្នុងការសម្រេចអំពី

24. ខៀវ សំផន លើកឡើងពីមតិផ្ទុយដោយផ្អែករបស់ចៅក្រម Downing ថាជាសិទ្ធិអំណាចរបស់គាត់ដើម្បីប្រកាសពីបញ្ហាអង្គច្បាប់ និង "អង្គហេតុជាន់លើគ្នាដ៏សំខាន់" ដើម្បីធ្វើជាយុត្តិកម្មលើបណ្តឹងជិតចិត្ត[63]។ ដូចដែលបានពិភាក្សាគ្នានៅខាងលើស្រាប់ ទស្សនៈរបស់ចៅក្រម Downing គឺតែ ម្នាក់ឯងជំទាស់ប្រឆាំងនឹងសេចក្តីសម្រេចភាគច្រើនដាច់ខាត[64] ហើយ ហេតុដូច្នេះហើយ ត្រូវបានផ្តល់ទម្ងន់តែបន្តិចបន្តួចតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ខៀវ សំផន មិនត្រូវបានផ្តល់នូវមូលហេតុសមហេតុសមផល ដើម្បីងាកចេញពីយុត្តិសាស្ត្រដែលបានរៀបចំយ៉ាងល្អប្រសើរ ដែលថាបានបកស្រាយយ៉ាងទៀងទាត់ពីសច្ចធារណ៍នៃអនាគតិ ដើម្បីដាក់ឱ្យចៅក្រមដែលមិនបានហាមឃាត់ពីការវិនិច្ឆ័យលើសំណុំរឿងមួយ ដោយគ្រាន់តែដោយសារគាត់បានជំនុំជម្រះសំណុំរឿងមួយផ្សេងទៀត ដែលទាក់ទងទៅនឹងព្រឹត្តិការណ៍មួយចំនួនដូចគ្នា ឬក៏ដែលដោះស្រាយបញ្ហាអង្គហេតុ និងអង្គច្បាប់ស្រដៀងគ្នា[65]។

25. ជាចុងក្រោយ ការអះអាងរបស់ ខៀវ សំផន ដែលថាចៅក្រមដែលរងការប្តឹងជិតចិត្ត គួរតែដកខ្លួនដោយស្ម័គ្រចិត្តដោយខ្លួនឯងនោះ គឺផ្អែកលើការអះអាងខុសថា ពួកគាត់ពេលនេះ "ស្ថិតក្នុងស្ថានភាពដូចគ្នានឹងចៅក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងខណៈដែលពួកគាត់ខ្លួនឯងផ្ទាល់បានណែនាំឱ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ"[66]។ នៅពេលដែលគាត់យោងសម្អាងនេះ កិច្ចដំណើរការនីតិវិធីសវនាការសំណុំរឿង០០២/០២ មិនទាន់បានចាប់ផ្តើមផងទេ[67] ដូច្នេះ អ.ជ.ត.ក គ្រាន់តែអាចធ្វើសមត្ថកម្មថា

---

ការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ជាថ្មី គឺជាការថែរក្សាលទ្ធភាពរបស់ខ្លួនដើម្បីឈានដល់ "ការចេញសាលក្រមកាត់ទោសមួយទាន់ពេលវេលា")។[...] អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា នៅពេលណាមានការបញ្ជាក់ច្បាស់ គោលដៅដូច្នេះមិនត្រូវបានច្រានចោលតាមរយៈសញ្ញាណនៃ "ផលប្រយោជន៍យុត្តិធម៌" *រួមទាំងថា វាអាចលុបលើការព្រួយបារម្ភផ្សេងៗទៀត*។ [...] [អជតក] ទន្ទឹមនេះ រកឃើញថា ការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងថា ការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ ជាថ្មី តម្រូវឱ្យស្ថិតនៅក្នុងផលប្រយោជន៍នៃយុត្តិធម៌ ដែលមិនតម្រូវឱ្យមានអន្តរាគមន៍ពីខាងឧទ្ធរណ៍" (សង្កត់ន័យដើម)។ ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី៣, កថាខណ្ឌ ៥៣-៥៥។

[63] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ ៥១-៥២។

[64] *សូមមើល* កថាខណ្ឌ ១ *យោងខាងលើ*។

[65] ដូចដែលបានពិភាក្សានៅក្នុងផ្នែក IV.ក *ខាងលើ*។

[66] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ៥៣-៥៥។

[67] សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែល អ.ជ.ត.ក បានស្នើទៅកាន់ក្រុមប្រឹក្សាជំនុំជម្រះទីពីរត្រូវបានចេញនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ (*សូមមើល* ឯកសារ **E163/5/1/13** សេចក្តីសេចម្រេចលើបណ្តឹងសាទុក្ខស្តីពីបំបែកកិច្ចដំណើរការនីតិវិធីលើកទី១ កថាខណ្ឌ៥១) ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ (*សូមមើល* ឯកសារ **E284/4/8** សេចក្តីសេចម្រេចលើបណ្តឹងសាទុក្ខស្តីពី

អាចមានភាពលម្អៀង និង/ឬការស្តែងចេញនូវភាពលម្អៀង ដោយយោងទៅលើភាពជាន់គ្នាជាមួយនឹងបញ្ហាដែលបានលើកឡើងនៅក្នុងសំណុំរឿង០០២/០២។ ផ្ទុយទៅវិញ អ.ជ.ត.ក បច្ចុប្បន្ននេះនៅចំពោះមុខខ្លួនមានការបញ្ជាក់ពីក្រុមប្រឹក្សាជំនុំជម្រះពិសេសថា ភាពជាន់គ្នាណាមួយរវាងរឿងក្តីមិនគ្រប់គ្រាន់ដើម្បីបង្ហាញថា អ្នកសង្កេតការដ៏សមហេតុផលនឹងយល់ថា ចៅក្រម (នៅទីនោះ ចៅក្រមអង្គជំនុំជម្រះសាលាដំបូង) អាចមិនមានលទ្ធភាពនាំមកនូវការគិតពីអនាគតិចំពោះសំណុំរឿង០០២/០២នោះទេ ដោយគ្រាន់តែដោយសារពួកគាត់បានធ្វើការសន្និដ្ឋាននានាផ្អែកលើភ័ស្តុតាងនៅក្នុងសំណុំរឿង០០២/០១ នោះ[68]។

*ii. ការរំលោភលើសិទ្ធិប្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលត្រូវបានចោទប្រកាន់*

26. ខៀវ សំផន បានអះអាងដោយខុសឆ្គងថា សិទ្ធិរបស់គាត់ត្រូវបានរំលោភ ប្រសិនបើចៅក្រម ដែលរងនូវការជំទាស់ មិនត្រូវបានទុកជាមោឃៈ ពីព្រោះវា "មិនអាចស្រមៃបាន" ថាតើពួកវាមិនអាចត្រូវបានជះឥទ្ធិពលទៅលើ ដោយការវាយតម្លៃភស្តុតាងពីមុនរបស់ពួកវា ឬយ៉ាងណា និងការរកឃើញផ្ទាល់របស់ពួកវានៅក្នុងសំណុំរឿង០០២/០១[69]។ ការណ៍នេះ និងការលើកឡើងបន្ថែមទៀតរបស់គាត់ថាវាជា "ជំនឿស្ទើរតែទាំងស្រុង" ថា អ.ជ.ត.ក នឹងសម្រេចប្រឆាំងនឹងរូបគាត់[70] គឺគ្រាន់តែជាការសង្ស័យថាជាភាពលំអៀងប៉ុណ្ណោះ ដែលថាវាមិនគ្រប់គ្រាន់ដើម្បីជំទាស់ពីសច្ចធារណ៍នៃអនាគតិ នោះទេ[71]។

---

ការបំបែកកិច្ចដំណើរការនីតិវិធីលើកទី២ កថាខណ្ឌ៧៣-៧៤) និងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ (*សូមមើល* ឯកសារ **E301/9/1/1/3** សេចក្តីសេចម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទី៣ កថាខណ្ឌ ៩០)។ កិច្ចដំណើរការនីតិវិធីសំណុំរឿង០០២/០២ ត្រូវបានបើកនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ (*សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ១៣)។

[68] ឯកសារ **E314/12/1** សំណុំរឿង០០២/០២ សេចក្តីសម្រេច របស់ អ.ជ.ស.ដ លើបណ្តឹងជិតចិត្ត ជាពិសេសកថាខណ្ឌ ១១ (ការចោទប្រកាន់របស់ ខៀវ សំផន ថា មាន "បញ្ហាជាន់គ្នា" មិនមាននោះទេ)។ កថាខណ្ឌ ៥០-៧០ (យោង៖ យុត្តិសាស្ត្រពិភាក្សាអំពីបុរេវិនិច្ឆ័យ និង កម្រងរឿងក្តីដោយឡែក) កថាខណ្ឌ ៩១-១០៥ (យោង៖ ការវិភាគរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេសអំពីការចោទប្រកាន់អំពីបុរេវិនិច្ឆ័យ) កថាខណ្ឌ១០៦ (ការសន្និដ្ឋាន)។

[69] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ៥៦-៥៨ (ការបកស្រាយពីសេចក្តីសម្រេចរបស់ Antonetti)។

[70] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ៥៩។

[71] ឯកសារ **E55/4** សំណុំរឿង០០២/០១ សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើសំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ ១៧-១៩។ ឯកសារ **E314/12/1** សំណុំរឿង០០២/០២ សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើសំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ ៣៥-៣៦, ឯកសារពិសេស PTC02-7 សេចក្តីសម្រេចលើសំណើសុំប្តឹងជិតចិត្តចៅក្រម Lemonde លើកទីមួយ កថាខណ្ឌ ៣៤-៣៦។

*iii. ការជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានផ្នែកអង្គហេតុនៃសាលដីកាសំណុំរឿង០០២/០១*

27. ខៀវ សំផន បានយោងទៅឧបសម្ព័ន្ធដែល "បង្ហាញយ៉ាងលម្អិត" ចំនួន ១៦ ដែលនៅក្នុងនោះ គាត់បានអះអាងថា គាត់បានបកស្រាយបង្ហាញពីការជាន់លើគ្នារវាងសាលដីកាក្នុងសំណុំរឿង០០២/០១ និងកំហុសនានាដែលបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[72]។ ដោយហេតុថា វាមិនអាចមានលទ្ធភាពក្នុងដោះស្រាយនូវការលើកឡើងចោទប្រកាន់នីមួយៗបាន នៅក្នុងរយៈពេល ឬ ចន្លោះពេលដែលបានអនុញ្ញាតចំពោះចម្លើយតបនេះ សហព្រះរាជអាជ្ញានឹងកំណត់អំណះអំណាងរបស់ខ្លួនចំពោះបញ្ហានានាដែល ខៀវ សំផន ចាត់ទុកថាជាការសំខាន់គ្រប់គ្រាន់ល្មមនឹងបង្កើតវាឡើងនៅក្នុងសំណើសុំប្តឹងជំទាស់ដិតចិត្ត។

28. កាលណាពិចារណាពីអំណះអំណាងនានាដែលស្រដៀងគ្នា ប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមជំនុំជម្រះ នៅក្នុងសាលក្រមនៃសំណុំរឿង០០២/០១ ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានថ្លែងថា៖

> អ្វីដែលត្រូវបង្ហាញនោះគឺថា សេចក្តីសម្រេចទាំងនេះត្រូវបាន ឬនឹងត្រូវបានយល់ឃើញយ៉ាងសមហេតុផលថា ជាលទ្ធផលនៃបុរេវិនិច្ឆ័យប្រឆាំងនឹងម្ចាស់បណ្តឹង ដែលមិនមែនជាការអនុវត្តច្បាប់ពិតប្រាកដ ផ្អែកលើលទ្ធផលនៃការបកស្រាយច្បាប់ ឬការវាយតម្លៃរបស់ចៅក្រមទៅលើអង្គហេតុនានា[73]។

29. ការអនុវត្តនូវតេស្តសាកល្បងនេះ ក៏ដូចជាតេស្តសាកល្បងស្តីពី "ធាតុផ្សំទាំងអស់" ពី *Poppe* ដែរ ការរកឃើញរបស់សាលដីកាដែល ខៀវ សំផន ជំទាស់នេះ បានបង្ហាញយ៉ាងច្បាស់ថា អ.ជ.ត.ក បានអនុវត្តយ៉ាងពិតប្រាកដនូវច្បាប់ និងបានវាយតម្លៃពីអង្គហេតុនានាដោយមិនមានធ្វើបុរេវិនិច្ឆ័យលើបញ្ហានានាដែលទាក់ទិនទៅនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០២ នោះឡើយ។ លើសពីនេះទៅទៀត ជំនួសឲ្យការធ្វើតាមវិធីសាស្ត្ររបស់ ខៀវ សំផន ស្តីពីការញែកឲ្យនៅដាច់ពីគេនូវប្រយោគតែឯងសម្រាប់ការវិភាគបែបដូច្នេះ សាលក្រមនេះបានវាយតម្លៃយ៉ាងត្រឹមត្រូវជាងជាការវិភាគមួយដែលមានការទាក់ទងគ្នាទៅវិញទៅមក ដែលនៅក្នុងនោះ សេចក្តីថ្លែងដែលមានកម្រិតដែលបានធ្វើឡើងនៅពេលចាប់ផ្តើមការវិភាគត្រូវបានយល់ ដើម្បីអនុវត្តទៅលើការវិភាគទាំងស្រុងដែលមានតាម

---

[72] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ដិតចិត្ត កថាខណ្ឌ៦០។

[73] ឯកសារ **E314/12/1** សំណុំរឿង០០២/០២ សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើសំណើសុំប្តឹងជំទាស់ដិតចិត្ត កថាខណ្ឌ ៣៦។ ឯកសារពិសេស PTC02-7 សេចក្តីសម្រេចលើសំណើសុំប្តឹងដិតចិត្តចៅក្រម Lemonde លើកទីមួយ កថាខណ្ឌ ៣៤។

ក្រោយ (ដូចជា សេចក្តីថ្លែងនានាដែលបានបញ្ជាក់ថា ការវិភាគនេះគឺត្រូវបានកម្រិតតែចំពោះបរិបទនៃសំណុំរឿង០០២/០១)។

30. **សហករណ៍ និង ការដ្ឋាន**[74]: ការយោងរបស់ ខៀវ សំផន ទៅរកការកំណត់ *"ដែលបាននិយាយដោយចៃដន្យ" (obiter dictum)* របស់ អជតក ដើម្បីបង្ហាញអំពីការធ្វើបុរេវិនិច្ឆ័យ[75]។ តាមន័យត្រង់ ពាក្យថា *obiter dictum* មានន័យថា "អ្វីដែលបាននិយាយដោយចៃដន្យ"[76] និងនៅក្នុងរឿងក្តី *Poppe* សេចក្តីថ្លែងដែលបានធ្វើឡើងដោយចៃដន្យដែលមិនបានសម្រេចលើគ្រប់លក្ខខណ្ឌវិនិច្ឆ័យពាក់ព័ន្ធចាំបាច់ទាំងអស់ដើម្បីបង្កើតជាបទល្មើសព្រហ្មទណ្ឌណាមួយ ឬរកមិនឃើញថា អ្នកដាក់ពាក្យ មានពិរុទ្ធភាពចំពោះបទល្មើសហួសពីវិមតិសង្ស័យ គឺជាបរាជ័យក្នុងការកំណត់អំពីអនាគតិ និង/ឬការលេចឡើងនៃអនាគតិ[77]។ ការប៉ុនប៉ងផ្សេងទៀតរបស់ ខៀវ សំផន ដើម្បីបង្ហាញអំពីការធ្វើបុរេវិនិច្ឆ័យអំពីគោលនយោបាយការដ្ឋាន ក៏បរាជ័យផងដែរ ដោយសារ កថាខណ្ឌដែលគាត់យោងគ្រាន់តែបាននិយាយអំពីទស្សនៈ "យោងតាមដីកាដំណោះស្រាយ" ដែលមិនមែនដូចគ្នានឹងការរកឃើញរបស់ អជតក ទេ[78]។ ចំពោះការតវ៉ាផ្សេងទៀតរបស់គាត់ អជតក បានកត់សម្គាល់យ៉ាងច្បាស់ថា ការចុះពិនិត្យមើលតាមការដ្ឋាននានារបស់ ខៀវ សំផន គឺពាក់ព័ន្ធតែទៅនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងតំណាក់កាលទីII ប៉ុណ្ណោះ ដែលជាបញ្ហានៅក្នុងសំណុំរឿង០០២/០១[79]។ កថាខណ្ឌដែលអះអាងថា "បានសម្រេចអំពីការពាក់ព័ន្ធ [របស់ ខៀវ សំផន] នៅក្នុងការធ្វើគោលនយោបាយសេដ្ឋកិច្ច"[80] គឺគ្រាន់តែបានពិភាក្សាអំពីថាតើ អង្គជំនុំជម្រះសាលាដំបូងសមហេតុផលនៅក្នុងការវាយតម្លៃរបស់ខ្លួនលើឯកសារមួយចុះខែកញ្ញា ឆ្នាំ១៩៧៥ ដែរឬ អត់ប៉ុណ្ណោះ ហើយបាន

[74] ឯកសារ **F53** សំណើសុំប្តឹងជំទាស់, កថាខណ្ឌ ៦២-៦៤។

[75] ឯកសារ **F53** សំណើសុំប្តឹងជំទាស់, កថាខណ្ឌ ៦២-៦៣។

[76] វចនានុក្រមច្បាប់ *Black's Law Dictionary*, ច្បាប់បោះពុម្ពលើកទី៩ (២០០៩), ទំព័រ ១១៧៧។

[77] សាលក្រម *Poppe*, កថាខណ្ឌ ២៨។

[78] ឯកសារ **F53** សំណើសុំប្តឹងជំទាស់, កថាខណ្ឌ ៦២ *យោង* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ២២៧ ("យោងតាមដីកាដំណោះស្រាយ (D427), គោលបំណងមួយក្នុងចំណោមគោលបំណងនានានៃការផ្លាស់ទីលំនៅប្រជាជន គឺ "ដើម្បីបំពេញលក្ខខណ្ឌតម្រូវផ្នែកពលកម្មនៅតាមសហករណ៍ និងការដ្ឋាននានា")។

[79] ឯកសារ **F53** សំណើសុំប្តឹងជំទាស់, កថាខណ្ឌ ៦៤។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ១០២៨ (ក្រោយការទទួលស្គាល់អំណះអំណាងរបស់ ខៀវ សំផន ថា ភស្តុតាងធ្លាក់ចេញពីវិសាលភាពនៃសំណុំរឿង ០០២/០១ អជតក បានកត់សំគល់ថា "ភស្តុតាងគឺពាក់ព័ន្ធដោយហេតុថា មានមនុស្សខ្លះដែលត្រូវបានគេបញ្ជូន ជាផ្នែកមួយនៃការផ្លាស់ទីលំនៅក្នុងដំណាក់កាលទី២ តាមពិតពួកគេត្រូវបានគេបញ្ជូនទៅកាន់ការដ្ឋាននានា")។

[80] ឯកសារ **F53** សំណើសុំប្តឹងជំទាស់, កថាខណ្ឌ ៦៤។

រកឃើញថា វាមិនមែនហេតុផលទេ (ដូច្នោះ ការរកឃើញពាក់ព័ន្ធ ក៏មិនសមហេតុផលដូចគ្នាដែរ)[81]។ ជាចុងក្រោយ អជតក មិនបានរកឃើញអង្គហេតុទាក់ទងនឹង "ការគូសបញ្ជាក់អំពីផែនការសេដ្ឋកិច្ចឆ្នាំ១៩៧៧"ទេ[82]។ ផ្ទុយទៅវិញ អជតក បានរកឃើញថា ខៀវ សំផន ខកខានមិនបានបង្ហាញភ័ស្តុតាងទៅលើអំណះអំណាងរបស់ខ្លួន ដែលតវ៉ាចំពោះការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះទេ និងដោយគ្មានអ្វីផ្សេងទៀត ធ្វើឲ្យការរកឃើញនេះហាក់ដូចជាមិនមែនមិនសមហេតុផលនោះឡើយ[83]។

31. **គោលនយោបាយកំណត់គោលដៅលើអតីតទាហ៊ាន និងមន្ត្រីសាធារណរដ្ឋខ្មែរ**[84]៖ ខៀវ សំផន បានដកស្រង់តាមបែបជ្រើសរើសនូវប្រយោគមិនជាប់គ្នាចំនួនពីរចេញពីកថាខណ្ឌដ៏វែងមួយ ដែលបានបង្កើតការសន្និដ្ឋានមួយមិនត្រឹមត្រូវដែល តាមពិតជាក់ស្តែង មិនមាននោះឡើយ[85]។ នៅពេលដែលកថាខណ្ឌនៃសាលដីកានេះត្រូវបានពិនិត្យឲ្យបានត្រឹមត្រូវ ក្នុងភាពពេញលេញទាំងស្រុងរបស់វា បរិបទបានបង្ហាញយ៉ាងច្បាស់ថា អ.ជ.ត.ក កំពុងពិភាក្សាភាពជាន់គ្នានៅក្នុងដីកាដំណោះស្រាយ (D427) មិនមែនធ្វើការសន្និដ្ឋានលើគោលនយោបាយ ប.ក.ក នោះទេ។ បន្ទាប់មក ខៀវ សំផន ដកស្រង់យកសម្រង់ចំនួនពីរចេញពីការវិភាគដ៏ទូលំទូលាយរបស់ អ.ជ.ត.ក លើភ័ស្តុតាងគាំទ្រការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលដំបូង ដែលថាគោលនយោបាយដែលរៀបចំឡើងសម្រាប់ការសម្លាប់ទាហ៊ាន និងមន្ត្រីសាធារណរដ្ឋខ្មែរ បានកើតមានឡើងក្នុងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ[86]។

---

[81] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៨៣៨, ៨៤០-៨៤២ (ពិភាក្សាអំពីអំណះអំណាងរបស់ ខៀវ សំផន ដោយមានការកត់សម្គាល់អំពីឯកសារជាច្រើនដែលបានគាំទ្រដល់ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង មានការពិភាក្សាអំពីគោលការណ៍ *ពេលមានមន្ទិលសង្ស័យ ផលប្រយោជន៍បានទៅជនជាប់ចោទ* និងការពន្យល់ថា ភាពមិនស៊ីចង្វាក់គ្នាក្នុងវត្ថុតាងនីមួយៗ មិនបានធ្វើឲ្យការពឹងផ្អែករបស់អង្គជំនុំជម្រះទៅលើវត្ថុតាមនីមួយៗទាំងនោះ មិនសមហេតុផលនោះទេឲ្យតែភ័ស្តុតាងទាំងនោះជារួមគាំទ្រដល់ការរកឃើញមួយដែលហួសពីវិមតិសង្ស័យ)។

[82] *ផ្ទុយទៅនឹង* ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត, កថាខណ្ឌ ៦៤។

[83] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៨៤៣។

[84] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ៦៥-៦៦។

[85] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ៦៥ ដែលបានដកស្រង់ពីឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ ២២៧។

[86] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ៦៦ ដែលបានស្រង់ការដកស្រង់ចេញពីឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៦០, ៩៧០។ ការវិភាគពេញលេញរបស់ អ.ជ.ត.ក មាននៅក្នុង ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ៩៣៤-៩៧២។ ការអានដោយស្មោះត្រង់បង្ហាញថា អ.ជ.ត.ក បានវាយតម្លៃរាល់ទិដ្ឋភាពនៃភ័ស្តុតាង

ទោះបីជាសម្រង់ដែលបានស្រង់ចេញមកនោះយោងទៅលើភស្តុតាង ដែលមានកាលបរិច្ឆេទមុនការសម្លាប់នៅទួលពោធិ៍ជ្រៃក៏ដោយ ក៏ អ.ជ.ត.ក បានពន្យល់ថា អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិផ្អែកលើភស្តុតាងបែបនេះ "ដើម្បីទាញការសន្និដ្ឋានអំពីគោលនយោបាយនៅមុនព្រឹត្តិការណ៍"[87]។ ដូច្នេះ នៅក្នុងការវិភាគរបស់ខ្លួនអំពីភស្តុតាងជាមូលដ្ឋានចំពោះការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងនេះ អ.ជ.ត.ក បានវាយតម្លៃភស្តុតាងក្រោយនោះក្នុងគោលបំណងក៏មានកម្រិតនេះ។ បើពិនិត្យមើលក្នុងបរិបទត្រឹមត្រូវ និងក្នុងភាពទាំងស្រុងរបស់វា កថាខណ្ឌដែលរងការជំទាស់ទាំងនេះ គ្រាន់តែបង្ហាញថាភស្តុតាងក្រោយនោះ មិនបានបង្ហាញពីគោលនយោបាយនៅមុនព្រឹត្តិការណ៍ឱ្យបានគ្រប់គ្រាន់នោះទេ។

32. **គោលនយោបាយខ្មាំង**[88]៖ នៅពេលដែលកថាខណ្ឌដែលរងការជំទាស់លេខ ៩៣៣ ត្រូវបានពិនិត្យមើលក្នុងបរិបទនៃផ្នែករបស់សាលក្រម ដែលជាកន្លែងដែលវាស្ថិតនៅ ជាជាងនៅដាច់តែឯងនោះ វាបង្ហាញយ៉ាងច្បាស់ថា ការវិភាគរបស់ អ.ជ.ត.ក ពាក់ព័ន្ធទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង អំពីគោលនយោបាយកំណត់គោលដៅថា "បានបន្តពេញមួយរយៈកាលនៃសំណុំរឿង ០០២/០១"[89] និងមិនបន្តហួសពីនេះដោយគ្មានការអនុញ្ញាតនោះទេ។ កថាខណ្ឌដែលរងការជំទាស់

និងបានសន្និដ្ឋានថា *ជាអាទិ៍* ថា "មានកម្រិតខ្សោយ ពុំមានភាពច្បាស់លាស់ និងមានតម្លៃទាប" (កថាខណ្ឌ៩៧០)។ អ.ជ.ត.ក បានសម្រេចថា ការសន្និដ្ឋានផ្នែកគោលនយោបាយរបស់អង្គជំនុំជម្រះមិនសមហេតុផលទេ។

[87] ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ៩៥៦។

[88] ឯកសារ **F53** សំណើសុំប្តឹងឧទ្ធរណ៍ កថាខណ្ឌ៦៧។

[89] ឯកសារ **F53** សំណើសុំប្តឹងឧទ្ធរណ៍ ជើងទំព័រ៩៥។ ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ៩២៣ ថ្លែងថា ជនជាប់ចោទបានលើកឡើងនូវទឡ្ហីករណ៍ជាច្រើននៃបណ្តឹងសាទុក្ខ ដែលជំទាស់ទៅនឹង "ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គោលនយោបាយ "កំណត់គោលដៅសម្រាប់ការចាប់ខ្លួន ការសម្លាប់ និង/ឬការធ្វើឱ្យបាត់ខ្លួនសមាសភាពទាំងអស់នៃរបបសាធារណរដ្ឋខ្មែរ" បានបន្តពេញមួយរយៈកាលនៃសំណុំរឿង ០០២/០១ បានផ្អែកជាមូលដ្ឋានទៅលើភស្តុតាងដែលពាក់ព័ន្ធទៅនឹងគោលជំហរ និងការណែនាំរបស់ ប.ក.ក ជាពិសេស ពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណ និងការប្រព្រឹត្តចំពោះ "ខ្មាំង"" (គូសបញ្ជាក់បន្ថែម)។ ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងនេះត្រូវបានពិនិត្យនៅក្នុងកថាខណ្ឌបន្តបន្ទាប់ ហើយកថាខណ្ឌដែលរងការជំទាស់លេខ ៩៣៣ ទាក់ទងទៅនឹងទឡ្ហីករណ៍ទីមួយនៃបណ្តឹងសាទុក្ខ (កថាខណ្ឌ៩២៤-៩៣៣) ទាក់ទងទៅនឹងការសន្និដ្ឋាននេះ។ ខណៈដែលការសន្និដ្ឋានគ្រប់ជ្រុងជ្រោយត្រូវបានកំណត់ត្រឹម "រយៈកាលនៃសំណុំរឿង ០០២/០១" ដូចគ្នាទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ត.ក នៅក្នុងកថាខណ្ឌ ៩៣៣ ដែរ។

ទីពីរមានដែនកំណត់ស្រដៀងគ្នា ដែលកំណត់ត្រឹម "ពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ" ដែលជាបញ្ហាក្នុងសំណុំរឿង០០២/០១[90]។

33. **ការចូលរួមប្រព្រឹត្តសហកម្មឧក្រិដ្ឋកម្មរួម ("JCE") និងការយល់ដឹងអំពីឧក្រិដ្ឋកម្មនានា**[91]៖ ដូចបានកត់សម្គាល់ដោយអង្គជំនុំជម្រះពិសេសនៅពេលដែលអង្គជំនុំជម្រះនេះ ធ្វើការវាយតម្លៃលើសំណើសុំប្ដឹងជិតចិត្តចៅក្រមសាលាដំបូងក្នុងសំណុំរឿង០០២/០២នោះ ចំណែកឯសំណុំរឿង០០២/០១ និង ០០/០២ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ខុសគ្នាជាសារវ័ន្តទាក់ទងនឹងឧក្រិដ្ឋកម្ម និងទីតាំងឧក្រិដ្ឋកម្ម[92]។ សំណុំរឿង០០២/០២ ក៏មានបញ្ជីធំល្មមនៃឈ្មោះឯកសារ សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលមិនមែនជាផ្នែកនៃភ័ស្តុតាងក្នុងសំណុំរឿង០០២/០១[93]។ នៅក្នុងការវាយតម្លៃរបស់ខ្លួន អង្គជំនុំជម្រះពិសេសបានពិចារណាថា សាលក្រមសំណុំរឿង០០២/០១ មានការសម្រេចជាបុរេនិច្ឆ័យចំពោះការចូលរួមប្រព្រឹត្ត JCE របស់ ខៀវ សំផន ប៉ុន្តែដោយសារអង្គជំនុំជម្រះសាលាដំបូងមិនបានវាយតម្លៃ ឬកំណត់អំពី*បំណងឧក្រិដ្ឋ* របស់គាត់ ទាក់ទងនឹងឧក្រិដ្ឋកម្មនៃសំណុំរឿង ០០២/០២ ឬមិនបានរកឃើញថា តើ JCE បណ្ដាលឲ្យមាន និង/ឬ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនៃសំណុំរឿង០០២/០២នោះ ទើបអនាគតិ ឬការលេចឡើងនៃអនាគតិមិនត្រូវបានបង្កើតឡើង[94]។ ស្រដៀងនេះ សាលដីកាសំណុំរឿង០០២/០១ មិនបានរកឃើញដូច្នេះទេ។

34. ទោះជាមានការរកឃើញខាងអង្គហេតុណាមួយដែល ខៀវ សំផន បានជំទាស់ គួរត្រូវបានពិចារណាជាន់គ្នាក្ដី ក៏លទ្ធភាពដែលអាចមាននៃ "ការសម្រេចដែលមានលក្ខណៈបុរេវិនិច្ឆ័យលើបញ្ហានានាដែលពាក់ព័ន្ធជារួម" មិនមែនមានន័យថាចៅក្រមម្នាក់មិនត្រូវបានគេពិចារណាថា មិនលំអៀងនោះទេ[95]។ ជាចុងក្រោយ ចៅក្រមដែលរងការជំទាស់ បានដឹងយ៉ាងច្បាស់ថា "ធាតុផ្សំនៃអង្គហេតុរួម

[90] ឯកសារ **F53** សំណើសុំប្ដឹងជិតចិត្ត ជើងទំព័រ៩៥។ ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ៩០៧ អានភ្ជាប់ជាមួយកថាខណ្ឌ ៩០១-៩០៦។

[91] ឯកសារ **F53** សំណើសុំប្ដឹងជិតចិត្ត, កថាខណ្ឌ ៦៨-៦៩។

[92] ឯកសារ **E314/12/1** សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្តរបស់ អជសជ ក្នុងសំណុំរឿង ០០២/០២, កថាខណ្ឌ ៩៣។

[93] ឯកសារ **E314/12/1** សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្តរបស់ អជសជ ក្នុងសំណុំរឿង ០០២/០២, កថាខណ្ឌ ៩៥។

[94] ឯកសារ **E314/12/1** សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្តរបស់ អជសជ ក្នុងសំណុំរឿង ០០២/០២, កថាខណ្ឌ ៩៤។

[95] ឯកសារ **E314/12/1** សេចក្ដីសម្រេចលើបណ្ដឹងជិតចិត្តរបស់ អជសជ ក្នុងសំណុំរឿង ០០២/០២, កថាខណ្ឌ ៩៦។ *ដែលបានយោង* ឯកសារ **E301/9/1/1/3** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខបំបែកកិច្ចដំណើរការនីតិវិធីលើកទីបី កថាខណ្ឌ៨៣។

នៅគ្រប់ករណីទាំងអស់ត្រូវតែបានបង្កើតឡើងថ្មីៗ" ដែលពួកគាត់បានអះអាងនាពេលកន្លងមក[96] និង អាចឱ្យរំពឹងទុកថា នឹងជួយលើកកម្ពស់ដល់លក្ខខណ្ឌតម្រូវនេះ។

### iv. *ការតវ៉ាចំពោះការសម្រេចផ្នែកច្បាប់នៅក្នុងសាលដីកាសំណុំរឿង០០២/០១*

35. ខៀវ សំផន ទាមទារថា ចៅក្រមដែលរងការជំទាស់បានធ្វើការវិនិច្ឆ័យទុកជាមុនលើបញ្ហាច្បាប់ដែលសំខាន់បំផុតដល់បណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង០០២/០២[97] របស់គាត់នោះ គឺគ្មានអង្គសេចក្តីទេ។ ចៅក្រម មិនត្រូវបានហាមឃាត់ពីការចូលរួមធ្វើជាអធិបតីក្នុងការចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌពីរដាច់ពីគ្នាដែលកើតចេញពីឈុតនៃអង្គហេតុតែមួយនោះទេ ទោះបីជាករណីទាំងនោះមានភាពត្រួតស៊ីគ្នា ឬបញ្ហាស្រដៀងគ្នានៃអង្គហេតុ ឬអង្គច្បាប់ក៏ដោយ ឱ្យតែគេអាចនាំយកនូវចិត្តគំនិតអនាគតិទៅលើភ័ស្តុតាងក្នុងសំណុំរឿងថ្មី[98]។ ផ្ទុយទៅនឹងការយល់ឃើញរបស់គាត់អំពីអង្គច្បាប់ បញ្ហាគន្លឹះចំពោះការវាយតម្លៃក្នុងការធ្វើបុរេវិនិច្ឆ័យនៅទីនេះ គឺថាតើចៅក្រមដែលរងការជំទាស់ បានសម្រេចនៅក្នុងសំណុំរឿង០០២/០១ លើគ្រប់ធាតុផ្សំនៃបទល្មើសក្នុងសំណុំរឿង០០២/០២ ដែរឬទេ និងបានរកឃើញថា ខៀវ សំផន មានពិរុទ្ធហួសពីវិមតិសង្ស័យក្នុងការប្រព្រឹត្តបទល្មើសនោះ ដែរឬអត់[99]។ ការណ៍នេះមិនបានកើតឡើងទេ។ ជាឧទាហរណ៍ ចៅក្រមដែលរងការជំទាស់ នឹងត្រូវវាយតម្លៃជាថ្មីថាតើភ័ស្តុតាងដែលបានពឹងផ្អែកដោយអង្គជំនុំជម្រះសាលាដំបូង បានបំពេញគ្រប់គ្រាន់តាមធាតុផ្សំចាំបាច់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនីមួយៗ ដូចបានចោទប្រកាន់ក្នុងសំណុំរឿង០០២/០២

---

[96] ឯកសារ **E314/12/1** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់ អជសជ ក្នុងសំណុំរឿង ០០២/០២, កថាខណ្ឌ ៩៦ *យោង* ឯកសារ **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីបី, កថាខណ្ឌ ៨៥។

[97] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ ៧០-៧៥។

[98] *សូមមើល* ការដកស្រង់ដែលមានរៀបរាប់នៅក្នុងជើងទំព័រលេខ ៣១ *យោងខាងលើ*។ អង្គហេតុដែលថា ចៅក្រមម្នាក់ពីមុនធ្លាប់បានធ្វើសេចក្តីសន្និដ្ឋានផ្នែកច្បាប់ទាក់ទងទៅនឹងរឿងក្តីបច្ចុប្បន្ន ឬ "ស្រប" ទៅនឹងទិដ្ឋភាពនានានៃរឿងក្តីបច្ចុប្បន្ន មិនបានបង្ហាញពីភាពលម្អៀងឡើយ (*សូមមើល ឧទាហរណ៍* ឯកសារ **E55/4** សំណុំរឿង០០២/០១ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ជ កថាខណ្ឌ១៦, ១៨។ *Mladić*, IT-09-92-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីសុំឱ្យមានការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌ និងសច្ចធារណ៍នៃនីរទោស ឬ ជាជម្រើសម្យ៉ាងទៀត សវនាការដែលមិនត្រឹមត្រូវ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៦ ("សេចក្តីសម្រេចស្តីពីសវនាការត្រឹមត្រូវយុត្តិធម៌ក្នុងរឿងក្តី *Mladić*") កថាខណ្ឌ២, ២៤។

[99] សាលក្រម *Poppe* កថាខណ្ឌ ២៨។ ឯកសារ **E314/12/1** សំណុំរឿង០០២/០២ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ជ កថាខណ្ឌ៤១-៤៤។ ឯកសារ **E55/4** សំណុំរឿង០០២/០១ សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ជ កថាខណ្ឌ១៧-១៨។ សេចក្តីសម្រេចស្តីពីសវនាការត្រឹមត្រូវយុត្តិធម៌ក្នុងរឿងក្តី *Mladić* កថាខណ្ឌ១១-១២។ *ផ្ទុយពីនេះ* ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ៧០។

ដែរឬទេ ទោះបីជាមានការរកឃើញពីមុនណាមួយរបស់ អជតក នៃធាតុផ្សំបរិបទនៅក្នុងសំណុំរឿង ០០២/០១ ក៏ដោយ។ ខៀវ សំផន បានអះអាងដោយគ្មានការបញ្ជាក់ពីភាពលំអៀងជាក់ស្តែង ឬការយល់ដឹងសមហេតុផលថា ចៅក្រមដែលរងការជំទាស់ មិនអាចវាយតម្លៃលើបញ្ហានេះក្នុងសំណុំរឿង ០០២/០២ ដោយចិត្តគំនិតអនាគតិឡើយ។

36. សរុបមក ខៀវ សំផន មិនត្រឹមតែខកខានមិនបានបង្ហាញឲ្យឃើញថា ចៅក្រមដែលរងការជំទាស់ មិនបានធ្វើអ្វីក្រៅតែពីការអនុវត្តច្បាប់សុទ្ធសាធ និងវាយតម្លៃលើអង្គហេតុ ថែមទាំងគាត់ក៏ខកខានមិនបានបំពេញលក្ខខណ្ឌតម្រូវតាមតេស្តសាកល្បងក្នុងរឿងក្តី *Furundžija* ផងដែរ។ អ្នកសង្កេតការណ៍សមហេតុផលដែលមានការជ្រួតជ្រាប នឹងទទួលស្គាល់នូវប្រពៃណីនៃសុចរិតភាពតុលាការ និងសច្ចធារណ៍នៃអនាគតិតុលាការដ៏ខ្លាំងក្លា[100] ព្រមទាំងកាលៈទេសៈទាំងមូលនៃសំណុំរឿង០០២ នៅ អ.វ.ត.ក រួមទាំងការពិតដែលសំណុំរឿង០០២ មិនត្រូវបានបំបែក ដែលចៅក្រមរងការជំទាស់ម្នាក់ៗដែលបានសម្រេចសេចក្តីក្នុងសំណុំរឿង០០២/០១ គួរតែបានចូលរួមសម្រេចលើបញ្ហានានា នៅក្នុងសំណុំរឿង០០២/០២ នៅក្នុងសាលក្រមតែមួយ។ អ្នកសង្កេតការណ៍សមហេតុផលគួរតែបានទទួលដំណឹងផងដែរថា ខៀវ សំផន ត្រូវបានតំណាងមួយភាគធំដោយក្រុមមេធាវីការពារក្តីតែមួយ នៅទូទាំងដំណើរការនៃសំណុំរឿងទាំងមូល និងបានដឹងជាយូរមកហើយអំពីចេតនាក្នុងការធ្វើចំណាត់ការជាមួយចៅក្រមដដែលក្នុងសំណុំរឿង០០២/០២[101]។ ខៀវ សំផន ខកខានមិនបានបង្ហាញឲ្យឃើញថា អ្នកសង្កេតការណ៍សមហេតុផល គួរតែបានដឹងជាសត្យានុម័តអំពីភាពលម្អៀងនោះទេ នៅពេលគាត់បានដឹងយ៉ាងច្បាស់អំពីកាលៈទេសៈទាំងនេះ។

## គ. ខៀវ សំផន ខកខានមិនបានបង្ហាញឲ្យឃើញភាពលម្អៀង និង/ឬ ការស្តែងចេញនូវភាពលម្អៀង នៅក្នុងសេចក្តីសន្និដ្ឋានផ្លូវច្បាប់នៃសាលដីកាបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១

37. ក្នុងការជំទាស់ថា សេចក្តីសន្និដ្ឋានផ្លូវច្បាប់ដែលត្រូវបានធ្វើឡើងដោយ អ.ជ.ត.ក ក្នុងសំណុំរឿង ០០២/០១ ("កំហុសបួនដែលត្រូវបានចោទប្រកាន់")[102] បង្ហាញពីភាពលម្អៀង និង/ឬ ការស្តែង

[100] *សូមមើល ឧទាហរណ៍* សាលដីកា *Čelebići* កថាខណ្ឌ៦៨៧។

[101] ឯកសារ **E314/12/1** សេចក្តីសម្រេចលើបណ្តឹងជំទាស់ដីតចិត្តរបស់ អជសជ ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១, ១០៦។

[102] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ ៨០-១០៩ បានចោទប្រកាន់កំហុសនៅក្នុងសេចក្តីសន្និដ្ឋានផ្នែកច្បាប់របស់ អ.ជ.ត.ក លើ (i) ការធ្វើតេស្តិ៍ផ្នែកច្បាប់ចំពោះឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវដើម្បីបំពេញតាមគោលការណ៍នីត្យានុកូលភាព (ii) ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (iii) ធាតុផ្សំអត្តនោម័តសម្រាប់សហឧក្រិដ្ឋកម្មរួម ("JCE") និង (iv) ការកំណត់ប្រភេទបទល្មើសនៃទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន។

ចេញនូវភាពលម្អៀងខាងផ្នែកចៅក្រមដែលរងការប្តឹងទាំងនេះ ខៀវ សំផន យល់ខុស ហើយដូច្នេះខកខានមិនបានបំពេញបទដ្ឋាននៃភ័ស្តុតាងសម្រាប់ការចោទប្រកាន់ពីភាពលម្អៀង និង/ឬ ការស្តែងចេញនៃភាពលម្អៀង។ ផ្ទុយទៅវិញ គាត់ស្វែងកទាំងគ្មានការអនុញ្ញាតឲ្យជំនុំជម្រះក្តីឡើងវិញ នៅក្នុងវេទិការមួយដែលមិនសមស្រប ជាបញ្ហាដែលគាត់ធ្លាប់បានស្នើសុំមិនជោគជ័យក្នុងសំណុំរឿង ០០២/០១។

38. ខៀវ សំផន បានទទួលស្គាល់យ៉ាងត្រឹមត្រូវថា នៅពេលវាយតម្លៃថាតើ មានភាពលម្អៀង ឬការស្តែងចេញនូវភាពលម្អៀង ឬយ៉ាងណានោះ បញ្ហាគឺ "មិនមែនដើម្បីបង្ហាញថាតើ [អ.ជ.ត.ក] ភាន់ច្រឡំនោះទេ ប៉ុន្តែដើម្បីបង្ហាញថាតើតាមរយៈសម្អាងហេតុរបស់តុលាការនេះ វាមានលេចឡើងនូវអ្វីដែលបង្ហាញថាតុលាការនេះលំអៀង ឬអត់"[103] និងថា សេចក្តីសម្រេចរបស់តុលាការដែលត្រូវបានដកស្រង់ជាភ័ស្តុតាងអំពីភាពលម្អៀង គួរតែត្រូវពិនិត្យមើល "មិនមែនរកឲ្យឃើញកំហុសនោះទេ គឺពិនិត្យដើម្បីកំណត់ថាតើ តាមរយៈកំហុសជាយថាហេតុ វាស្តែងឲ្យឃើញថាចៅក្រមពិតជាលំអៀងមែន ឬវាស្តែងឲ្យឃើញថា អ្នកអង្កេតការណ៍សមហេតុផលម្នាក់ដែលដឹងច្បាស់អំពីកាលៈទេសៈពាក់ព័ន្ធ អាចព្រួយបារម្ភថាចៅក្រមលំអៀង ដោយមានហេតុផល ឬអត់"[104]។ និយាយម្យ៉ាងទៀត កំហុសអង្គច្បាប់ផ្ទាល់មិនគ្រប់គ្រាន់ដើម្បីបង្ហាញពីភាពលម្អៀងឡើយ ហើយវា "ភាគីមិនមានមូលដ្ឋានគ្រប់គ្រាន់ដោយគ្រាន់តែចោទប្រកាន់ថា សេចក្តីសម្រេចទាំងនោះមានកំហុសនោះទេ"[105]។ នៅក្នុងសេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តនៃសំណុំរឿង០០២/០២របស់ខ្លួន ក្រុមប្រឹក្សាជំនុំជម្រះពិសេសបានបញ្ជាក់យ៉ាងច្បាស់ថា ភាគីមិនត្រូវប្រើសំណើសុំប្តឹងជំទាស់ចិត្តជាវេទិការសម្រាប់ជំទាស់ទៅនឹងអង្គសេចក្តីនៃសេចក្តីសម្រេចពីមុនដែលខ្លួនមិនយល់ស្របនោះទេ[106]។

---

[103] *សូមមើ* ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ ៧៧ *បានដកស្រង់* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១២ និងការដកស្រង់ខាងក្នុង។ *សូមមើលផងដែរ* ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ ៧៨ *ដែលបានដកស្រង់* ឯកសារ **E314/12/1** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦។ ឯកសារ **E55/4** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១៣។

[104] **F53** សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ ៧៨ (គូសបញ្ជាក់បន្ថែម) *បានដកស្រង់* ឯកសារ **E314/12/1** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦។ ឯកសារ **E55/4** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១៣។ *សូមមើលផងដែរ* ការដកស្រង់ខាងក្នុងនោះ។

[105] **E314/12/1** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦។ ឯកសារ **E55/4** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១៣។

[106] **E314/12/1** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦ *ដែលបានដកស្រង់* ឯកសារ **E55/4** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១៣។

39. ប៉ុន្តែ វាច្បាស់ណាស់ថា តាមរយៈការសន្និដ្ឋានរបស់គាត់ ខៀវ សំផន ប្រៀបធៀបកំហុសអង្គច្បាប់ (ដែលបានចោទប្រកាន់) ជាមួយនឹងភាពលម្អៀងទាំងមិនអាចអនុញ្ញាតឱ្យធ្វើទៅបាន[107] និងបានក្លែងបន្លំបណ្តឹងសាទុក្ខដែលត្រូវបានហាមឃាត់[108] តាមនីតិវិធីប្រឆាំងនឹងសាលដីកាបណ្តឹងសាទុក្ខសំណុំរឿង០០២/០១ ធ្វើជាសំណើសុំប្តឹងជំទាស់ចៅក្រម។ ក្នុងការធ្វើដូច្នេះ គាត់ខកខានមិនបានដឹងច្បាស់ ឬបំពេញបាននូវ "បន្ទុកបង្ហាញភស្តុតាងក្នុងកម្រិតខ្ពស់" ដែលភាគីស្វែងរកដើម្បីជំទាស់ទៅនឹងសច្ចធារណ៍នៃភាពអនាគតិរបស់ចៅក្រមត្រូវបំពេញ[109]។ ដូចដែលក្រុមប្រឹក្សាជំនុំជម្រះពិសេសបានសម្រេចថា "ការដែលជនជាប់ចោទត្រឹមតែសង្ស័យថា មានភាពលម្អៀង មិនមានភាពគ្រប់គ្រាន់នោះទេ។ លក្ខខណ្ឌតម្រូវនោះគឺការយល់ឃើញអំពីភាពលម្អៀងដែលមានហេតុផលត្រឹមត្រូវ និងមិនលម្អៀង ផ្អែកលើការយល់ដឹងអំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់"[110]។ ស្របគ្នាទៅនឹងគោលជំហរនេះ តុលាការ ICTY Bureau បានលើកឡើងថា ខណៈដែលខ្លួន "មិនបដិសេធចោលទាំងស្រុងនូវលទ្ធភាពដែលថា សេចក្តីសម្រេចដែលចេញដោយចៅក្រម ឬអង្គជំនុំជម្រះខ្លួនឯងផ្ទាល់ អាចគ្រប់

[107] *សូមមើលឧទាហរណ៍* ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចៅក្រម កថាខណ្ឌ ៧៩, ៨១, ៨៤, ៩២, ១០៤, ១០៥។

[108] *សូមមើ* ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក") មាត្រា ៣៦ថ្មី ("តុលាការកំពូលពិនិត្យសម្រេច ជាចុងក្រោយទាំងអង្គហេតុ ទាំងអង្គច្បាប់")។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មទី៩) ដូចដែលត្រូវបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង") វិធាន ១១១(៦) ("ក្នុងករណីដែលបណ្តឹងសាទុក្ខត្រូវបានបដិសេធ នោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវចូលជាស្ថាពរ និងមិនអាចតវ៉ាបានទៀតឡើយ")។

[109] *សូមមើលឧទាហរណ៍* ឯកសារ **E314/12/1** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម អ.ជ.ស.ដ សំណុំរឿង ០០២/០២ កថាខណ្ឌ ៣៥ ។ *សូមមើលឧទាហរណ៍* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ១១២។ សាលដីកា *Furundžija* កថាខណ្ឌ ១៩៦-១៩៧។ *Norman*, SCSL-2004-14-PT, សេចក្តីសម្រេចលើបណ្តឹងប្តឹងជំទាស់ចៅក្រម Winter ចេញពីការពិភាក្សាក្នុងញត្តិបឋមស្តីពីការជ្រើសរើសទាហានជាកុមារ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ កថាខណ្ឌ២៥។

[110] **E314/12/1** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ៣៦ *បានដកស្រង់ Bagosora និងគូកន.*, ICTR-98-41-T, សេចក្តីសម្រេចលើញត្តិប្តឹងជំទាស់ចៅក្រម, តុលាការ ICTR Bureau ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៧ ("សេចក្តីសម្រេចលើបណ្តឹងជំទាស់ក្នុងរឿងក្តី *Bagosora*") កថាខណ្ឌ៧។

គ្រាន់ដើម្បីបង្ហាញពីភាពលម្អៀងជាក់ស្ដែងនោះ *វាគឺជាករណីវិសាមញ្ញដែលសេចក្ដីសម្រេចទាំងនោះអាចមាន*"[111]។

40. ខណៈដែលផ្អែកលើសាលដីកាបណ្ដឹងសាទុក្ខនៃសំណុំរឿង០០២/០១ ខ្លួនវាផ្ទាល់[112] ខៀវ សំផន មើលមិនឃើញថា អ.ជ.ត.ក បានច្រានចោលការចោទប្រកាន់របស់ នួន ជា អំពីភាពលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីកំហុសដែលបានចោទប្រកាន់ក្នុងសាលក្រមសំណុំរឿង០០២/០១ ដោយសម្អាងលើមូលហេតុច្បាស់លាស់ទាំងអស់នេះ៖

> [អ.ជ.ត.ក] ពុំជឿជាក់ថា ឧទាហរណ៍ដែល នួន ជា បានដកស្រង់ កង្វះភាពអនាគតិនោះទេ ហើយក៏ពុំមែនជាកំហុសអង្គហេតុ ឬអង្គច្បាប់ដែរ។ ភាគីដែលធ្វើបណ្ដឹងជំទាស់លើសច្ចធាណ៍នៃភាពអនាគតិរបស់ចៅក្រម មាន *បន្ទុកត្រូវបង្ហាញភស្តុតាងក្នុងកម្រិតខ្ពស់*"[113]។

41. ការអះអាងជាច្រើនរបស់ ខៀវ សំផន ថា កំហុសដែលត្រូវបានចោទប្រកាន់ទាំងបួននោះ បង្ហាញនូវភាពលម្អៀង និង/ឬ ការស្ដែងចេញនូវភាពលម្អៀង ដោយសារតែវាតំណាងឱ្យផ្លូវតែមួយគត់សម្រាប់ អ.ជ.ត.ក ធានាបាននូវការផ្ដន្ទាទោសក្នុងសំណុំរឿង០០២/០១[114] គឺមិនត្រូវបានគាំទ្រដោយភស្តុតាងសត្យានុម័តណាមួយឡើយ និងបានដាក់បញ្ចូលគ្នាខុសទំនងនូវការផ្ដន្ទាទោសជនជាប់ចោទម្នាក់ផ្អែកលើការអនុវត្តច្បាប់ដ៏ត្រឹមត្រូវចំពោះភាពលម្អៀង។ ជាងនេះទៀត កុំថាឡើយអង្គហេតុដែលថាចៅក្រមដែលរងការប្ដឹងជំទាស់ ធ្លាប់បានតម្កល់ការផ្ដន្ទាទោសប្រឆាំងនឹង ខៀវ សំផន និងកុំថាឡើយការបារម្ភដ៏សមហេតុផល ថាពួកគេអាចសម្រេចលើបញ្ហាច្បាប់តាមវិធីដដែលនាពេលអនាគតនោះ ក៏វាមិនអាចបដិសេធសច្ចធារណ៍នៃភាពអនាគតិដ៏ខ្ពស់បំផុតបានទេ[115]។

---

[111] *Blagojević និងគូកន*, IT-02-60, សេចក្ដីសម្រេចលើសំណើរបស់ Blagojević អនុលោមតាមវិធាន ១៥(ខ), តុលាការ ICTY Bureau ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ ១៤ (គូសបញ្ជាក់បន្ថែម) *ត្រូវបានយោងដោយមានអនុញ្ញាត* នៅក្នុងសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ក្នុងរឿងក្ដី *Bagosora* កថាខណ្ឌ១០។

[112] **F53** សំណើសុំប្ដឹងជំទាស់ កថាខណ្ឌ ៧៧ *បានដកស្រង់* ឯកសារ **F36** សាលដីកា សំណុំរឿង០០២/០១ កថាខណ្ឌ ១១២។

[113] **F36** សាលដីកា សំណុំរឿង០០២/០១ កថាខណ្ឌ ១១២ (គូសបញ្ជាក់បន្ថែម)។

[114] **F53** សំណើសុំប្ដឹងជំទាស់ កថាខណ្ឌ ៧៩, ៨៤, ៨៩, ៩១-៩២, ១០៥។ *សូមមើលផងដែរ* ឯកសារ **E457/6/4/1** សេចក្ដីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន (០០២/០២) ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ វិសោធនកម្ម ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ ("សេចក្ដីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន") កថាខណ្ឌ ៣៥០, ៤០៣។

[115] ឯកសារ **E314/12/1** សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ៦០-៦៤, ៧៣ និងការដកស្រង់យោងខាងក្នុងនោះ។

42. នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ សេចក្តីអះអាងរបស់ ខៀវ សំផន ដែលថា អ.ជ.ត.ក ត្រូវបាន កំណត់ដើម្បីឲ្យ "កែបំភ្លៃច្បាប់"[116] ក្នុងគោលបំណងដើម្បីធានាការកាត់ឲ្យជាប់ទោសរបស់គាត់ ត្រូវបានគេជឿដោយការរកឃើញផ្សេងៗទៀតនៅក្នុងសាលដីកាក្នុងសំណុំរឿង០០២/០១។ "បុគ្គល ម្នាក់ដែលបានទទួលព័ត៌មានគ្រប់គ្រាន់អំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់"[117] បានដឹងថា អង្គជំនុំ ជម្រះនេះ ក៏បានបដិសេធការរកឃើញខាងអង្គហេតុ និងអង្គច្បាប់ របស់អង្គជំនុំជម្រះសាលាដំបូង មួយចំនួនប្រឆាំងនឹង ខៀវ សំផន ផងដែរ។ ជាឧទាហរណ៍ អ.ជ.ត.ក បានបដិសេធការ រកឃើញខាងអង្គច្បាប់មួយចំនួន ពាក់ព័ន្ធនឹងការចូលរួមចំណែករបស់ ខៀវ សំផន នៅក្នុងគោល ដៅរួម[118] និងបានរកឃើញនូវកំហុសឆ្គងនានានៅក្នុងរបកគំហើញជាក់លាក់នៃឧក្រិដ្ឋកម្មដែលបាន ប្រព្រឹត្តនៅក្នុងកំឡុងពេលនៃការផ្លាស់ប្តូរទីលំនៅប្រជាជនលើកទី I និងលើកទី II[119]។ គេលើក ឡើងថា បំណងឧក្រិដ្ឋចំពោះការសម្លាប់រង្គាលនៅក្នុងការពេញចិត្តរបស់ ខៀវ សំផន[120] នាំឲ្យមាន ការបដិសេធចំពោះការកាត់ឲ្យជាប់ទោសស្តីពីការសម្លាប់រង្គាល ទាក់ទងទៅនឹងការផ្លាស់ប្តូរទី លំនៅប្រជាជនលើកទី I និងលើកទី II[121]។ ចុងបញ្ចប់ ខ្លួនបានបដិសេធការរកឃើញនានា របស់ អង្គជំនុំជម្រះសាលាដំបូង ស្តីពីអត្ថិភាពនៃគោលនយោបាយមួយដែលសញ្ជឹងគិតដល់ការសម្លាប់ ពួកទាហាន និងពួកមន្ត្រីផ្លូវការនៃសាធារណរដ្ឋខ្មែរ នៅពេលដែលមានព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ដែលបណ្តាលឲ្យមានការរួចខ្លួនពីគ្រប់បទចោទទាំងអស់ប្រឆាំងនឹង ខៀវ សំផន ចំពោះទីកន្លែង សម្លាប់នោះ[122]។

43. ការប្រើពាក្យសំដីខុសឆ្គងដូចគ្នាដែរ គឺសេចក្តីអះអាងរបស់ ខៀវ សំផន ដែលថា ការខកខានរបស់ អ.ជ.ត.ក មិនបានកាត់បន្ថយការកាត់ឲ្យជាប់ទោសអស់មួយជីវិត នៅក្នុងសំណុំរឿង០០២/០១

---

[116] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ កថាខណ្ឌ ៧៩។

[117] *សូមមើល ខាងលើ* កថាខណ្ឌ ១០។ សូមមើលផងដែរ កថាខណ្ឌ ៣៨-៣៩។

[118] *សូមមើល ឧទា.* ឯកសារ **F36** សាលដីកា សំណុំរឿង០០២/០១ កថាខណ្ឌ ១០០៩, ១០២៣, ១០៨០ (បានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងនៅក្នុងការរកឃើញថា ខៀវ សំផន (i) បានចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិម នៅខែមិថុនា ឆ្នាំ១៩៧៤ ដែលនៅក្នុងនោះ ពួកអ្នកចូលរួមប្រជុំបានសម្រេចផែនការជម្លៀសភ្នំពេញ, (ii) បានធ្វើសុន្ទរកថា សម្ពោធនៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៦, និង (iii) បានដឹកនាំប្រជុំសភាជាតិពិសេសមួយ ព្រោះហេតុដូច្នោះហើយ បានគាំទ្រ ការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងកំឡុងពេលផ្លាស់ប្តូរទីលំនៅប្រជាជនលើកទី II)។

[119] *សូមមើល ឧទា.* ឯកសារ **F36** សាលដីកា សំណុំរឿង០០២/០១ កថាខណ្ឌ ៤៣៦, ៤៤៨, ៤៥៤, ៤៧១-៤៧២, ៤៨៣។

[120] ឯកសារ **F36** សាលដីកា សំណុំរឿង០០២/០១ កថាខណ្ឌ ៥២២។

[121] ឯកសារ **F36** សាលដីកា សំណុំរឿង០០២/០១ កថាខណ្ឌ ៥៤១, ៥៦០ និង ផ្នែកសម្រេចសេចក្តី។

[122] ឯកសារ **F36** សាលដីកា សំណុំរឿង០០២/០១ កថាខណ្ឌ ៩៧២ និង ផ្នែកសម្រេចសេចក្តី។

ដោយមានទាក់ទងនឹងការដោះលែងទាំងនេះ បានបកស្រាយបង្ហាញពីភាពលំអៀង[123]។ ដូចដែល អ.ជ.ត.ក បានពន្យល់ដូច្នោះដែរ ការកាត់ឱ្យជាប់ទោសអស់មួយជីវិតរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាការផ្តន្ទាទោសរួម ទាក់ទងទៅនឹងការកាត់ឱ្យជាប់ទោសទាំងអស់ដោយមិនបានបញ្ជាក់ពីការផ្តន្ទាទោសជាក់លាក់ចំពោះឧក្រិដ្ឋកម្មនីមួយៗ[124]។ ដោយហេតុថា ការដាក់ពន្ធនាគារអស់មួយជីវិត គឺជាការផ្តន្ទាទោសអតិបរមាដែលអាចមាននៅ អ.វ.ត.ក[125] វានៅតែអាចសមហេតុសមផលនៅឡើយដែលត្រូវបានធ្វើយុត្តិកម្មដោយការកាត់ឱ្យជាប់ទោសនានាដែលនៅសល់ ហើយការដោះលែងឱ្យរួចខ្លួន មិនតម្រូវជាស្វ័យប្រវត្តិឱ្យមានការបន្ធូរបន្ថយទោសនោះទេ។ នៅក្នុងសំណុំរឿងនេះ អ.ជ.ត.ក បានយកមករំឭកយ៉ាងត្រឹមត្រូវថា ការផ្តន្ទាទោសមួយត្រូវតែឆ្លុះបញ្ចាំងនូវភាពធ្ងន់ធ្ងរដែលមាននៅជាប់ជាមួយនឹងទង្វើប្រព្រឹត្តឧក្រិដ្ឋកម្ម[126] ហើយបន្ទាប់ពីការវិភាគយ៉ាងហ្មត់ចត់មកបានរកឃើញថា ការដោះលែងឱ្យរួចខ្លួននានាមានផលប៉ះពាល់បន្តិចបន្តួចទៅលើជនរងគ្រោះទូទៅមួយចំនួន ដែលនៅក្នុងនោះ ខៀវ សំផន ត្រូវទទួលខុសត្រូវ ដែលជាផលប៉ះពាល់យូរអង្វែងនៃឧក្រិដ្ឋកម្មចំពោះជនរងគ្រោះ និងវិសាលភាពពេលវេលានៃឧក្រិដ្ឋកម្ម។ តួនាទីដ៏សំខាន់របស់ ខៀវ សំផន នៅក្នុងឧក្រិដ្ឋកម្ម និងកង្វះខាតទាំងស្រុងរបស់គាត់ក្នុងការពិចារណាពីវាសនាចុងក្រោយរបស់ប្រជាជនកម្ពុជា ជាពិសេសក្រុមនានាដែលងាយរងគ្រោះបំផុត ក៏ស្រដៀងគ្នានេះដែរ គឺនៅតែមិនផ្លាស់ប្តូរជាដដែល[127]។

44. លើសពីនេះទៀត ការអនុវត្តឆន្ទានុសិទ្ធិរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿងនេះ គឺទៀងទាត់ដោយមានការបង្ហាញពីចៅក្រមសាលាឧទ្ធរណ៍នៅតុលាការព្រហ្មទណ្ឌផ្សេងៗទៀត។ ជាឧទាហរណ៍ នៅ

---

[123] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ កថាខណ្ឌ ៩៣, ១០៦។

[124] ឯកសារ **F36** សាលដីកា សំណុំរឿង០០២/០១ កថាខណ្ឌ ១១១៧។ *សូមមើល ផងដែរ* ឯកសារ **E313** សាលក្រម សំណុំរឿង០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ (“សាលក្រម សំណុំរឿង០០២/០១”) កថាខណ្ឌ ១០៧២។

[125] ច្បាប់ អ.វ.ត.ក មាត្រា ៣៩។

[126] ឯកសារ **F36** សាលដីកា សំណុំរឿង០០២/០១ កថាខណ្ឌ ១១១៨។ នៅក្នុងកថាខណ្ឌដដែលនេះ វាត្រូវបានយកមករំឭកយ៉ាងត្រឹមត្រូវថា ដូចដែល អ.ជ.ត.ក មាននៅក្នុងសំណុំរឿង០០១ (សំណុំរឿង០០១-ឯកសារ **F28** សាលដីកាចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ (“សាលដីកា *ឌុច*”) កថាខណ្ឌ ៣៧៥) ដែលភាពធ្ងន់ធ្ងរនៃទង្វើប្រព្រឹត្តត្រូវបានវាយតម្លៃដោយទាក់ទងនឹង *ក្នុងចំណោមនោះ* ចំនួន និងភាពងាយរងការឈឺចាប់របស់ជនរងគ្រោះ ផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើពួកគាត់ និងក្រុមគ្រួសាររបស់ពួកគាត់ ចេតនារើសអើងនៃបុគ្គលដែលបានកាត់ឱ្យជាប់ទោសនៅពេលដែលការណ៍នេះមិនទាន់ជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មនៅឡើយ។ វិសាលភាព និងអំពើឃោរឃៅនៃបទល្មើសនានា និងតួនាទីដែលបានដើរតួដោយបុគ្គល ដែលត្រូវបានកាត់ឱ្យជាប់ទោស។

[127] ឯកសារ **F36** សាលដីកា សំណុំរឿង០០២/០១ កថាខណ្ឌ ១១២០។

ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍តម្កល់ការកំណត់ទោសមួយជីវិតសម្រាប់ *Tolimir*[128], *Popović*[129] និង *Beara*[130] បើទោះបីជាមានការលើកលែងឱ្យពួកគេ រួចខ្លួនពីបទចោទសំខាន់ៗមួយចំនួន - ដោយមានមូលដ្ឋាននៅលើភាពធ្ងន់ធ្ងរនៃការកាត់ទោសដែលនៅសេសសល់។

45. ជាសេចក្តីសន្និដ្ឋាន សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើសុំប្តឹងជំទាស់ចិត្តចៅក្រមរបស់ ខៀវ សំផន ដែលមានមូលដ្ឋាននៅលើកំហុសឆ្គងដែលបានលើកឡើងចោទប្រកាន់ចំនួនបួននេះ ត្រូវតែបដិសេធចោល។ វាកំពុងអនុវត្តនូវកិច្ចដំណើរការនីតិវិធីមួយដែលរារាំងនូវបណ្តឹងឧទ្ធរណ៍ក្លែងបន្លំមួយ ថាដូចជា សំណើសុំប្តឹងជំទាស់ចិត្ត ដែលនៅក្នុងនោះ ខៀវ សំផន គិតថាដូចគ្នាដោយខុសឆ្គងនូវកំហុសអង្គច្បាប់ដែលបានអះអាង ជាមួយនឹងភាពលំអៀង។ នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ ការអះអាងរបស់ ខៀវ សំផន ពីកំហុសឆ្គង (និង ហេតុដូច្នេះ គឺភាពលំអៀង) គឺជាការប្រើពាក្យសំដីខុសឆ្គងដូចដែលសហព្រះរាជអាជ្ញាកំណត់ដោយត្រួសៗនៅខាងក្រោមនេះ។ ដូចដែលបានរំពឹងទុកជាមុន សហព្រះរាជអាជ្ញា សូមរក្សាសិទ្ធិក្នុងការពង្រីកនូវសេចក្តីសន្និដ្ឋានទាំងនេះ ប្រសិនបើមានបញ្ហាដូចគ្នាខ្លះ ត្រូវបានលើកឡើងម្តងទៀតនៅក្នុងបណ្តឹងឧទ្ធរណ៍នៃសំណុំរឿង០០២/០២។

*i. គោលការណ៍នីត្យានុកូលភាព*

46. ការចោទប្រកាន់របស់ ខៀវ សំផន ទាក់ទងនឹងការសម្រេចរបស់ អជតក ស្តីពីគោលការណ៍នីត្យានុកូលភាពនៅក្នុងសំណុំរឿង០០២/០១[131] គឺពោរពេញទៅដោយការយល់ច្រឡំ ទាំងការសម្រេច

---

[128] *Tolimir* សំណុំរឿងលេខ IT-05-88/2-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥ កថាខណ្ឌ ២១៥, ២១៧-២១៩, ២៣៣-២៣៥, ២៣៧, ២៦៦-២៦៨, ២៧០, ២៧២ (ដោយបានបដិសេធការកាត់ឱ្យជាប់ទោសមួយចំនួនរបស់ Tolimir ចំពោះអំពើប្រល័យពូជសាសន៍) ៦៤៨ ("ការកាត់ឱ្យជាប់ទោសដែលនៅសេសសល់របស់ Tolimir ជាពិសេសចំពោះអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តក្នុងរយៈកាលនៃការសម្លាប់ពួកបុរសពី Srebrenica និងក្នុងរយៈកាលនៃការធ្វើឱ្យឈឺចាប់ខាងរាងកាយយ៉ាងធ្ងន់ធ្ងរ ឬការខូចខាតខាងសតិបញ្ញាចំពោះប្រជាជនមូស្លីមបូស្នីនៃ Srebrenica ដែលត្រូវបានទទួលរង។ ទាក់ទងទៅនឹងការកាត់ឱ្យជាប់ទោសពីអំពើប្រល័យពូជសាសន៍តែឯងនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ពិចារណាថា ការទទួលខុសត្រូវរបស់ Tolimir មិនធានាការពិនិត្យឡើងវិញពីការផ្តន្ទាទោសរបស់គាត់ទេ។ នៅក្នុងកាលៈទេសៈនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានបញ្ជាក់ពីការផ្តន្ទាទោសរបស់ Tolimir ថាដាក់ក្នុងពន្ធនាគារអស់មួយជីវិត")។

[129] *Popović និងគូកន* សំណុំរឿងលេខ IT-05-88-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ("សាលដីការបស់ *Popović*") កថាខណ្ឌ ៥៤៥, ៥៤៦, ៥៥៧, ១០៦៥, ១០៦៨, ១០៦៩-១០៧០, ១៤៤៤, ២១១០។

[130] សាលដីការបស់ *Popović* កថាខណ្ឌ ៥៥៤, ៥៥៥, ៥៥៧, ១០៥៩, ១០៦៥, ១០៦៨, ១០៦៩, ១៤៤៤, ២១១១។

[131] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត, កថាខណ្ឌ ៨០-៨១។ ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ ៣៣១-៣៨០។

និងទាំងសាលក្រមរបស់ អជតក ក្នុងសំណុំរឿង០០១ ដែលពួកគេគួរតែបានដាកចេញ។ លើសពីនេះ ខៀវ សំផន មើលរំលងចំពោះភាពស៊ីចង្វាក់គ្នារវាងសាលដីកាក្នុងសំណុំរឿង០០២/០១ និងបទដ្ឋាន ដែលបានបង្កើតដោយ អបជ និងអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY។ ការសម្រេច របស់ អជតក មិនមានកំហុសទេ ហើយក៏មិនលំអៀងដែរ។

47. ទីមួយ ផ្ទុយពីការអះអាងរបស់ ខៀវ សំផន អជតក នៅក្នុងសំណុំរឿង០០២/០១ *មិនបាន* សម្រេច ថា "វាមានលក្ខណៈគ្រប់គ្រាន់ថា ឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវនានាដែលបានកើតឡើង នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងពេលនៃព្រឹត្តិការណ៍ និងថាជនជាប់ចោទបានកាន់មុខ តំណែងជាន់ខ្ពស់នោះទេ"[132]។ ដូចគ្នានឹងសំណុំរឿង០០១ ដែរ អជតក ក្នុងសំណុំរឿង០០២/០១ បាន សម្រេចថា ឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវនានាត្រូវតែ (i) បានមានកើតឡើងមិនថានៅ ក្រោមច្បាប់ជាតិ ឬអន្តរជាតិ និង (ii) មានលទ្ធភាពទទួលបាន/ដឹងបាន និងអាចព្យាករណ៍បាន ចំពោះជនជាប់ចោទនៅពេលនោះអំពីទង្វើព្រហ្មទណ្ឌដូចបានចោទប្រកាន់[133]។ អង្គជំនុំជម្រះនេះបាន *យល់ស្រប* ជាមួយនឹងការសន្និដ្ឋានរបស់ ខៀវ សំផន ថា "លក្ខខណ្ឌតម្រូវអំពីភាពអាចព្យាករណ៍ បាន និងភាពអាចទទួលបាន/ដឹងបាន ត្រូវបានកំណត់តាមរយៈការវិភាគបែបសត្យានុម័ត គឺមានន័យ ថា ឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវនានាត្រូវតែអាចមានលទ្ធភាពទទួលបាន/ដឹងបាន និង អាចព្យាករណ៍បានជាទូទៅ"[134] ប៉ុន្តែបានរកឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសក្នុង ការលើកយកមុខតំណែងរបស់ ខៀវ សំផន មកពិចារណាឡើយ ពេលធ្វើការកំណត់ថាតើគោល ការណ៍នីត្យានុកូលភាពត្រូវបានប្រកាន់យកដែរ ឬអត់នោះ គឺគ្រាន់តែដូចគ្នា អ.ជ.ត.ក បានធ្វើនៅក្នុង សំណុំរឿង០០១ តែប៉ុណ្ណោះ[135]។

48. ជាងនេះទៀត ការសម្រេចក្នុងសំណុំរឿង០០២/០១ របស់ អជតក ទាក់ទងនឹងតេស្តសាកល្បង សម្រាប់ "*ភាពអាចទទួលបាន/ដឹងបាន*" និង "*ភាពអាចព្យាករណ៍បាន*" គឺស្របគ្នាទាំងស្រុងជាមួយ នឹងភាពអាចទទួលបាន/ដឹងបាន និងភាពអាចព្យាករណ៍បាន ដែលបានធ្វើឡើងដោយអង្គជំនុំជម្រះ

---

[132] ឯកសារ **F53** សំណើសុំប្តឹងឧទ្ធរណ៍, កថាខណ្ឌ ៨០។

[133] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៧៦១-៧៦២។ ប្រៀបធៀបនឹងសំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច កថាខណ្ឌ ៩១, ៩៦-៩៧។

[134] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦១។

[135] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦១ *យោង* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច កថាខណ្ឌ ២៨០។

អជតក ក្នុងសំណុំរឿង ០០១។ ការរកឃើញក្នុងសំណុំរឿង ០០២/០១ ដែលថា "ចំពោះលក្ខខណ្ឌតម្រូវនៃភាពអាចទទួលបាន/ដឹងបាន ជាការបន្ថែមទៅលើសន្និសញ្ញានានា 'ច្បាប់នានាដែលផ្អែកទៅលើទម្លាប់ [...] អាចអាស្រ័យបានថា ជនជាប់ចោទដែលអាចរកបានយ៉ាងគ្រប់គ្រាន់នោះ" គឺបានផ្អែកទៅលើការដកស្រង់ដោយផ្ទាល់មួយចេញពីសាលដីកាក្នុងសំណុំរឿង០០១ ដែលត្រូវបានគាំទ្រដោយយុត្តិសាស្ត្ររបស់តុលាការ ICTY[136]។

49. ចំពោះពាក្យថា ភាពអាចព្យាករណ៍បាន ខៀវ សំផន បានពិពណ៌នាទាំងខុសចំពោះការសម្រេចក្នុងសំណុំរឿង០០២/០១ របស់ អជតក ដែលថាជនជាប់ចោទ "ត្រូវតែមានលទ្ធភាពបំពេញបានថា ទង្វើនោះ គឺពិតជាអំពើព្រហ្មទណ្ឌ ក្នុងន័យដែលគេអាចយល់បានជាទូទៅដោយពុំចាំបាច់មានការយោងទៅរកបទប្បញ្ញត្តិជាក់លាក់ណាមួយឡើយ" ទុកដូចជាការងាកចេញពីយុត្តិសាស្ត្រអតីតកាលរបស់អជតក។[137] តាមពិត ក្នុងការធ្វើការសម្រេចនេះក្នុងសំណុំរឿង ០០២/១ អជតក បានយោងយ៉ាងច្បាស់ក្រឡែតទៅរកការសម្រេចពីមុន*ដូចគ្នាបេះបិទ* ស្ដីពីអត្ថន័យនៃពាក្យ "អាចព្យាករណ៍បាន" ក្នុងសំណុំរឿង ០០១[138]។ ខៀវ សំផន មិនបានផ្ដល់ការពន្យល់ថាតើនិយមន័យណាមួយផ្សេងទៀតនៃពាក្យ "ភាពអាចព្យាករណ៍បាន" នឹងត្រូវអនុវត្តចំពោះសេចក្ដីសម្រេចនៅក្នុងសំណុំរឿង ០០១ ដែល

---

[136] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៧៦២ *យោង* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ ៩៦។ *Hadžihasanović និងគូកន* IT-01-47-AR72 សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្អំដែលតវ៉ាអំពីយុត្តាធិការទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ ("សាលដីកាសម្រេចស្ដីពីការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងរឿងក្ដី *Hadžihasanović*]") កថាខណ្ឌ ៣៤។ *Milutinović និងគូកន* IT-99-37-AR72, សាលដីកាសម្រេចលើញត្តិរបស់ Dragoljub Ojdanić តវ៉ាអំពីយុត្តាធិការ - *សហកម្មឧក្រិដ្ឋកម្មរួម,* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ ("សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ Ojdanić"), កថាខណ្ឌ ៤០។

[137] ឯកសារ **F53** សំណើសុំប្ដឹងជំទាស់ចិត្ត, កថាខណ្ឌ ៨០-៨១។ *សូមមើលផងដែរ* ឯកសារ **E457/6/4/1** សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន, កថាខណ្ឌ ២៣៤ ("[អជតក ក្នុងសំណុំរឿង ០០២/០២] គ្រាន់តែបានយោងសេចក្ដីសម្រេចមួយរបស់តុលាការ ICTY ដែលថ្លែងដោយឥតអៀនខ្មាស់ និងគ្មានយោងបទប្បញ្ញត្តិណាមួយនោះថា ភាពអាចព្យាករណ៍បាន [...] [ជនជាប់ចោទ] ត្រូវតែមានលទ្ធភាពអាចបំពេញបានថា ទង្វើប្រព្រឹត្តនោះគឺជាអំពើព្រហ្មទណ្ឌក្នុងន័យដែលគេអាចយល់បានជាទូទៅ ដោយពុំចាំបាច់យោងទៅរកបទប្បញ្ញត្តិជាក់លាក់ណាមួយឡើយ")។ ខៀវ សំផន យោង ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៧៦២, កំណត់សម្គាល់ជើងទំព័រ ១៩៨៣ "យោង [សាលដីកាសម្រេចស្ដីពីការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងរឿងក្ដី *Hadžihasanović*], កថាខណ្ឌ ៣៤" ខណៈកំណត់សម្គាល់ជើងទំព័រ ១៩៨៣ នេះក៏យោងសំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ ៩៦, ៣៥០-៣៥១ ផងដែរ។

[138] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៧៦២ *យោង* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ ៩៦។ សាលដីកាសម្រេចស្ដីពីការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងរឿងក្ដី *Hadžihasanović*, កថាខណ្ឌ ៣៤។

ថា "ការសម្រេចស្តីពីធាតុផ្សំនៃបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវ [...] ត្រូវតែអាចព្យាករណ៍បាន និងមានលទ្ធភាពទទួលបាន/ដឹងបានចំពោះជនជាប់ចោទ"[139] នោះទេ។

50. ជាចុងក្រោយ ខៀវ សំផន មើលរំលងថា លក្ខណវិនិច្ឆ័យនៃភាពអាចព្យាករណ៍បាន និងលទ្ធភាពអាចទទួលបាន/ដឹងបាន ដែលបានអនុម័តដោយ អជតក ក៏បានគាំទ្រយ៉ាងប្រសើរចំពោះសាលដីកាក្នុងសំណុំរឿង ០០២/០១ ទាំងដោយយុត្តិសាស្ត្ររបស់ អបជ[140] និងទាំងរបស់តុលាការ ICTY[141]។ លក្ខណវិនិច្ឆ័យទាំងនោះ ក៏ស៊ីចង្វាក់គ្នាជាមួយនឹងគោលការណ៍ដែលបានបង្កើតឡើងយ៉ាងល្អដែលថា គោលការណ៍នីត្យានុកូលភាពអន្តរជាតិមិនហាមឃាត់តុលាការណាមួយមិនឱ្យបកស្រាយ និងធ្វើការបញ្ជាក់បំភ្លឺពីបញ្ញាច្បាប់ ឬមិនឱ្យពឹងផ្អែកទៅលើសេចក្តីសម្រេចទាំងឡាយដែលបានធ្វើឡើងនៅក្នុងករណីផ្សេងៗទៀតនោះឡើយ[142]។ ក្នុងការរិះគន់ អជតក ចំពោះការរកឃើញក្នុងសំណុំរឿង ០០២/០១ ថា ឧក្រិដ្ឋកម្មនានាមានលក្ខណៈធ្ងន់ធ្ងរដែលស្ទើរតែមិនអាចជឿបានថា ខៀវ សំផន មិនយល់ថាទង្វើរបស់គាត់មិនមែនជាអំពើព្រហ្មទណ្ឌ "ក្នុងន័យដែលគេអាចយល់បានជាទូទៅនោះ"[143] ស្រដៀងគ្នានេះ គឺគាត់ខកខានក្នុងការទទួលស្គាល់ថា អង្គជំនុំជម្រះផ្សេងទៀតរបស់ អ.វ.ត.ក និងតុលាការ ICTY បានអនុវត្តតាមការផ្តល់សម្អាងហេតុដូចគ្នាទាក់ទងនឹងទង្វើប្រព្រឹត្តស្រដៀងគ្នា[144]។

---

[139] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត, កថាខណ្ឌ ៨០ *យោង* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ ៩៧។

[140] ឯកសារ **D427/2/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, អ.ប.ជ, ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ("សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ នួន ជា និង អៀង ធីរិទ្ធ") កថាខណ្ឌ ១០៦។ ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, អ.ប.ជ, ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ("សាលដីកាលើសម្រេចបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ អៀង សារី") កថាខណ្ឌ ២៣៥។ឯកសារ **D97/14/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE), អ.ប.ជ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ("សាលដីកាស្តីពី JCE") កថាខណ្ឌ ៤៥។

[141] សាលដីកាសម្រេចស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងរឿងក្តី *Hadžihasanović*, កថាខណ្ឌ ៣៤។

[142] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ ៩៥។ *Aleksovski*, IT-95-14/1-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ១២៦-១២៧។ *រឿងក្តី Kononov ទល់នឹងប្រទេសឡាតវីយ៉ា* លេខ 36376/04 សាលដីកា អង្គជំនុំជម្រះខ្នាតធំ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ១៨៥ និងសេចក្តីយោងនៅក្នុងនោះ។

[143] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ ៨០ *យោង* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៧៦២។

[144] *សូមមើល ជាឧទាហរណ៍* សំណុំរឿង០០១-ឯកសារ **F28** សាលដីកា ឌុច កថាខណ្ឌ ៩៦។ ឯកសារ **D427/2/15** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ នួន ជា និង អៀង ធីរិទ្ធ កថាខណ្ឌ ១០៦។ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីយុត្តាធិការក្នុងរឿងក្តី *Ojdanić*, កថាខណ្ឌ ៤២។

### *ii. ធាតុផ្សំអត្តនោម័តសម្រាប់អំពើមនុស្សឃាតក្នុងរូបភាពជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

51. ការអះអាងរបស់ ខៀវ សំផន[145] ទាក់ទងនឹងការសន្និដ្ឋានរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០២/០១ ថា *ធាតុផ្សំអត្តនោម័ត* នៃអំពើមនុស្សឃាតរួមបញ្ចូល *ចេតនាប្រព្រឹត្ត* ខកខានមិនបានបង្ហាញពីកំហុសនោះទេ កុំថាឡើយបំពេញបានបទដ្ឋាននៃការបង្ហាញភ័ស្តុតាងខ្ពស់បំផុតដែលត្រូវការដើម្បីបង្ហាញពីភាពលម្អៀង និង/ឬ ការស្តែងចេញនូវភាពលម្អៀង។ មិនមានត្រង់ណានៅក្នុងសារណារបស់ ខៀវ សំផន បង្ហាញថា ការវិភាគប្រកបដោយសម្អាងហេតុគ្រប់ជ្រុងជ្រោយរបស់ អ.ជ.ត.ក ដែលបានធ្វើឡើងក្នុងការពិចារណាលើបណ្តឹងសាទុក្ខផ្ទាល់របស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០១[146] ជាលទ្ធផលនៃបុរេវិនិច្ឆ័យរបស់ចៅក្រមដែលរងការប្តឹងជំទាស់ប្រឆាំងនឹង ខៀវ សំផន ផ្ទុយទៅនឹងការអនុវត្តច្បាប់ដោយសុក្រិត្យ "ដែលអាចបកស្រាយបានច្រើនរបៀប"[147]។

52. ទីមួយ ការអះអាងរបស់ ខៀវ សំផន អំពីភាពលម្អៀង ត្រូវបានធ្វើឲ្យចុះខ្សោយទាំងមូលដោយអង្គហេតុដែលថា មិនមានត្រង់ណានៅក្នុងសំណើសុំប្តឹងជំទាស់ចៅក្រមរបស់គាត់ ឬសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលសំណុំរឿង០០២/០១ គាត់បានដកស្រង់ឯកសារយោង*ណាមួយ*សម្រាប់ការអះអាងរបស់គាត់ ដែលការចោទប្រកាន់របស់គាត់អំពីភាពលម្អៀងត្រូវបានផ្អែកលើ ថាធាតុផ្សំអត្តនោម័តនៃអំពើមនុស្សឃាតគឺជា "ចេតនាដោយផ្ទាល់ក្នុងការសម្លាប់"[148]។

53. ខៀវ សំផន ក៏បានមើលរំលងភាពស៊ីចង្វាក់គ្នារវាងការរកឃើញរបស់សាលដីកាសំណុំរឿង ០០២/០១ និងការសម្រេចរបស់អង្គជំនុំជម្រះ អ.វ.ត.ក ក្នុងសំណុំរឿង០០១[149] ក៏ដូចជាតុលាការ

---

[145] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចៅក្រម កថាខណ្ឌ៨២-៨៤។ ឯកសារ **E457/6/4/1** សារណាបិទកិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ៣៩៤-៤២៩។

[146] *សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ៣៨៧-៣៨៨, ៤១០។

[147] ឯកសារ **E314/12/1** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ៣៦។ ឯកសារ **E55/4** សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ១៣។

[148] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចៅក្រម កថាខណ្ឌ៨៣-៨៤។ ឯកសារ **E457/6/4/1** សារណាបិទកិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ៣៩៥, ៤០៤-៤០៥, ៤២៥។

[149] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ៣៣២-៣៣៤ *ដកស្រង់* សំណុំរឿង០០១-ឯកសារ **E188** សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("សាលក្រម *ឌុច*") កថាខណ្ឌ ៣៣៣ ('ចេតនាសម្លាប់ ឬបង្កឲ្យមានរបួសធ្ងន់ធ្ងរលើរូបរាងកាយធ្ងន់ធ្ងរ ដោយមានហេតុផលដឹងថា អំពើសកម្ម ឬអកម្មនេះ មុខជានាំឲ្យមានការបាត់បង់ជីវិតមនុស្ស' (*ធាតុផ្សំអត្តនោម័ត*)")។

*មិនអចិន្ត្រៃយ៍*ផងដែរ[150]។ អង្គជំនុំជម្រះ និងតុលាការទាំងអស់នេះបានបង្ហាញថា ចេតនាផ្ទាល់ក្នុងការសម្លាប់ *មិន* ចាំបាច់ទេនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ហើយទាំងអស់នេះអនុម័តទម្រង់ដូចគ្នា ដែលត្រូវបានអនុម័តដោយសាលក្រមសំណុំរឿង០០២/០១[151] ដែល អ.ជ.ត.ក បានតម្កល់[152]។ តុលាការ*មិនអចិន្ត្រៃយ៍*ធ្វើការវាយតម្លៃផ្ទាល់ខ្លួនរបស់ពួកគេចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិ ផ្អែកលើប្រភពមុនឆ្នាំ១៩៧៥ ក្នុងការធ្វើសេចក្តីសន្និដ្ឋាននេះ[153] និងកត់សម្គាល់លើសេចក្តីអត្ថាធិប្បាយរបស់គណៈកម្មការច្បាប់អន្តរជាតិ

---

[150] *សូមមើលឧទាហរណ៍ Kordić & Čerkez*, IT-95-14/2-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ១១៣ (ដែលបានតម្កល់ថា "មិនអាចជំទាស់បាន" *Kordić & Čerkez*, IT-95-14/2-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ២៣៥-២៣៦ ("ដើម្បីរកឃើញថា ជនជាប់ចោទម្នាក់មានពិរុទ្ធចំពោះអំពើមនុស្សឃាត ធាតុផ្សំខាងក្រោមត្រូវតែបញ្ជាក់៖ [...] ថា ជនជាប់ចោទនោះ ឬ ជនក្រោមបង្គាប់របស់គាត់មានចេតនាសម្លាប់ជនរងគ្រោះ ឬបណ្តាលឲ្យមានព្យសនកម្មធ្ងន់ធ្ងរ ឬបង្កឲ្យមានរបួសធ្ងន់ធ្ងរ ដោយមានហេតុផលដឹងឮថា ការវាយប្រហារទំនងជាបណ្តាលឲ្យមានការបាត់បង់ជីវិត។")។ *D. Milošević*, IT-98-29/1-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១០៨។ *Stakić*, IT-97-24-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៥៨៧ ("ការត្រឡប់ទៅមើលធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្ម អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ទាំង*ចេតនាផ្ទាល់* និង *ចេតនាប្រព្រឹត្ត* គឺគ្រប់គ្រាន់ដើម្បីបង្ហាញពីឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាតតាមមាត្រា៣។"), កថាខណ្ឌ៦៤២ ("ចេតនាដែលត្រូវការសម្រាប់អំពើមនុស្សឃាតក្នុងរូបភាពជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (គឺ៖ *ចេតនាផ្ទាល់* ឬ *ចេតនាប្រព្រឹត្ត*)"។ មិនត្រូវបានរំខាននៅដំណាក់កាលបណ្តឹងសាទុក្ខទេ។)។ *Akayesu*, ICTR-96-4-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ៥៨៩។ *Taylor*, SCSL-03-01-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ៤១២។ *Bikindi*, ICTR-01-72-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៤២៩។

[151] ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ៤១២។

[152] *សូមមើល* ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ៣៨៧-៣៨៨, ៤១០។

[153] *សូមមើលឧទាហរណ៍ Delalić និងគូកន*, IT-96-21-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ("*Čelebići* TJ") កថាខណ្ឌ៤២០-៤៣៨ (ការវិភាគអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ពិធីសារបន្ថែម I និងសេចក្តីអត្ថាធិប្បាយ ឆ្នាំ១៩៧៧ ជាមយួយនឹងយុត្តិសាស្រ្តពីយុត្តាធិការច្បាប់ស៊ីវិល និងច្បាប់ខាំម៉ុន) កថាខណ្ឌ៤៣៩ ("ផ្អែកលើមូលដ្ឋាននៃការវិភាគនេះតែឯង អង្គជំនុំជម្រះសាលាដំបូងច្បាស់ណាស់ថា ចេតនាចាំបាច់ មានន័យថា ចេតនាឧក្រិដ្ឋ ដែលតម្រូវដើម្បីបង្ហាញពីឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតដោយចេតនា និងអំពើមនុស្សឃាត ដូចដែលបានទទួលស្គាល់នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ គឺមានវត្តមាន នៅត្រង់កន្លែងណាដែលត្រូវបានបង្ហាញចេតនារបស់ជនជាប់ចោទដើម្បីសម្លាប់ ឬបង្កឲ្យមានរបួសធ្ងន់ធ្ងរដោយធ្វេសប្រហែសមិនខ្វល់ពីជីវិតមនុស្ស")។ ដូចដែលបានបញ្ជាក់ដោយ អង្គជំនុំជម្រះ អ.វ.ត.ក និងតុលាការ ICTY ធាតុផ្សំនៃការធ្វើមនុស្សឃាតដោយចេតនា ក្នុងរូបភាពជាការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើមនុស្សឃាតក្នុងរូបភាពជាឧក្រិដ្ឋកម្មសង្គ្រាម ឬជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺដូចគ្នា។ *សូមមើលឧទាហរណ៍* សំណុំ

ដែលថា "អំពើមនុស្សឃាតគឺជាឧក្រិដ្ឋកម្មដែលត្រូវបានដឹងច្បាស់ និងត្រូវបានកំណត់និយមន័យច្បាស់លាស់នៅក្នុងច្បាប់ជាតិរបស់រដ្ឋទាំងអស់។ អំពើដែលត្រូវបានហាមឃាត់នេះមិនតម្រូវឲ្យមានការពន្យល់ណាបន្ថែមទៀតទេ"[154]។

54. ផ្ទុយទៅនឹងអំណះអំណាងរបស់ ខៀវ សំផន[155] អ.ជ.ត.ក មិនបាន "បកស្រាយខុស" នូវ *សំណុំរឿងវេជ្ជសាស្ត្រ* នៅពេលដែលខ្លួនបានសម្រេចថា សំណុំរឿងនេះបានផ្តល់នូវការបញ្ជាក់មួយដ៏រឹងមាំថា នៅក្នុងរយៈពេលក្រោយសង្គ្រាមលោកលើកទី II ការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានរួមបញ្ចូលនូវសញ្ញាណនៃ*ចេតនាប្រព្រឹត្ត* ផងដែរ[156]។ ថាតើ តុលាការអន្តរជាតិផ្សេងទៀតបានពឹងផ្អែកលើ*សំណុំរឿងវេជ្ជសាស្ត្រ*ចំពោះគោលដៅនេះ ឬយ៉ាងណានោះ គឺមិនទាក់ទងទៅនឹងតម្លៃអាជ្ញាព្រឹត្តនោះទេ[157] គឺជាអង្គហេតុដែលមិនមាននិយមន័យច្បាស់លាស់ស្តីពី*បំណងឧក្រិដ្ឋ* នោះទេ។ ការរកឃើញរបស់តុលាការ ស.រ.អា ស្តីពីការធ្វើមនុស្សឃាត ដោយអវត្តមាននូវចេតនាដោយផ្ទាល់ដើម្បីសម្លាប់ គឺច្បាស់លាស់តាមរយៈសម្អាងហេតុរបស់ខ្លួន[158]។

---

រឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៤៣១។ *Brđanin* IT-99-36-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ៣៨០ និងការយោងជើងទំព័រលេខ ៩០៣។

[154] *Blaškić*, IT-95-14-T, សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ២១៧ *បានសន្និដ្ឋានថា ធាតុផ្សំអត្តនោម័ត* នៃអំពើមនុស្សឃាត "ចេតនា [...] បណ្តាលឲ្យមានព្យសនកម្មធ្ងន់ធ្ងរដោយមានហេតុផលដឹងឮថា ការវាយប្រហារទំនងជាបណ្តាលឲ្យមានការបាត់បង់ជីវិត" និង *បានដកស្រង់* របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ ស្តីពីការងារ សម័យប្រជុំលើកទី៤៨របស់ខ្លួន ចុះថ្ងៃទី៦ ខែឧសភា ដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩៦ UN Doc. A/51/10, ទំព័រ៩៦។

[155] ឯកសារ **F53** សំណើសុំប្តឹងឧទ្ធរណ៍ កថាខណ្ឌ ៨៣។ ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ ៣៩៧-៤២០។

[156] ឯកសារ **F36** សាលដីកានៃសំណុំរឿង០០២/០១ កថាខណ្ឌ ៣៩៥ *ដោយបានយោងសម្អាង សហរដ្ឋអាមេរិក ទល់នឹង Brandt និងគូកន* សាលក្រម ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៤៧ ("សាលក្រម*វេជ្ជសាស្ត្រ*") សវនាការនៃពួកឧក្រិដ្ឋកម្មសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuernberg ក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាច្បាប់លេខ១០ វ៉ុលូម II ទំព័រ ១៨៩-២០៧, ២៣៥-២៤១, ២៥៣-២៦៣, ២៧១, ២៩០។

[157] *ផ្ទុយទៅនឹង* ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល របស់ ខៀវ សំផន កថាខណ្ឌ ៤០៥។

[158] *សូមមើល ឧទា.* សាលក្រម*វេជ្ជសាស្ត្រ* ទំព័រ ២៣៦ (ភស្តុតាងបង្ហាញថា ការពិសោធន៍វេជ្ជសាស្ត្រទាំងនេះត្រូវបាន ដំណើរការទៅ "ដើម្បីកំណត់កម្រិតនៃភាពអំណត់ និងអត្ថិភាព របស់មនុស្សក្នុងកំរិតខ្ពស់បំផុត") ទំព័រ ២៣៧-២៣៨ (ការ ពិសោធន៍ត្រូវបានដំណើរការទៅដើម្បី "ពិនិត្យបញ្ជាក់ពីប្រសិទ្ធិភាពនៃប្រព្រឹត្តកម្មផ្សេងៗគ្នានៃមុខរបួស ដែលបានបង្កឡើងដោយ ឧស្ម័ន Lost [...] ការពិសោធន៍នេះមានមុខរបួសបង្កឡើងនៅលើផ្នែកផ្សេងៗនៃរាងកាយរបស់បុគ្គល ដែលត្រូវបានពិសោធន៍ ហើយក្រោយមក បានបង្កភោគដល់ពួកគាត់ដោយឧស្ម័ន Lost")។

55. ការអះអាងនានារបស់ ខៀវ សំផន ដែលថា "ជំរុំប្រមូលផ្តុំទាំងអស់នៃរបបណាហ្សី" ត្រូវបាន "ប្រើសម្រាប់ [...] មនុស្សដែលរបបអ៊ីត្លែបញ្ជូនឱ្យស្លាប់យ៉ាងប្រាកដ" ហើយថាចុងចោទនានា ដែលនៅក្នុងសំណុំរឿង*វេជ្ជសាស្ត្រ* ត្រូវតែមានចេតនាដោយផ្ទាល់ដើម្បីសម្លាប់[159] គឺខុសឆ្គង និងមិនគាំទ្រដោយភស្តុតាងពាក់ព័ន្ធនោះទេ។ ទីមួយ វាមានមូលដ្ឋានដោយអធម្មានុរូបដោយផ្អែក នៅលើ ការរកឃើញខាងអង្គហេតុរបស់សំណុំរឿង*ផ្សេងទៀត*[160] ដែលសូម្បីតែមិនមានពោលពីជំរុំប្រមូលផ្តុំទាំងអស់នោះផងនៅក្នុងសំណុំរឿង*វេជ្ជសាស្ត្រ* ហើយដែលនៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ បានបង្ហាញថា វាមិនមានចេតនាផ្ទាល់ ដើម្បីសម្លាប់អ្នកនៅក្នុងជំរុំប្រមូលផ្តុំទាំងអស់នោះទៀតផង[161]។ អំណះអំណាងដែលនៅសេសសល់របស់ ខៀវ សំផន មិនបាននាំឆ្ពោះទៅរកអ្វីច្រើនជាងការពិចារណាមិនត្រឹមត្រូវ អំពី*បំណងឧក្រិដ្ឋ* របស់ចុងចោទនោះឡើយ ដែលថាគាត់បានទាញយកដោយមិនត្រឹមត្រូវពីការរក ឃើញរបស់អង្គជំនុំជម្រះ ដែលថាការស្លាប់នានាបានកើតឡើងជាចុងក្រោយនេះ[162] រួមជាមួយនឹង អំណះអំណាងរបស់គាត់ផ្ទាល់ដែលមិនបានចង្អុលភស្តុតាងអំពីការបំពុលដោយប្រើថ្នាំ ដែលបានផ្តល់ ឱ្យដល់ជនរងគ្រោះជាការពិសោធន៍[163]។

---

[159] ឯកសារ E457/6/4/1 សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ ៤១១-៤២០។

[160] ឯកសារ E457/6/4/1 សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ ៤១២, ៤១៦ *ដោយបានយោងសម្អាង សហរដ្ឋអាមេរិក និងគូកន ទល់នឹង* Göring *និងគូកន* សាលក្រម ចុះថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៦ ("សាលក្រម IMT") សវនាការនៃឧក្រិដ្ឋជនសង្គ្រាមធំៗនៅចំពោះមុខតុលាការយោធាអន្តរជាតិ វ៉ូលូម I ទំព័រ ២៣៤-២៣៥, ២៥២។

[161] ឯកសារ E457/6/4/1 សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ ៤១២ *ដោយបានលើកឡើងពី* សាលក្រម IMT កថាខណ្ឌ ២៣៤-២៣៥។

[162] ឯកសារ E457/6/4/1 សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ ៤១៥, ៤១៧។ ជាងនេះទៀត សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថាសម្អាងហេតុទាំងនោះ មិនគាំទ្រដល់ការអះអាងរបស់ ខៀវ សំផន ដែលថា ការពិសោធន៍ A និង B "ចៀសមិនផុតពីសេចក្តីស្លាប់"។ ជាងនេះទៀត សម្អាងហេតុរបស់អង្គជំនុំជម្រះ បានបញ្ជាក់ច្បាស់ថាមានអ្នកនៅរស់រានមានជីវិតជាច្រើនជាឧទាហរណ៍។ សូមមើលឧទាហរណ៍ សាលក្រមវេជ្ជសាស្ត្រ កថាខណ្ឌ ១៧៥ (ការពិសោធន៍ A "អ្នកផ្សេងទៀត ទទួលរងនូវការរងគ្រោះ ការធ្វើទារុណកម្ម និងការធ្វើបាបធ្ងន់ធ្ងរ")។ ការពិសោធន៍ B "បន្ទាប់ពីអ្នកនៅរស់រានមានជីវិត ទទួលរងនូវការប៉ះពាល់អារម្មណ៍ធ្ងន់ធ្ងរ ការធ្វើឱ្យមានភាពកក់ក្តៅឡើងវិញ ត្រូវការមធ្យោបាយជាច្រើន") ២៣៦-២៣៧ (ការពិសោធន៍ A "កម្មវត្ថុជាច្រើននៃការពិសោធន៍នេះ បានធ្វើឱ្យរងគ្រោះធ្ងន់ធ្ងរ ដោយសារការធ្វើទារុណកម្ម និងការធ្វើបាប")។

[163] ឯកសារ E457/6/4/1 សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ ខៀវ សំផន កថាខណ្ឌ ៤១៦-៤២០។

56. ជាចុងក្រោយ ខៀវ សំផន យល់ខុសចំពោះគោលបំណងនៃការពឹងទៅលើផ្អែករបស់ អជតក[164] លើច្បាប់ក្នុងស្រុកដែលគាំទ្រចំពោះបទដ្ឋាននៃ *ចេតនាប្រព្រឹត្ត*[165]។ អជតក មិនបានស្វែងរក "ការដាក់បង្ហាញការអនុវត្តរបស់រដ្ឋ ឬមតិយោបល់ច្បាប់ក្នុងលក្ខណៈទូលំទូលាយ ឬដូចៗគ្នា ដែលបង្កើតបាននូវនិយាមនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ១៩៧៥"[166] នោះទេ។ ផ្ទុយទៅវិញ អជតក បានបង្ហាញគោលការណ៍ច្បាប់ទូទៅមួយដែលថា "ធាតុផ្សំខាងផ្លូវចិត្តចាំបាច់នៃការសម្លាប់ដោយចេតនាត្រូវបានបំពេញ បើទោះបីជាចារីបានធ្វើសកម្មភាពតិចជាងចេតនាក្នុងការសម្លាប់ដោយផ្ទាល់" (ប៉ុន្តែលើសពីភាពធ្វេសប្រហែស)[167]។ ការតវ៉ារបស់ ខៀវ សំផន ចំពោះភាពអាចអនុវត្តបាននៃច្បាប់ក្នុងស្រុកដែលឈរលើមូលដ្ឋានថា ច្បាប់ទាំងនោះចុះកាលបរិច្ឆេទក្រោយឆ្នាំ១៩៧៥[168] គឺជាការធ្វើតំណាងខុសចំពោះប្រភពឯកសារយោងដែល អជតក បានពឹងផ្អែក។ ការវិភាគរបស់គាត់ផ្ទាល់បង្ហាញថា ប្រភពឯកសារយោងជាច្រើននៃប្រភពឯកសារយោងទាំងនេះ ទាំងពីខាងយុត្តាធិការនៃច្បាប់ស៊ីវិល និងខាំម៉ុនឡ គឺចុះកាលបរិច្ឆេទមុនឆ្នាំ១៩៧៥[169] ហើយគាត់ខកខានមិនបានបង្ហាញថា យុត្តាធិការដែលនៅសេសសល់ណាមួយ បានធ្វើឱ្យមានការផ្លាស់ប្តូរដល់អភិក្រមជាមូលដ្ឋាននោះទេ នៅក្រោយឆ្នាំ១៩៧៥ ឬបានប្រើបទដ្ឋាន *បំណងឧក្រិដ្ឋ* នៅមុនកាលបរិច្ឆេទនោះ[170]។

---

[164] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៣៩៦-៤០៩។

[165] ឯកសារ **E457/6/4/1** សារណាបិទកិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន, កថាខណ្ឌ ៤២២-៤២៩។

[166] *ផ្ទុយទៅនឹង* ឯកសារ **E457/6/4/1** សារណាបិទកិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន, កថាខណ្ឌ ៤២៩។

[167] *សូមមើលជាពិសេស* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៣៩៦, ៤០៩។

[168] ឯកសារ **F53** សំណើសុំថ្លឹងថ្លែងដិតចិត្ត, កថាខណ្ឌ ៨៣។ ឯកសារ **E457/6/4/1** សារណាបិទកិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន, កថាខណ្ឌ ៤២៧-៤២៨។

[169] ឯកសារ **E457/6/4/1** សារណាបិទកិច្ចពិភាក្សាដេញដោលរបស់ ខៀវ សំផន, កថាខណ្ឌ ៤២៤-៤២៥, ៤២៧-៤២៨ *បញ្ជាក់អះអាង* ថាប្រភពនានាដែល អជតក បានពឹងផ្អែកនៅក្នុងឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៣៩៨-៤០៤, ចុះកាលបរិច្ឆេទមុនឆ្នាំ១៩៧៥ កម្ពុជា (១៩៥៦), (បែលស៊ិក (១៨៧៩), ប៉ូឡូញ (១៩០៩ និង ១៩៣២), អាហ្វ្រិកខាងត្បូង (១៩៦៣), អង់គ្លេស និងវេល (១៩៧៤), ឥណ្ឌា (១៨៦០), សឹង្ហបូរី (១៨៧២), អូស្ត្រាលី (១៨៩៩, ១៩០០, ១៩១៣, ១៩២៤, ១៩៧១, ១៩៧៣), សហរដ្ឋអាមេរិក (១៩៦២)។

[170] ជាឧទាហរណ៍ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ខណៈដែល អជតក បានយោងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ របស់ប្រទេសកាណាដា (ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កំណត់សម្គាល់ជើងទំព័រ ១០០៤), ក្រមព្រហ្មទណ្ឌកាណាដា បានដាក់បញ្ចូលបទប្បញ្ញត្តិស្តីពីអំពើមនុស្សឃាតដោយធ្វេសប្រហែស នៅចុងបំផុតក្នុងឆ្នាំ១៩៧០ ដែលនៅតែមានអនុភាពទៅលើចិរវេលាទាំងមូលនៃឆ្នាំ១៩៧៥-១៩៧៩។ *សូមមើល* ក្រមព្រហ្មទណ្ឌកាណាដា, ១៩៧០, ជំពូក គ-៣៤, § 201(a) (ការធ្វើមនុស្សឃាតរួមបញ្ចូលទាំង "មានចេតនាបង្កឱ្យស្លាប់ ឬមានចេតនាដែលនាំឱ្យរងរបួសដល់រាងកាយដែលពួកគេដឹងថា ទំនងជានឹងបណ្តាលឱ្យស្លាប់បាន *ហើយជាភាពធ្វេសប្រហែសមិនថាវានាំឱ្យមានការស្លាប់ ឬអត់នោះទេ)* (សង្កត់ន័យដើម); §201(c)

iii. *ការទទួលខុសត្រូវតាមបែបសហឧក្រិដ្ឋកម្មរួម*

57. ការអះអាងដោយខុសឆ្គងរបស់ ខៀវ សំផន ដែលថាការកឃើញនៅក្នុងសំណុំរឿង០០២/០១ របស់ អ.ជ.ត.ក ថាវិសាលភាពនៃផែនការឧក្រិដ្ឋរួមនៃសហឧក្រិដ្ឋកម្មរួម មានរួមបញ្ចូលនូវឧក្រិដ្ឋកម្ម ដែលសមាជិកសហឧក្រិដ្ឋកម្មរួមបានទទួលយក "ការមិនអើពើ និងយថាហេតុដែលអាចកើតឡើង" ("របកគំហើញផែនការរួម") បង្ហាញពីភាពលំអៀងជាក់ស្តែង និង/ឬ ភាពទំនងជាលំអៀង[171]។ ជាថ្មីម្តងទៀត គាត់ដែលជាភាគីប្តឹង បានខកខានមិនបានលើកពីបន្ទុកដ៏ធ្ងន់ធ្ងរដែលបានដាក់នៅលើ គាត់ដើម្បីឲ្យត្រូវតាមបទដ្ឋាននៃការបង្ហាញថា សេចក្តីសម្រេចរបស់ចៅក្រមដែលរងនូវការ ជំទាស់ មិនអាចជា "ការអនុវត្តច្បាប់ជាក់ស្តែង ដែលអាចមានការបកស្រាយបានច្រើន"[172]។ មានតែនៅក្នុង "សំណុំរឿងវិសាមញ្ញពិតប្រាកដ"ប៉ុណ្ណោះ ដែលបន្ទុកនេះនឹងត្រូវបានបំពេញ[173] ហើយ ខៀវ សំផន បានខកខាននៅទីនេះ មិនបានធ្វើដូច្នោះទេ។

58. ការអះអាងរបស់ ខៀវ សំផន ដែលថា "ចៅក្រមរងបណ្តឹងដិតចិត្ត មិនបានបញ្ជាក់ពីឯកសារយោង ណាមួយ ដើម្បីគាំទ្រការវិភាគរបស់ខ្លួនទាល់តែសោះ"[174] បានដាក់ដោយមិនសមហេតុផលនូវ កថាខណ្ឌពីរនៃសម្អាងហេតុរបស់ អ.ជ.ត.ក ឲ្យនៅតែឯង។ ដូច ខៀវ សំផន បានទទួលស្គាល់ពីមុន ៗ នៅក្នុងសារណាបិទកិច្ចពិភាក្សាដេញដោល ក្នុងសំណុំរឿង០០២/០២[175]។ ការវាយតម្លៃយ៉ាង ទូលំទូលាយរបស់ អ.ជ.ត.ក ស្តីពីលក្ខខណ្ឌតម្រូវនៃ *អំពើពិរុទ្ធ* សម្រាប់ការទទួលខុសត្រូវសហ ឧក្រិដ្ឋកម្មរួម បានគ្របដណ្តប់លើកថាខណ្ឌប្រមាណជា ៤៤ ស្តីពីការវិភាគពិស្តារនៃករណីយុត្តិ សាស្ត្រពី ICTY, ICTR និង SCSL ក៏ដូចជា ករណីនានានៃក្រោយសង្គ្រាមលោកលើកទី II

(ការធ្វើមនុស្សឃាត រួមបញ្ចូលទាំងទង្វើប្រព្រឹត្ត "ដែលធ្វើឡើងក្នុងគោលបំណងខុសច្បាប់ ដែលបុគ្គលណាម្នាក់ធ្វើអ្វីមួយដែល គាត់ដឹង ឬគួរតែដឹងថាទង្វើនោះទំនងជានឹងបង្កឲ្យមានការស្លាប់ ដោយហេតុនោះ វាបង្កឲ្យមានការស្លាប់មនុស្សណាម្នាក់ ថ្វីបើ គាត់ប្រាថ្នាចង់ឲ្យគោលបំណងរបស់គាត់មិនបង្កឲ្យមានការស្លាប់ ឬរងរបួសដល់រូបរាងកាយទៅលើមនុស្សណាម្នាក់ក៏ដោយ")។

[171] ឯកសារ **F53** សំណើសុំប្តឹងដិតចិត្ត កថាខណ្ឌ ៨៥, ៩២ *ដោយបានលើកឡើង* ត្រង់កថាខណ្ឌ ៨៥ ឯកសារ **F36** សាលដីកា នៃសំណុំរឿង០០២/០១ កថាខណ្ឌ ៨០៩។

[172] *សូមមើល ខាងលើ* កថាខណ្ឌ ២៨, ៥១។

[173] *សូមមើល ខាងលើ* កថាខណ្ឌ ៣៩។

[174] ឯកសារ **F53** សំណើសុំប្តឹងដិតចិត្ត កថាខណ្ឌ ៨៦ *ដោយបានលើកឡើង* ឯកសារ **F36** សាលដីកានៃសំណុំរឿង០០២/០១ កថាខណ្ឌ ៨០៨, ៨០៩។

[175] ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល កថាខណ្ឌ ៤៣២-៤៥៣, ៤៧៥។

ផងដែរ[176] ដែល អ.ជ.ត.ក បានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងជំហាននីមួយៗនៃការវិភាគរបស់ខ្លួនដើម្បីបានឈានដល់នូវរបកគំហើញនៃផែនការរួមរបស់ខ្លួន[177]។ ដូចដែល ខៀវ សំផន បានលើកឡើងដូច្នោះដែរ អ.ជ.ត.ក មិនបាន "ទម្លាក់ចោលរាល់វិធានច្បាប់ដែលអាចអនុវត្តបាន" នោះទេ[178]។

59. ផ្ទុយទៅវិញ អ.ជ.ត.ក បានទទួលស្គាល់យ៉ាងត្រឹមត្រូវថា ករណីរឿងក្តីនៅក្រោយសង្គ្រាមលោកលើកទី II "បានតម្រូវ [...] ថា [ជនជាប់ចោទ] យល់ស្របតាមគោលបំណងរួមនៃចរិតឧក្រិដ្ឋ"[179]។ ដោយពឹងផ្អែកលើសាលដីការបស់ *Tadić* ខ្លួនបានរំលឹកឡើងវិញថា ដើម្បីគោលបំណងនៃការបង្កើត*អំពើពិរុទ្ធ* នៃសហឧក្រិដ្ឋកម្មរួម ត្រូវតែមានផែនការរួម "ដែលជាបទឧក្រិដ្ឋ ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ"[180]។ អ.ជ.ត.ក ក៏បានរំលឹកឡើងវិញផងដែរ និងបានអនុវត្តនូវករណីយុត្តិសាស្ត្រនៃសាលាឧទ្ធរណ៍របស់ SCSL នៅក្នុងករណីរឿង *Brima* ដែល បានរកឃើញថា "គោលបំណងឧក្រិដ្ឋដែលជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម មិនត្រឹមតែអាចសន្និដ្ឋានចេញពីគោលដៅចុងក្រោយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចេញពីមធ្យោបាយនានា*ដែលប្រើប្រាស់* ដើម្បីសម្រេចគោលដៅនោះផងដែរ។ គោលដៅ *និង មធ្យោបាយ* ដើម្បីសម្រេចបានគោលដៅនេះ អាចចាត់ទុកថាជាការរៀបចំ ឬផែនការរួម"[181]។ នៅពេលនោះខ្លួនបានរកឃើញថា "មធ្យោបាយនានាដែលប្រើប្រាស់" ដើម្បីសម្រេចនូវគោលដៅនៃគោលបំណងរួម រួមបញ្ចូលទាំងឧក្រិដ្ឋកម្មទាំងនោះដែលសមាជិកនៃសហឧក្រិដ្ឋកម្មរួមបានទទួលស្គាល់ គឺត្រូវបានប្រព្រឹត្តឡើងដើម្បីសម្រេចនូវគោលដៅលាក់កំបាំងមួយ។ និយាយម្យ៉ាងទៀត អ.ជ.ត.ក បានរកឃើញថា "សមាជិកនៃសហឧក្រិដ្ឋកម្មរួមត្រូវទទួលយកការប្រព្រឹត្តឧក្រិដ្ឋកម្ម ទាំងជាគោលដៅ ទាំងជាផលវិបាកដែលជៀសមិនរួចនៃគោលបំណង

[176] ឯកសារ **F36** សាលដីកានៃសំណុំរឿង០០២/០១ កថាខណ្ឌ ៧៦៧-៨១០។

[177] ឯកសារ **F36** សាលដីកានៃសំណុំរឿង០០២/០១ កថាខណ្ឌ ៧៦៧-៨១០។

[178] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ កថាខណ្ឌ ៨៦។

[179] ឯកសារ **F36** សាលដីកានៃសំណុំរឿង០០២/០១ កថាខណ្ឌ ៧៧៩, ៧៨៩ (សង្កត់ន័យបន្ថែម)។ ចំពោះការវិភាគរបស់ អ.ជ.ត.ក ស្តីពីករណីយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី II ដែលបានគាំទ្រដល់គោលជំហរនេះ *សូមមើល* ឯកសារ **F36** សាលដីកានៃសំណុំរឿង០០២/០១ កថាខណ្ឌ ៧៨០-៧៨៨ និង ការលើកឡើងនៅក្នុងនោះ។

[180] ឯកសារ **F36** សាលដីកានៃសំណុំរឿង០០២/០១ កថាខណ្ឌ ៧៨៩, ៨០៧ *ដោយដកស្រង់* *Tadić* សំណុំរឿងលេខ IT-94-1-A សាលដីកា សាលាឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ ("សាលដីការបស់ *Tadić*") កថាខណ្ឌ ២២៧។

[181] ឯកសារ **F36** សាលដីកានៃសំណុំរឿង០០២/០១ កថាខណ្ឌ ៧៨៩ *ដោយបានលើកឡើងពី រដ្ឋអាជ្ញា ទល់នឹង Brima និងគូកន* សំណុំរឿងលេខ SCSL-2004-16-A សាលដីកា សាលាឧទ្ធរណ៍ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ ("សាលដីការបស់ *Brima*") កថាខណ្ឌ ៧៦ (គូសបញ្ជាក់បន្ថែម)។ *សូមមើល ផងដែរ* ឯកសារ **F36** សាលដីកានៃសំណុំរឿង០០២/០១ កថាខណ្ឌ ៨០៨ *ដោយបានលើកឡើងពី* សាលដីការបស់ *Brima* កថាខណ្ឌ ៨០។

បឋម ឬ ទាំងគ្មានការអើពើពីយថាហេតុដែលអាចកើតឡើង"[182]។ ខៀវ សំផន ខកខានមិនបាន បង្ហាញថា តើរបៀបណាដែលការវិភាគនេះបង្ហាញពីភាពលំអៀងនោះ។

60. ការវិភាគរបស់ អ.ជ.ត.ក ក្នុងផ្នែកសេសសល់នៃសាលដីកានេះ ក៏ផ្ទុយផងដែរទៅនឹងការអះអាងរបស់ ខៀវ សំផន ដែលថា អ.ជ.ត.ក បានបង្កើតដោយមិនត្រូវបានអនុញ្ញាតនូវ "សហឧក្រិដ្ឋកម្មរួមកូនកាត់មួយ ដែលបូកបញ្ចូលគ្នានូវធាតុផ្សំនៃ*អំពើឧក្រិដ្ឋ*នៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី I និងធាតុផ្សំនៃ*ចេតនាឧក្រិដ្ឋ*ទម្រង់ទី III"[183]។ នៅពេលវាយតម្លៃ*ចេតនាឧក្រិដ្ឋ*របស់ជនជាប់ចោទ ស្របគ្នាទៅនឹងយុត្តិសាស្ត្រដែលបានបង្កើតឡើងយ៉ាងត្រឹមត្រូវពីតុលាការនេះ និងតុលាការមិនអចិន្ត្រៃយ៍ផ្សេងទៀត ចំពោះចេតនាឧក្រិដ្ឋក្នុងសហឧក្រិដ្ឋកម្មរួម អ.ជ.ត.ក បានបញ្ជាក់ថា ជនជាប់ចោទត្រូវតែបានចូលរួមជាមួយនឹងអ្នកចូលរួម JCE ផ្សេងទៀតទាំងចេតនា *គឺ ចេតនាឧក្រិដ្ឋ*[184]ដែលពាក់ព័ន្ធដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងគោលបំណងរួម និងចេតនាចូលរួមក្នុងផែនការរួម ដែលបានផ្តោតលើការប្រព្រឹត្តិ[185]។ អង្គជំនុំជម្រះក៏បានច្រានចោលបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាផងដែរ ដោយបានសម្រេចថា ការទទួលខុសត្រូវ ត្រូវបានកំណត់ត្រឹមឧក្រិដ្ឋកម្មដែលមាននៅក្នុងគោលបំណងរួម[186]។

### iv. *ការកំណត់អង្គហេតុគតិយុត្តឡើងវិញក្នុងសំណុំរឿង០០២/០១*

[182] ឯកសារ **F36** សាលដីកានៃសំណុំរឿង០០២/០១ កថាខណ្ឌ ៨០៩។

[183] ឯកសារ **F53** សំណើសុំប្តឹងជំទាស់មិនចិត្ត កថាខណ្ឌ ៨៦។

[184] ដោយសារតែការចូលរួមប្រព្រឹត្តក្នុង JCE គឺជាទម្រង់មួយនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ដូច្នេះសមាជិក JCE នឹងតម្រូវឲ្យមាន*ចេតនាឧក្រិដ្ឋ*ដូចគ្នា មិនមែនខ្ពស់ជាងនេះទេ ដូចដែលចារីផ្ទាល់តម្រូវឲ្យមានដែរ។

[185] ឯកសារ **F36** សាលដីកា សំណុំរឿង០០២/០១ កថាខណ្ឌ ១០៥៣-១០៥៤។ *សូមមើលបន្ថែមទៀត ឧទាហរណ៍*ឯកសារ **D97/15/9** សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) អ.ប.ជ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ៣៧, ៣៩។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥០៩។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៦៩០, ៦៩៤។ សាលដីកា *Tadić* កថាខណ្ឌ ១៩៦, ២២០, ២២៨។ សាលដីកា *Popović* កថាខណ្ឌ ១៣៦៩។ *រដ្ឋអាជ្ញា ទល់នឹង Munyakazi*, ICTR-97-36A-A, សាលក្រម អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ១៦០។ *រដ្ឋអាជ្ញា ទល់នឹង Sesay និងគូកន*, SCSL-04-15-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ ៤៧៥។

[186] ឯកសារ **F36** សាលដីកាសំណុំរឿង០០២/០១ កថាខណ្ឌ៨០៧។

61. ផ្ទុយនឹងការតវ៉ារបស់ ខៀវ សំផន[187] សារណារបស់គាត់ដែលទាក់ទងនឹង (i) ការកំណត់ឡើងវិញរបស់ អជតក ពីការសម្លាប់ក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី២ ពីឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល ទៅជាការធ្វើមនុស្សឃាតដោយ *ចេតនាប្រព្រឹត្ត*"[188] និង (ii) ការឈានដល់ការកាត់ទោសចំពោះការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំនៅក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី២ នៅក្រោមការទទួលខុសត្រូវ JCE[189] មិនបានបន្ថយបន្ទុករបស់គាត់[190] ក្នុងការបង្ហាញនូវអនាគតិជាក់ស្តែង[191] (និង/ឬ ការលេចឡើងនៃអនាគតិ) ពីខាងចៅក្រមដែលរងការជំទាស់ឡើយ។

62. ទីមួយ ការកំណត់អង្គហេតុឡើងវិញរបស់ អជតក ពីឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល ទៅជាការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តក្នុង *ចេតនាប្រព្រឹត្ត* នៅក្នុងអំឡុងនៃការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី២[192] គឺជារឿងស្របច្បាប់។ វិធាន ១១០(២) ចែងថា "គ្រប់ករណីទាំងអស់ អង្គជំនុំជម្រះតុលាការកំពូល អាចកែប្រែបទចោទប្រកាន់ដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់។ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលមិនត្រូវបានបន្ថែមធាតុផ្សំថ្មី នៃបទល្មើសណាមួយដែលមិនបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូងដើម្បីសម្រេចនោះទេ"។ បន្តពីការរកឃើញរបស់ អជតក ថា *បំណងឧក្រិដ្ឋ* នៃការសម្លាប់រង្គាល មិនបានបញ្ចូល*ចេតនាប្រព្រឹត្ត* នោះការធ្វើមនុស្សឃាតលែងត្រូវបានស្របចូលទៅក្នុងឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលទាំងស្រុងហើយ នៅក្នុងករណីនេះ[193]។ យ៉ាងណាមិញ ខៀវ សំផន មិនត្រឹមត្រូវទេដែលអះអាងថា អជតក បានបន្ថែមធាតុផ្សំថ្មីដោយមិនសមរម្យនៅពេលដែលអង្គជំនុំជម្រះនេះបានធ្វើការកំណត់បទចោទឡើងវិញ។

---

[187] ឯកសារ **F53** សំណើសុំប្តឹងជំទាស់, កថាខណ្ឌ ៩៣-១០៩។

[188] ឯកសារ **F53** សំណើសុំប្តឹងជំទាស់, កថាខណ្ឌ ៩៧-៩៩ *យោង* ឯកសារ **F36** សាលដីកាសំណុំរឿង 00២/0១, កថាខណ្ឌ ៥៥៧-៥៦២។

[189] ឯកសារ **F53** សំណើសុំប្តឹងជំទាស់, កថាខណ្ឌ ១០១-១០៤ *យោង* ឯកសារ **F36** សាលដីកាសំណុំរឿង 00២/0១, កថាខណ្ឌ ១០៩៧-១០៩៩។

[190] សូមមើលយោងខាងលើ កថាខណ្ឌ ៣៩-៤០។

[191] ឯកសារ *ផ្ទុយទៅនឹង* ឯកសារ **F53** សំណើសុំប្តឹងជំទាស់, កថាខណ្ឌ ៩៣, ១០៥, ១០៩។

[192] ឯកសារ **F36** សាលដីកាសំណុំរឿង 00២/0១, កថាខណ្ឌ ៥៦១-៥៦២។

[193] ឯកសារ **F36** សាលដីកាសំណុំរឿង 00២/0១, កថាខណ្ឌ ៥២២, ១០៩៧ (កំណត់សម្គាល់ជើងទំព័រ ២៩៧៥)។

63. ដូចដែល អ.ជ.ត.ក បានពន្យល់[194] នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទការសម្លាប់មនុស្សដែលបានកើតឡើងនៅក្នុងពេលជម្លៀសប្រជាជនដំណាក់កាលទី II ថាជាការសម្លាប់រង្គាលនោះ អង្គជំនុំជម្រះនេះបានធ្វើការសន្និដ្ឋានផ្នែកអង្គហេតុ និងអង្គច្បាប់ដែលពាក់ព័ន្ធទាំងអស់ដែលចាំបាច់ដើម្បីបំពេញធាតុផ្សំនៃឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាត ដោយរួមបញ្ចូល ការរកឃើញដែលថា ចារីបានធ្វើយ៉ាងហោចណាស់ដោយមាន*ចេតនា*ប្រព្រឹត្ត[195]។ ហេតុដូច្នេះ អ.ជ.ត.ក ត្រូវបានអនុញ្ញាតឲ្យកំណត់ឡើងវិញនូវអង្គហេតុទាំងអស់នោះ ដោយមិនបន្ថែមធាតុផ្សំបង្កើតថ្មីណាមួយឡើយ[196]។ ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន[197] នៅពេលអង្គជំនុំជម្រះសាលាដំបូង បានយកអង្គហេតុទាំងនេះមកពិនិត្យ[198] អំពីការសម្លាប់ក្នុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី II ត្រូវបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ត្រូវបានចោទប្រកាន់ថាជាការសម្លាប់រង្គាលនៅក្នុងដីកាដំណោះស្រាយ[199]។

---

[194] ឯកសារ **F36** សាលដីកានៃសំណុំរឿង០០២/០១ កថាខណ្ឌ ៥៦១។

[195] ឯកសារ **E313** សាលក្រមនៃសំណុំរឿង០០២/០១ កថាខណ្ឌ ៦៤៦-៦៤៨។

[196] ការណ៍នេះគឺស៊ីសង្វាក់គ្នាទាំងស្រុងជាមួយនឹងការកំណត់បទចោទឡើងវិញរបស់ អ.ជ.ត.ក តាមវិធាន ១១០(២) ក្នុងសំណុំរឿង០០១។ អង្គជំនុំជម្រះសាលាដំបូង បានធ្វើការរកឃើញចាំបាច់ចំពោះការកាត់ឲ្យជាប់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្តីពីការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត ប៉ុន្តែបានចូលតែការកាត់ឲ្យជាប់ទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្តីពីការធ្វើទុក្ខបុកម្នេញប៉ុណ្ណោះ។ អ.ជ.ត.ក បានបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីស្រូបឧក្រិដ្ឋកម្មនីមួយៗនៅក្រោមការធ្វើទុក្ខបុកម្នេញ ហើយជាការបន្ថែមទៅនឹងការកាត់ឲ្យជនជាប់ចោទមានទោសចំពោះការធ្វើទុក្ខបុកម្នេញ បានបញ្ចូលវាទៅ ក្នុងការកាត់ឲ្យជាប់ទោសផ្សេងទៀតដែលនៅក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (សំណុំរឿង០០១-ឯកសារ **F28** សាលដីការបស់ *ឌុច* កថាខណ្ឌ ៣៣១, ៣៣៦)។ នៅក្នុងកំណត់សម្គាល់ជើងទំព័រមួយ អ.ជ.ត.ក បានកត់សម្គាល់ថា "ការបញ្ចូលការសម្រេចដាក់ពិរុទ្ធភាពជាផ្លូវការនៅទីនេះ គឺអនុលោមតាមវិធាន ១១០(២) នៃវិធានផ្ទៃក្នុង និងមាត្រា ៤០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដែលតុលាការឧទ្ធរណ៍ អាចកែប្រែបទចោទ ដោយមិនត្រូវបន្ថែមធាតុផ្សំថ្មីនៃបទល្មើសណាមួយដែលមិនបានដាក់ជូននៅអង្គជំនុំជម្រះសាលាដំបូងដើម្បីសម្រេចនោះទេ"។ (សំណុំរឿង០០១-ឯកសារ **F28** សាលដីការបស់ *ឌុច* កំណត់សម្គាល់ជើងទំព័រលេខ ៧៣៥)។

[197] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ចិត្ត កថាខណ្ឌ ៩៩។

[198] វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ("សាលក្រមត្រូវសម្រេចត្រឹមតែ*អង្គហេតុទាំងឡាយណា* ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ *អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ* ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ"។ (គូសបញ្ជាក់បន្ថែម))។

[199] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៨១។ *សូមមើល* ឯកសារ **F36** សាលដីកានៃសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៦២។

64. ការចោទប្រកាន់របស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ត.ក ដែលថា គាត់ទទួលខុសត្រូវតាមរយៈការចូលរួមព្រឹត្តក្នុង JCE សម្រាប់អំពើមនុស្សឃាតទាំងអស់នេះ ក៏ដូចជាអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំ ជាការចោទប្រកាន់ខុសផងដែរ។ ផ្ទុយទៅនឹងការអះអាងរបស់គាត់[200] និងដូចដែលសហព្រះរាជអាជ្ញាបានបង្ហាញលម្អិតនៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់ អ.ជ.ត.ក សុំឱ្យដាក់សេចក្ដីសន្និដ្ឋានលើការកំណត់បទចោទឡើងវិញក្នុងសំណុំរឿង០០២/០១[201] សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ ខៀវ សំផន ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម*ទាំងអស់*ពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ក្រោមទម្រង់នៃការទទួលខុសត្រូវ JCE[202] ដោយរួមបញ្ចូលការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការបាត់ខ្លួនដោយបង្ខំក្នុងអំឡុងពេលជម្លៀសប្រជាជនដំណាក់កាលទី II[203]។ ជាងនេះទៀត ខៀវ សំផន នៅតែបានទទួលការជូនដំណឹងក្នុងពេលសវនាការនៃសំណុំរឿង០០២/០១ ទាំងមូលថា គាត់អាចនឹងត្រូវបានដាក់ពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មទាំងអស់នេះក្រោមទម្រង់ JCE ហើយគាត់ត្រូវបានផ្ដល់ឱកាស

---

[200] ឯកសារ **F53** សំណើសុំប្ដឹងជំទាស់ កថាខណ្ឌ ១០១ (ការធ្វើមនុស្សឃាត), ១០៣ (ការបាត់ខ្លួនដោយបង្ខំ)។

[201] ឯកសារ **F30/6** សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្ដីពីការកំណត់បទចោទជាសក្ដានុពលឡើងវិញ លើឧក្រិដ្ឋកម្មនានា ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ("សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្ដីពីការកំណត់បទចោទ")។

[202] ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៤-១៥២៥, ១៥៤០ ("ខៀវ សំផន [...] បានប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយនេះ ក្នុងឋានៈរបស់ខ្លួនជាសមាជិកក្នុងសហឧក្រិដ្ឋកម្មរួម [JCE]")។

[203] អនុលោមតាមឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥ តាមរយៈការអនុវត្តគោលនយោបាយផ្លាស់ទីប្រជាជន ជនជាប់ចោទត្រូវបានចោទប្រកាន់អំពី អំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារប្រឆាំងនឹងសេចក្ដីថ្លៃថ្នូររបស់មនុស្ស និងការផ្លាស់ទីដោយបង្ខំ។ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ២០៩ បានភ្ជាប់យ៉ាងច្បាស់នូវការប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនក្នុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ទៅនឹងការអនុវត្តគោលនយោបាយកំណត់គោលដៅ ដែលតាមរយៈនេះត្រូវបានប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹងមនុស្សជាតិនៃ (i) *ការសម្លាប់រង្គាល* និង (ii) អំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈ*ការបាត់ខ្លួនដោយបង្ខំ*។ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១-១៣៨៣, ១៣៨៧-១៣៩០ បានបញ្ជាក់ថា ការសម្លាប់រង្គាលដែលបានប្រព្រឹត្តឡើងក្នុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី I និង II) គឺជា "គឺជាផ្នែកមួយនៃមធ្យោបាយទាំងឡាយដែលប្រើប្រាស់ដើម្បីសម្រេចនូវគោលដៅរួមក្នុងការបោសសម្អាត "ខ្មាំង""។ [...] មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាជាអ្នកដែលចេញសេចក្ដីសម្រេច និងសម្របសម្រួលឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ ក្នុងក្របខណ្ឌនៃផែនការរួម" ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧០-១៤៧៨ បានបញ្ជាក់ថា អំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការបាត់ខ្លួនដោយបង្ខំដែលបានប្រព្រឹត្តឡើងក្នុងពេលផ្លាស់ទីប្រជាជន (ដំណាក់កាលទី II) "បង្កើតបានជាផ្នែកមួយនៃមធ្យោបាយ ដែលបានប្រើប្រាស់ដើម្បីសម្រេចនូវផែនការរួម ក្នុងការកម្ទេច "ខ្មាំង""។ [...] ការបាត់ខ្លួនទាំងនេះ ត្រូវបានសម្រេច និងសម្របសម្រួលដោយដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងក្របខណ្ឌនៃផែនការរួម"។ *សូមមើលបន្ថែមទៀត* ឯកសារ **F30/6** សេចក្ដីសន្និដ្ឋានរបស់ ក.ស.ព ស្ដីពីការកំណត់បទចោទឡើងវិញ កថាខណ្ឌ ២១-២២, ២៥។

ហើយគាត់ពិតជាបានទទួលឱកាសនោះមែន ដើម្បីធ្វើការការពារក្តីរបស់គាត់ឲ្យស្របទៅតាមនោះ[204]។

65. វាគ្រាន់តែជាលទ្ធផលនៃការបកស្រាយចង្អៀតជ្រុលរបស់អង្គជំនុំជម្រះសាលាដំបូងអំពីវិសាលភាពសំណុំរឿង០០២/០១ប៉ុណ្ណោះ ដែលអង្គជំនុំជម្រះនេះបានធ្វើឡើងដំបូងបង្អស់នៅក្នុងសាលក្រម ដែលខ្លួនមិនបានដាក់ពិរុទ្ធភាពចំពោះការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំក្រោមទម្រង់នៃការទទួលខុសត្រូវបែប JCE[205]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសន្និដ្ឋានដែលចាំបាច់ទាំងអស់អំពីការចូលរួមចំណែកសំខាន់ៗរបស់ ខៀវ សំផន ក្នុង JCE ដែលរួមបញ្ចូលទាំងឧក្រិដ្ឋកម្មទាំងអស់នោះ[206]។ មុនពេលសាលដីកាលើបណ្តឹងសាទុក្ខ អ.ជ.ត.ក បានជូនដំណឹងដល់ភាគីនានាអំពីលទ្ធភាពនៃការកំណត់បទចោទឡើងវិញ និងបានផ្តល់ឱកាសឲ្យពួកគេធ្វើសេចក្តីសន្និដ្ឋាន[207]។ ហេតុដូច្នេះ សិទ្ធិរបស់ ខៀវ សំផន ត្រូវបានការពារយ៉ាងពេញលេញ[208] ហើយ អ.ជ.ត.ក ត្រូវបានអនុញ្ញាតឲ្យដាក់ពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ ក្រោមការទទួលខុសត្រូវបែប JCE (ដោយរួមបញ្ចូល ការសម្លាប់រង្គាល ដែលត្រូវបានចាត់ថ្នាក់ឡើងវិញថាជាអំពើមនុស្សឃាត[209]) អនុលោមតាមវិធាន១១០(២) នៃវិធានផ្ទៃក្នុង ឬផ្សេងពីនេះ។

66. ជាងនេះទៀត ខៀវ សំផន មិនបានបង្ហាញថាកំហុសណាមួយ (ដែលមិនមានសោះនោះ) ក្នុងការដាក់ពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ អនុលោមតាម JCE ក្រៅពីការរៀបចំផែនការ ការបញ្ជា និងការជួយ និងទំនុកបម្រុង គឺជាជំនួយនៃការសម្រេចរបស់ អ.ជ.ត.ក ក្នុងការតម្កល់ទោសជាប់ពន្ធនាគារមួយជីវិតរបស់គាត់[210]។ វាត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវថា មិនមានឋានានុក្រមជាប់

---

[204] ឯកសារ **F30/6** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីការកំណត់បទចោទ កថាខណ្ឌ ៣, ១៧, ២៤-២៧, ៣១-៣២។

[205] ឯកសារ **F30/6** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីការកំណត់បទចោទ កថាខណ្ឌ ២៣-២៦។ ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៧៧៩-៧៨១, ៨១១-៨១៣, ៨៣៨, ៩៤៣។

[206] ឯកសារ **E313** សាលក្រមសំណុំរឿង០០២/០១ កថាខណ្ឌ ៧៨៦, ៨០៤-៨១០, ៩៦០-៩៩៦។

[207] ឯកសារ **F30** ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥។

[208] ឯកសារ **F30/6** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីការកំណត់បទចោទ កថាខណ្ឌ ១២-១៣, ១៨។

[209] *សូមមើល ខាងលើ* កថាខណ្ឌ៦២-៦៣។

[210] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ កថាខណ្ឌ៩៣, ១០៥-១០៨។

មកជាមួយនៃភាពធ្ងន់ធ្ងរសម្រាប់ទម្រង់នៃការទទួលខុសត្រូវឡើយ[211] និងថាការកំណត់ទោសត្រូវផ្អែកលើទង្វើប្រព្រឹត្តរួមទាំងមូលរបស់ជនជាប់ចោទ[212]។ ដូចបានពិភាក្សាខាងលើ អ.ជ.ត.ក បានវាយតម្លៃការកំណត់ទោសរបស់ ខៀវ សំផន ដោយផ្អែកលើគោលការណ៍ទាំងអស់នេះ និងបានតម្កល់ការកំណត់ទោសរបស់គាត់[213]។

## ឃ. ខៀវ សំផន ខកខានមិនបានបង្ហាញអំពីភាពលម្អៀង នៅក្នុងសេចក្តីសម្រេចរបស់ អ.ជ.ត.ក ដែលបានចេញនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

67. ខៀវ សំផន ខកខានមិនបានបង្ហាញថា មួយណាក្នុងចំណោមសេចក្តីសម្រេចរបស់ អ.ជ.ត.ក[214] ដែលបានចេញតាំងពីការប្រកាសសាលក្រមសំណុំរឿង០០២/០២ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨[215] មានកំហុសនោះឡើយ។ ហេតុដូច្នេះ គាត់ខកខានមិនបានបំពេញបទដ្ឋាននៃការបង្ហាញភស្តុតាងខ្ពស់សមល្មម[216] សម្រាប់ការបង្ហាញអំពីភាពលម្អៀង (និង/ឬ ការស្តែងចេញនូវភាពលម្អៀង)[217]។ ខៀវ សំផន បំភ្លៃសម្អាងហេតុរបស់ អ.ជ.ត.ក ក្នុងសេចក្តីសម្រេចទាំងពីរ[218] និង

---

[211] សាលដីកា *Taylor* កថាខណ្ឌ ៦៦១-៦៧០ (បានសន្និដ្ឋានថា "វាមិនមានឋានានុក្រម ឬ ភាពខុសគ្នាចំពោះគោលបំណងនៃការកំណត់ទោសរវាងទម្រង់នៃការចូលរួមប្រព្រឹត្តនៅក្នុងឧក្រិដ្ឋកម្ម ដែលបានបង្កើតឡើងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ" ហើយថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកច្បាប់នៅក្នុងការសម្រេចថា ការជួយ និងការទំនុកបម្រុងជាទំរង់នៃការទទួលខុសត្រូវ ដែលជាទូទៅធានាបាននូវការកំណត់ទោសមួយដែលស្រាលជាងទម្រង់ផ្សេងៗទៀតនៃការចូលរួមប្រព្រឹត្ត)។

[212] *សូមមើលឧទាហរណ៍* សាលដីកា *Taylor* កថាខណ្ឌ៦៦២-៦៧០។ *Gacumbitsi*, ICTR-2001-64-A, សាលក្រមអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ២០៤ ("ការកំណត់ទោសដំបូង និងសំខាន់បំផុត គួរផ្អែកលើភាពធ្ងន់ធ្ងរនៃបទល្មើស និងកម្រិតនៃការទទួលខុសត្រូវរបស់ជនដែលត្រូវដាក់ពិរុទ្ធ")។ ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ១១១៨។

[213] *សូមមើលខាងលើ* កថាខណ្ឌ៤៣-៤៤។

[214] ឯកសារ **E463/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសម្រេចសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ")។ ឯកសារ **E463/1/5** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេចលេខ E463/14/3 បណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ("សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព")។

[215] ឯកសារ **E1/529.1** ការប្រកាសសាលក្រមក្នុងសំណុំរឿង០០២/០២ ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

[216] *សូមមើលខាងលើ* កថាខណ្ឌ៣៨-៤០។

[217] សហព្រះរាជអាជ្ញាកត់សម្គាល់ថា ខៀវ សំផន ចោទប្រកាន់អំពីភាពលម្អៀងជាក់ស្តែងនៅក្នុងករណីទាំងអស់នេះ (*សូមមើល* ឯកសារ **F53** សំណើសុំប្តឹងជំទាស់ ចំណងជើង ឃ និងកថាខណ្ឌ ១១០)។

បានស្វែងរកដោយគ្មានការអនុញ្ញាតប្រើប្រាស់សំណើសុំប្តឹងជិតចិត្តនេះ ដើម្បីតវ៉ាឡើងវិញជាថ្មីម្តងទៀតនូវបណ្តឹងសាទុក្ខ ដែលមិនអាចទទួលយកបានរបស់គាត់ប្រឆាំងនឹងសេចក្តីសម្រេចជាស្របច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការប្រកាសសាលក្រមរបស់ខ្លួនមុនពេលចេញសម្អាងហេតុជាលាយលក្ខណ៍អក្សរពេញលេញ[219]។

68. ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន[220] អ.ជ.ត.ក *មិន*បានធ្វើនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខភ្លាមៗរបស់គាត់ទេ[221] ហាក់ដូចជាគាត់បានកំពុងតែប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសង្ខេបសាលក្រម ជំនួសឱ្យផ្នែកសម្រេចសេចក្តីនៃសាលក្រមដែលបានប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ អង្គជំនុំជម្រះនៅចងចាំយ៉ាងច្បាស់អំពីសារណារបស់ ខៀវ សំផន ដែលនៅក្នុងនោះគាត់បានអះអាងថាគាត់កំពុងតែប្តឹងសាទុក្ខ "ផ្នែកសម្រេចសេចក្តី"[222]។ ម្យ៉ាងទៀត វាបានកំណត់អត្តសញ្ញាណកម្មវត្ថុនៃបណ្តឹងសាទុក្ខភ្លាមៗនោះ ថាជា "ការប្រកាសផ្នែកសម្រេចសេចក្តី"[223]

---

[218] *សូមមើល* ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ ១១១, ១១៣។

[219] ដូចដែលសហព្រះរាជអាជ្ញាបានពន្យល់នៅក្នុងចម្លើយតបទៅនឹងអង្គសេចក្តីនៃបណ្តឹងសាទុក្ខដើមដំបូងរបស់ ខៀវ សំផន (ឯកសារ **E463/1** បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៩ ខែវិច្ឆិការ ឆ្នាំ២០១៨) មិនមានត្រង់ណានៅក្នុងវិធានផ្ទៃក្នុង ឬកន្លែងណាផ្សេងទៀត (i) រារាំងអង្គជំនុំជម្រះសាលាដំបូងមិនឱ្យបំពេញ*កាតព្វកិច្ច* របស់ខ្លួនដើម្បីប្រកាសសាលក្រមជាសាធារណៈនោះទេ (ដោយមានសេចក្តីសង្ខេបនៃសាលក្រម និងផ្នែកសម្រេចសេចក្តី) អនុលោមតាមវិធាន ១០២(១) នៅមុនពេលខ្លួនបោះពុម្ពផ្សាយសម្អាងហេតុជាលាយលក្ខណ៍អក្សរស្របតាមវិធាន ១០១ នៃវិធានផ្ទៃក្នុង ឬ (ii) ប្រសិនបើការធ្វើដូច្នេះធ្វើឱ្យសាលក្រមនេះអសុពលភាពនោះឡើយ។ តាមពិតនោះ អ.ជ.ត.ក, អ.ប.ជ និងអង្គជំនុំជម្រះសាលាដំបូងក៏ដូចជាអង្គជំនុំជម្រះនៅតុលាការ SCSL, ICTY និង ICTR បានអនុវត្តតាមវិធីនេះ នៅពេលចេញសាលក្រម និងសេចក្តីសម្រេចរបស់ពួកគេ។ អវត្តមានសាលក្រមជាលាយលក្ខណ៍អក្សរនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ មិនមានន័យថា សេចក្តីសង្ខេប និងផ្នែកសម្រេចសេចក្តីបង្កើតបានជា "សាលក្រមសំណុំរឿង០០២/០១" ទេ ហើយអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ក្នុងឱកាសជាច្រើនមកថា សម្អាងហេតុជាលាយលក្ខណ៍អក្សរ នឹងត្រូវចេញក្នុងពេលយ៉ាងឆាប់បំផុត ដែលនៅពេលនោះកាលបរិច្ឆេទកំណត់សម្រាប់បណ្តឹងសាទុក្ខនឹងចាប់ផ្តើមដំណើរការសម្រាប់ភាគី ក្នុងសំណុំរឿង០០២/០២។ ខៀវ សំផន ខកខានមិនបានបង្ហាញឱ្យឃើញពីរបៀបដែលសិទ្ធិរបស់គាត់ត្រូវបានប៉ះពាល់ខ្លាំង ដោយវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង។ *សូមមើល* ឯកសារ **E463/1/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ១៤-២២។

[220] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ ១១១។

[221] ឯកសារ **E463/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ។

[222] ឯកសារ **E463/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៦, ៩។

[223] ឯកសារ **E463/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១៤។

ឬ "ការប្រកាសសេចក្តីសង្ខេបនៃសាលក្រម និងសេចក្តីសន្និដ្ឋានរបស់វា"[224] ដែលមាន "ផ្នែកសម្រេចសេចក្តី" នៃសាលក្រមនោះ[225] ស្របតាមវិធាន ១០២(១) នៃវិធានផ្ទៃក្នុង[226]។

69. ក្នុងករណីណាក៏ដោយ សម្អាងហេតុរបស់ អ.ជ.ត.ក សម្រាប់ការប្រកាសថាបណ្តឹងសាទុក្ខភ្លាមៗនេះ មិនអាចទទួលយកបាន ផ្អែកលើទឡ្ហីករណ៍នីមួយៗក្នុងចំណោមទឡ្ហីករណ៍ទាំងបី ដែលបានលើកឡើងដោយ ខៀវ សំផន អនុវត្តតែទៅលើបណ្តឹងសាទុក្ខនៃផ្នែកសម្រេចសេចក្តីនោះតែឯងប៉ុណ្ណោះ។ ដូចដែល អ.ជ.ត.ក បានថ្លែងថា៖ (i) វិធាន ១០៥(១)(ខ) នៃវិធានផ្ទៃក្នុង "អនុវត្តទៅលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្តី *បើតាមន័យចង្អៀត*" តែប៉ុណ្ណោះ[227] (ii) វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង មិនអនុវត្តទេ ដោយសារតែការប្រកាសផ្នែកសម្រេចសេចក្តីគ្រាន់តែបញ្ចប់ដំណាក់កាលជំនុំជម្រះប៉ុណ្ណោះ ប៉ុន្តែមិនមានអនុភាពរំលត់កិច្ចដំណើរការនីតិវិធី ឬដកហូតសិទ្ធិជនជាប់ចោទមិនឲ្យពិនិត្យអង្គសេចក្តីនៃការដាក់ពិរុទ្ធភាព និងការប្រកាសទោសឡើយ[228] (iii) អ.ជ.ត.ក មិនមានយុត្តាធិការទេ "ដោយហេតុថា សាលក្រមចុងក្រោយជាលាយលក្ខណ៍អក្សរដែលមានសម្អាងហេតុពេញលេញ និងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខដែលរំពឹងទុកនោះ ពុំទាន់ត្រូវបានដោះស្រាយនៅឡើយ" ហើយមិនមានហានិភ័យដល់សិទ្ធិប្តឹងសាទុក្ខដែលអាចលែងមានអានុភាពដោយគ្មានការអន្តរាគមន៍របស់អង្គជំនុំជម្រះនោះឡើយ[229]។

70. ការចោទប្រកាន់របស់ ខៀវ សំផន អំពីភាពលំអៀងដែលកើតចេញពីសេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំធ្វើមោឃភាពរបស់គាត់នេះ[230] គឺគ្មានមូលដ្ឋានស្រដៀងគ្នានេះដែរ។ ទីមួយ

---

[224] ឯកសារ **E463/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៦, ១២, ១៨ (ភាសារបស់ អ.ជ.ត.ក ផ្សេងគ្នាពីរបៀបដែលមិនសំខាន់រវាងកថាខណ្ឌទាំងបីនេះ)។

[225] ឯកសារ **E1/529.1** ប្រកាសសាលក្រមក្នុងសំណុំរឿង០០២/០២ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោង៖ ១១.២៥.៤៣ ("បាទ សេចក្តីសង្ខេបនៃសម្អាងហេតុរបស់អង្គជំនុំជម្រះចប់ត្រឹមនេះ ហើយជាបន្ត យើងនឹងអានផ្នែកសម្រេចសេចក្តី")។

[226] វិធាន ១០២ នៃវិធានផ្ទៃក្នុង។ ("ការប្រកាសសាលក្រមនៅសវនាការសាធារណៈ៖ ១. គ្រប់សាលក្រមទាំងអស់ត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ។ ផ្នែកសង្ខេបនៃសម្អាងហេតុ និងផ្នែកសម្រេចសេក្តីត្រូវតែអានខ្លាំងៗ ដោយប្រធានអង្គជំនុំជម្រះសាលាដំបូង ឬ សមាជិកនៃអង្គជំនុំជម្រះណាម្នាក់")។

[227] ឯកសារ **E463/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១២។

[228] ឯកសារ **E463/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១៤។

[229] ឯកសារ **E463/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១៦-១៧។

[230] ឯកសារ **E463/1/5** សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព។

ការចោទប្រកាន់របស់ ខៀវ សំផន អំពីចេតនាអាក្រក់[231] របស់ អ.ជ.ត.ក ដែលបណ្តាលមកពីការពន្យារពេលចំនួនបីខែ ក្នុងការជូនដំណឹងអំពីសំណើរបស់គាត់នេះ[232] គឺគ្មានអង្គសេចក្តីទាំងស្រុង។ គាត់ខកខានមិនបានបង្ហាញថា គាត់បានទទួលរងគ្រោះនូវភាពលំអៀងណាមួយនោះទេ ជាពិសេសនៅពេលដែល អ.ជ.ត.ក បានចេញសេចក្តីសម្រេចរបស់ខ្លួនលើសំណើសុំធ្វើមោឃភាព តែក្នុងរយៈពេលជាងមួយខែប៉ុណ្ណោះបន្ទាប់ពីសេចក្តីជូនដំណឹងនោះ[233]។ ជាក់ស្តែង ខៀវ សំផន ខកខានមិនបានបង្ហាញថា តើរឿងនេះអាចជំទាស់ទៅនឹងសច្ចធារណ៍ដ៏ខ្លាំងនៃអនាគតិរបស់ចៅក្រមដែលរងនូវការប្តឹងជំទាស់នោះ[234]។

71. ទីពីរ ខៀវ សំផន យល់ខុសចំពោះការរកឃើញ[235]របស់ អជតក ថាគាត់ "បានកំណត់ដោយច្រឡំចំពោះកាលប្បវត្តិដែលអង្គជំនុំជម្រះបានចេញដីកាចាត់តាំង[236] និងសេចក្តីសម្រេចដែលរងការជំទាស់[237]"[238]។ ឈរលើមូលដ្ឋាននៃកាលប្បវត្តិនេះ *ដែលបានដាក់ជូនដោយ ខៀវ សំផន* អជតក បច្ចុប្បន្នបានកំណត់ថា ខៀវ សំផន "បានយល់ច្រឡំអំពីការទទួលបាននូវសេចក្តីសម្រេចដែលរងការជំទាស់ពីមន្ត្រីគ្រប់គ្រងសំណុំរឿង ជាមួយនឹងសេចក្តីជូនដំណឹងនៃដីកាចាត់តាំងតាមប្រព័ន្ធអេឡិចត្រូនិក"[239]

[231] ឯកសារ **F53** សំណើសុំប្តឹងជំទាស់ កថាខណ្ឌ ១១២។

[232] ឯកសារ **E463/1/4** សំណុំរឿង០០២/០២ សំណើរបស់លោក ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេច E463/1/3 លើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ("សំណើសុំធ្វើមោឃភាព")។

[233] សំណើសុំធ្វើមោឃភាព ត្រូវបានជូនដំណឹង នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩ ដោយមាន ឯកសារ **E463/1/5** សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព នៅក្រោយថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩។

[234] *សូមមើលខាងលើ* កថាខណ្ឌ១០, ១៦, ២៦, ៣៩-៤០។

[235] ឯកសារ **F53** សំណើសុំប្តឹងជំទាស់, កថាខណ្ឌ ១១៣។

[236] ឯកសារ **F38** ដីកាចាត់តាំងចៅក្រមបម្រុង, ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ បានដាក់ដោយ អជតក នៅម៉ោង ១:៤៦ រសៀល (ជាភាសាបារាំង និងខ្មែរ) និងនៅម៉ោង ១:៤៧ រសៀល (ភាសាអង់គ្លេស) នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ និងបានជូនដំណឹងដល់ភាគីនៅម៉ោង ៣:០៦ រសៀល ក្នុងថ្ងៃដដែល។

[237] ឯកសារ **E463/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗដែលបានដាក់ដោយ អ.ជ.ត.ក នៅម៉ោង ២:៥២ រសៀល នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩។

[238] ឯកសារ **E463/1/5** សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព កថាខណ្ឌ ៥ (សេចក្តីយោងខាងក្នុងត្រូវបានបន្ថែមដោយសហព្រះរាជអាជ្ញាដើម្បីឲ្យកាន់តែច្បាស់)។

[239] ឯកសារ **E463/1/5** សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព កថាខណ្ឌ ៥។

ដូច្នេះហើយក៏ធ្វើឱ្យការទាមទាររបស់ ខៀវ សំផន បរាជ័យ[240] ដែលថាចៅក្រមបម្រុង Rapoza មិនត្រូវបានតែងតាំងដោយត្រឹមត្រូវទៅក្នុងអង្គចៅក្រម រហូតដល់ក្រោយការដាក់សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ[241]។ ដូច អជតក បានចង្អុលបង្ហាញដែរថាការពិភាក្សាត្រូវបានធ្វើឡើងដោយសម្ងាត់[242] ហើយសារណាបន្ថែម[243]របស់ ខៀវ សំផន ទាក់ទងនឹងពេលវេលា និងខ្លឹមសារនៃសារណានេះ គឺគ្មានអ្វីក្រៅតែពីការស្មានប៉ុណ្ណោះ។

72. ក្នុងករណីណាក៏ដោយ បើមានកំហុសផ្នែកនីតិវិធីណាមួយ (ដែលការពិតគ្មានកំហុសណាមួយនោះ) មិនមានអានុភាពទៅលើខ្លឹមសារនៃសេចក្តីសម្រេចនេះឡើយ ហើយអង្គជំនុំជម្រះក៏អាចចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗនេះឡើងវិញបាន ដើម្បីលុបលាងវិការៈផ្នែកនីតិវិធីណាមួយ។ ការចេញសេចក្តីសម្រេចរបស់ អជតក ដែលផ្ទុយទៅនឹងការអះអាងរបស់គាត់[244] ដែលមិនបានបង្កឱ្យ ខៀវ សំផន រងនូវការខូចខាតនោះ មិនបង្កើតបាននូវអនាគតិណាមួយប្រឆាំងនឹងគាត់ទេ។

---

[240] ឯកសារ **E463/1/4** សំណើសុំធ្វើមោឃភាព, កថាខណ្ឌ ៧-៨ (ទាមទារថា ដីកាសម្រេចដិតចិត្ត (ឯកសារ **F38**) បានចូលជាធរមានតែនៅពេលដែលដីកានេះត្រូវបានជូនដំណឹងនៅម៉ោង ៣:០៦ រសៀលប៉ុណ្ណោះ ដែលការពិត ពេលវេលានៃការដាក់ដីកានេះ គឺនៅម៉ោង ១:៤៦ រសៀល ដែលនេះមានការពាក់ព័ន្ធគ្នាក្នុងការកំណត់អំពីពេលវេលាដែល អជតក បានសម្រេចទៅលើសេចក្តីសម្រេចចាត់តាំងចៅក្រម Rapoza ជាលាយល័ក្ខណ៍អក្សរ។ សេចក្តីសម្រេចរបស់ អជតក (ឯកសារ **E463/1/3**) បានដាក់នៅម៉ោង ២:៥២ រសៀល គឺ*ក្រោយពេល* ការដាក់ដីកាចាត់តាំង។ ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត, កថាខណ្ឌ ១១៣។

[241] *សូមមើល* ឯកសារ **E463/1/5** សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព, កថាខណ្ឌ ៤-៥។

[242] ឯកសារ **E463/1/5** សេចក្តីសម្រេចលើសំណើសុំធ្វើមោឃភាព កថាខណ្ឌ៦ *យោង* វិធាន៩៦(១), ១០៤ស្ទួន នៃវិធានផ្ទៃក្នុង។

[243] ឯកសារ **F53** សំណើសុំប្តឹងជិតចិត្ត កថាខណ្ឌ ១១៣។ ឯកសារ **E463/1/4** សំណើសុំធ្វើមោឃភាព, កថាខណ្ឌ៩-១១, ១៤។

[244] ឯកសារ **E463/1/4** សំណើសុំធ្វើមោឃភាព កថាខណ្ឌ ២១។

## V. ដំណោះស្រាយដែលស្នើសុំ

73. តាមសម្អាងហេតុដូចបានគូសបញ្ជាក់ខាងលើ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល បដិសេធសំណើសុំប្ដឹងជំទាស់ (ផ្ទាល់) ខៀវ សំផន។ សហព្រះរាជអាជ្ញាយល់ឃើញថា មានសារណាជាលាយលក្ខណ៍អក្សរគ្រប់គ្រាន់ពីភាគីទាំងអស់ ដើម្បីសម្រេចលើបញ្ហានេះ ប៉ុន្តែសហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងសវនាការផ្ទាល់មាត់លើបញ្ហានេះទេ ប្រសិនបើ អ.ជ.ត.ក សម្រេចថានឹងជួយអង្គជំនុំជម្រះនោះ[245]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
| --- | --- | --- | --- |
| ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៨ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | |
| | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | |

[245] ឯកសារ F53 សំណើសុំប្ដឹងជំទាស់ កថាខណ្ឌ១១៦ (ស្នើសុំសវនាការតទល់ជាសាធារណៈ:)។